ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# កត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា

## Factor Influencing on Career Choice Among High School Students in Cambodia

អាត សារ៉េត

ATH SARET

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# កត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា

# Factor Influencing on Career Choice Among High School Students in Cambodia


អាត សារ៉េត

ATH SARET


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្ដុះបណ្ដាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

គ្រូណែនាំគោល៖ លោកបណ្ឌិត ហាយ ចាន់ថេង

គ្រូណែនាំរង៖ លោកបណ្ឌិត ឈុក ច័ន្ទនាយ៉ា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**កត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា**» សម្រាប់បំពេញលក្ខខណ្ឌក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះ ពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ការទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទ ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**



**អាត សារ៉េត**

# លិខិតបញ្ជាក់ពីគ្រូណែនាំ

| | | | |
|---|---|---|---|
| បណ្ឌិត | **មាយ** | **ចាន់ថេង** | ជាគ្រូដឹកនាំបង្គោល |
| បណ្ឌិត | **ឈូក** | **ច័ន្ទឆាយា** | ជាគ្រូដឹកនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **អាត សារ៉េត** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**កត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា**» ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

| គ្រូដឹកនាំបង្គោល | គ្រូដឹកនាំរង |
|---|---|
| **បណ្ឌិត មាយ ចាន់ថេង** | **បណ្ឌិត ឈូក ច័ន្ទឆាយា** |
| អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ |

# លិខិតថ្លែងអំណរគុណ

ខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះអ្នកម្តាយ **អ៊ុក សុវណ្ណ** លោកឪពុក **ឌុល សំអាត** និងបងប្រុសច្បង ដែលបានផ្តល់កំណើត ព្រមទាំងចិញ្ចឹមបីបាច់ផ្តល់ឱកាសសិក្សារៀនសូត្របានពេញលេញដល់រូបខ្ញុំបាទ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណដល់ភរិយាជាទីស្រឡាញ់ **ស្រេង ថាវី** ដែលបានគាំទ្រ និងផ្តល់ឱកាសពេញលេញដល់ខ្ញុំ ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ តាំងពីចាប់ផ្តើមរហូតដល់ចប់។

ខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ ថ្នាក់ដឹកនាំ បុគ្គលិកអប់រំនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ដែលបានរួមចំណែកផ្តល់មតិយោបល់កែលម្អការសិក្សាស្រាវជ្រាវនេះ និងផ្តល់ការអនុគ្រោះពេលវេលាដល់ខ្ញុំ ឱ្យមានឱកាសធ្វើការសិក្សាស្រាវជ្រាវនេះបានពេញលេញ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានផ្តល់អាហារូបករណ៍សម្រាប់ការសិក្សានេះ ដែលជាឱកាសនៃការអភិវឌ្ឍសមត្ថភាពក្នុងគន្លងអាជីពជាបុគ្គលិកអប់រំ។ ខ្ញុំសូមគោរពថ្លែងអំណរគុណជូនលោកគ្រូអ្នកគ្រូទទួលបន្ទុកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ដែលបានផ្តល់ចំណេះដឹង បទពិសោធ និងបំណិនដល់ខ្ញុំ ក្នុងអំឡុងពេលនៃការសិក្សារយៈពេល ២ឆ្នាំមកនេះ។

ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះលោកបណ្ឌិត **មាឃ ចាន់ថេង** និងលោកបណ្ឌិត **ឈូក ច័ន្ទធាយា** ដែលលោកទាំងពីរបានលះបង់ពេលវេលាដ៏មមាញឹកផ្ទាល់ខ្លួន ដឹកនាំការសិក្សាស្រាវជ្រាវខ្ញុំបាទ ឱ្យទទួលបានលទ្ធផលផ្លែផ្កានាពេលនេះ។ ទន្ទឹមនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកគ្រូអ្នកគ្រូ លោក លោកស្រីទាំងអស់ ជាបុគ្គលិកអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងវិទ្យាល័យគោលដៅទាំង ១៨ ដែលបានផ្តល់កិច្ចសហការជិតស្និទ្ធ ជួយសម្របសម្រួលការប្រមូលទិន្នន័យក្នុងការសិក្សាស្រាវជ្រាវនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យ ជូនដល់ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ ដែលបានរួមចំណែកក្នុងការធ្វើឱ្យសម្រេចបាននូវកិច្ចការស្រាវជ្រាវនេះ សូមមានសុខភាពល្អ កម្លាំងមាំមួន សម្រេចជោគជ័យគ្រប់ភារកិច្ចការងារ ព្រមទាំងសម្រេចបាននូវពុទ្ធពរ ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងសំខាន់ពីរគឺ៖ (១) ស្វែងរកកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា, (២) សិក្សាពីភាពខុសគ្នានៃកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ដោយផ្អែកលើភេទ និងប្រភេទមុខរបរឪពុកម្តាយសិស្ស។ ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងក្នុងទម្រង់ការស្រាវជ្រាវតាមបែបបរិមាណ ដោយប្រើប្រាស់កម្រងសំណួរប្រមូលទិន្នន័យចំនួន ៨០ ល្បះសំណួរ (កម្រិតចង្អុលបង្ហាញ ៥ កម្រិត)។ ភាគសំណាកដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី១២ ឆ្នាំសិក្សា២០២១-២០២២ ចំនួន ១ ៥២០នាក់ មកពីវិទ្យាល័យចំនួន ១៨ នៃរាជធានីខេត្តចំនួន ៩ ក្នុងប្រទេសកម្ពុជា។ ទិន្នន័យដែលប្រមូលបានពីភាគសំណាកខាងលើ ត្រូវបានវិភាគដោយប្រើប្រាស់ស្ថិតិពណ៌នា (Descriptive Statistics) និងស្ថិតិសន្និដ្ឋាន (Inferential Statistics) ដើម្បីបកស្រាយលទ្ធផលស្រាវជ្រាវ។

លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា មានកត្តាធំៗចំនួន ២ ដែលជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ជាអាទិ៍៖ (១) កត្តាខាងក្រៅ (កត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច), (២) កត្តាខាងក្នុង (កត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន)។ ការវិភាគដោយប្រើប្រាស់ស្ថិតិពណ៌នាបង្ហាញថា កត្តាខាងក្រៅ (M=៣.៧៦) ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ជាងកត្តាខាងក្នុង (M=៣.៧២)។ ដោយឡែក លទ្ធផលវិភាគដោយប្រើប្រាស់ស្ថិតិសន្និដ្ឋានបង្ហាញថា កត្តាខាងក្រៅ ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ មានភាពប្រែប្រួលអាស្រ័យលើប្រភេទមុខរបរឪពុកម្តាយរបស់សិស្ស ខណៈកត្តាខាងក្នុង ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ មានភាពប្រែប្រួលអាស្រ័យលើភេទរបស់សិស្ស។

ផ្អែកលើលទ្ធផលនេះ អ្នកសិក្សាស្រាវជ្រាវបានដាក់ចេញនូវសំណូមពរចំនួន ៥ ចំណុចជាអាទិ៍៖ (១) អ្នករៀបចំគោលនយោបាយ គួរពង្រឹងយន្តការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា និងចែករំលែកព័ត៌មានទីផ្សារការងារឱ្យកាន់តែទូលំទូលាយកម្រិតអន្តរស្ថាប័នថ្នាក់ជាតិមានសមត្ថកិច្ច, (២) កម្រិតសាលារៀន

គួរពង្រឹងការអនុវត្តសេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា និងកម្មវិធីតម្រង់ទិសវិជ្ជាជីវៈដល់សិស្ស, (៣) ឪពុកម្តាយ ឬក្រុមគ្រួសារសិស្ស គួរពង្រីកការយល់ដឹងអំពីស្ថានភាពវិវត្តរបស់សង្គម និងផ្តល់មូលដ្ឋានតម្រង់ទិសអាជីពកូនៗឱ្យចំគោលដៅនៃតម្រូវការ និងលទ្ធភាពផ្ទាល់ខ្លួនរបស់ពួកគេ, (៤) បុគ្គលសិស្សផ្ទាល់ខ្លួន គួរប្រមូលព័ត៌មានពាក់ព័ន្ធឱ្យបានច្រើនតាមដែលអាចធ្វើបាន និងធ្វើស្វ័យវាយតម្លៃផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវមុននឹងសម្រេចចិត្តជ្រើសរើសអាជីពអនាគត, និង (៥) អ្នកសិក្សាស្រាវជ្រាវបន្ត គួរពិនិត្យលទ្ធភាពក្នុងការសិក្សាឱ្យកាន់តែស៊ីជម្រៅលើកម្រិតឥទ្ធិពលនៃកត្តាជះឥទ្ធិពលលើជម្រើសអាជីព ព្រមទាំងអាចស្នើឡើងនូវវិធីសាស្ត្រចាំបាច់ដែលគាំទ្រដល់ដំណើរការជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ៕

## Abstract

The purpose of this study were: (1) to find out what factors influencing on the career choices of high school students in Cambodia, and (2) to find out the differences among the factors influencing on the career choices of high school students based on gender and parents' occupation types. To meet the above objectives, this study was conducted in the form of a quantitative study using 80 questionnaires (5 levels of indication). The sample that participated in this study was 1,520 students in the 12th grade of the 2021-2022 school year from 18 high schools in 9 provinces in Cambodia. The data collected from the above sample were analyzed by using Descriptive Statistics and Inferential Statistics to interpret the research results.

The research finding revealed that there are two main factors influencing the career choices of high school students in Cambodia: (1) External factors (include sub factors: family factor, school factor, labor market information factor; and socio-economic factor), (2) Internal factors (include sub factors: self-efficacy factor, occupational expectation factor, self-perceive talent factor; and personal identity factor). Analysis using descriptive statistics shows that external factors influence the career choices of high school students in Cambodia more than internal factors. The results of the analysis using inferential statistics show that external factors affect the career choices of high school students vary depending on the occupation of the student's parents, while the internal factors affect the career choices of high school students vary depending on the gender of the students.

Based on these results, the researchers made five recommendations: (1) Policy makers should strengthen the mechanism for implementing career guidance programs and providing comprehensive consultation and sharing of labor market information at the national and institutional levels. (2) school level should strengthen the implementation of career guidance and counseling service, and vocational orientation programs for students, (3) Parents or families of students should expand their understanding of the evolving

situation of society and provide a career orientation basis for their children to target their personal needs and abilities, (4) Individual students should gather as much relevant information as possible and self-assess properly before deciding on a future career; and (5) Researchers should continue to examine the possibility of in-depth study on the level of influence of factors influencing career choices, as well as be able to propose the necessary approaches that support the career selection process of high school students.

# មាតិកា


សេចក្ដីអះអាងរបស់បេក្ខជន ........ i

លិខិតបញ្ជាក់ពីគ្រូណែនាំ ........ ii

លិខិតថ្លែងអំណរគុណ ........ iii

មូលន័យសង្ខេប ........ iv

មាតិកា ........ viii

បញ្ជីតារាង ........ xiii

ជំពូកទី១ សេចក្ដីផ្ដើម ........ ១

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៥

១.៣. គោលបំណងនៃការស្រាវជ្រាវ ........ ៩

១.៤. សំណួរស្រាវជ្រាវ ........ ៩

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៩

១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ ១០

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ១១

១.៨. និយមន័យពាក្យគន្លឹះ ........ ១២

ជំពូកទី២ រំលឹកទ្រឹស្ដី ........ ១៣

២.១. ទ្រឹស្ដីអភិវឌ្ឍអាជីព ........ ១៣

២.២. កត្តាជះឥទ្ធិពលលើជម្រើសអាជីព ........ ១៥

២.២.១. កត្តាខាងក្រៅខ្លួន ........ ១៥

២.២.១.១. កត្តាគ្រួសារ ........ ១៥
២.២.១.២. កត្តាសាលារៀន ........ ១៨
២.២.១.៣. កត្តាព័ត៌មានទីផ្សារការងារ ........ ២០
២.២.១.៤. កត្តាសង្គមសេដ្ឋកិច្ច ........ ២៤
២.២.២. កត្តាខាងក្នុងខ្លួន ........ ២៦
២.២.២.១. កត្តាភាពជឿជាក់លើខ្លួនឯង ........ ២៦
២.២.២.២.កត្តាលទ្ធផលរំពឹងទុក ........ ២៨
២.២.២.៣. កត្តាទេពកោសល្យផ្ទាល់ខ្លួន ........ ៣១
២.២.២.៤. កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ........ ៣៣
**២.៣. លទ្ធផលនៃការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ** ........ ៣៦
**ជំពូកទី៣ វិធីសាស្រ្តស្រាវជ្រាវ** ........ ៣៧
**៣.១. ការឌីហ្សាញការសិក្សាស្រាវជ្រាវ** ........ ៣៧
៣.១.១. លំហសំណាក និងភាគសំណាក ........ ៣៧
៣.១.១.១. លំហសំណាក ........ ៣៧
៣.១.១.២. ភាគសំណាក ........ ៣៧
៣.១.២. ការសាងឧបករណ៍ស្រាវជ្រាវ ........ ៣៩
៣.១.២.១. កម្រងសំណួរផ្នែកទី១ ........ ៤០
៣.១.២.២. កម្រងសំណួរផ្នែកទី២ ........ ៤០
៣.១.២.៣. កម្រងសំណួរផ្នែកទី៣ ........ ៤២

៣.១.២.៤. ការត្រួតពិនិត្យគុណភាពឧបករណ៍ស្រាវជ្រាវ ........ ៤៣
៣.១.៣. ការប្រមូលទិន្នន័យ ........ ៤៤
៣.១.៤. ការវិភាគទិន្នន័យ ........ ៤៥
**៣.២. ដំណើរការសិក្សាស្រាវជ្រាវ** ........ ៤៦
**ជំពូកទី៤ លទ្ធផល និងការពិភាក្សា** ........ ៤៩
**៤.១. ការវិភាគទិន្នន័យប្រជាសាស្ត្រ** ........ ៤៩
**៤.២. ការវិភាគលើសំណួរស្រាវជ្រាវ** ........ ៥០
៤.២.១. សំណួរស្រាវជ្រាវទី១៖ កត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា ........ ៥០
៤.២.១.១. កត្តាខាងក្រៅ ........ ៥០
៤.២.១.២. កត្តាខាងក្នុង ........ ៦១
៤.២.២. សំណួរស្រាវជ្រាវទី២៖ ភាពខុសគ្នានៃកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ដោយផ្អែកលើភេទ និងប្រភេទមុខរបរឪពុកម្ដាយ ........ ៧១
៤.២.២.១. កត្តាខាងក្រៅ ........ ៧២
៤.២.២.២. កត្តាខាងក្នុង ........ ៨៣
**៤.៣. ការពិភាក្សា** ........ ៩០
៤.៣.១. ការពិភាក្សាលើទិន្នន័យប្រជាសាស្ត្រ ........ ៩០
៤.៣.២. ការពិភាក្សាលើសំណួរស្រាវជ្រាវទី១ ........ ៩២
៤.៣.២.១. កត្តាខាងក្រៅ ........ ៩២

៤.៣.២.២. កត្តាខាងក្នុង ........ ៩៥

៤.៣.៣. ការពិភាក្សាលើសំណួរស្រាវជ្រាវទី២ ........ ៩៩

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ ១០២

**៥.១. សេចក្តីសន្និដ្ឋាន** ........ ១០២

**៥.២. សំណូមពរ** ........ ១០៥

៥.២.១. អ្នករៀបចំគោលនយោបាយនិងផែនការ ........ ១០៥

៥.២.២. អ្នកអនុវត្តកម្រិតសាលារៀន ........ ១០៦

៥.២.៣. មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ........ ១០៧

៥.២.៤. សាមីខ្លួនសិស្ស ........ ១០៧

៥.២.៥. អ្នកសិក្សាស្រាវជ្រាវ ........ ១០៨

**ឯកសារយោង** ........ ១០៩

**ឧបសម្ព័ន្ធ១** កម្រងសំណួរប្រមូលទិន្នន័យ ........ ១២៥

**ឧបសម្ព័ន្ធ២** ធាតុផ្សំនៃការសាងកម្រងសំណួរផ្នែកទី២ ........ ១៣៣

**ឧបសម្ព័ន្ធ៣** ទិន្នន័យប្រជាសាស្ត្រភាគសំណាកតាមរាជធានី ខេត្ត ........ ១៣៧

**ឧបសម្ព័ន្ធ៤** តម្លៃ Cronbach's Alpha របស់កម្រងសំណួរប្រមូលទិន្នន័យ ........ ១៤០

**ឧបសម្ព័ន្ធ៥** ចរិតលក្ខណៈនៃការឆ្លើយកម្រងសំណួរប្រមូលទិន្នន័យ លើកត្តាជះឥទ្ធិពល ........ ១៤៣

**ឧបសម្ព័ន្ធ៦** ការវិភាគ T-Test ដើម្បីរកភាពខុសគ្នារវាងភេទ ធៀបនឹងកត្តាជះឥទ្ធិពល ........ ១៥០

**ឧបសម្ព័ន្ធ៧** ការវិភាគ One-Way-Anova ដើម្បីរកភាពខុសគ្នារវាងប្រភេទមុខរបរឪពុកម្តាយសិស្ស ធៀបនឹងកត្តាជះឥទ្ធិព ........ ១៥២

**ឧបសម្ព័ន្ធ៨** លិខិតអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យ ............................................................ ១៥៤

**ឧបសម្ព័ន្ធ៩** លិខិតឧទ្ទេសនាមគ្រូណែនាំគោល និងគ្រូណែនាំរង........................................ ១៥៥

**ឧបសម្ព័ន្ធ១០** លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ .................................................. ១៥៩

**ឧបសម្ព័ន្ធ១១** លិខិតឧទ្ទេសនាមគណៈកម្មការការពារ..........................................................១៦១

# បញ្ជីតារាង


តារាង 1 គោលដៅប្រមូលទិន្នន័យស្រាវជ្រាវ......................................................................................................៣៩

តារាង 2 កម្រិតនៃភាពជឿជាក់របស់ឧបករណ៍ប្រមូលទិន្នន័យ..................................................................................៤៤

តារាង 3 ដំណើរការសិក្សាស្រាវជ្រាវ..................................................................................................................៤៦

តារាង 4 ចរិតលក្ខណៈកត្តាខាងក្រៅ ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ (n=១ ៥២០).៥០

តារាង 5 ចរិតលក្ខណៈកត្តាគ្រួសារ (n=១ ៥២០).......................................................................................................៥២

តារាង 6 ចរិតលក្ខណៈកត្តាសាលារៀន (n=១ ៥២០)..................................................................................................៥៤

តារាង 7 ចរិតលក្ខណៈកត្តាព័ត៌មានទីផ្សារការងារ (n=១ ៥២០)...................................................................................៥៧

តារាង 8 ចរិតលក្ខណៈកត្តាសង្គម-សេដ្ឋកិច្ច (n=១ ៥២០)..........................................................................................៥៩

តារាង 9 ចរិតលក្ខណៈកត្តាខាងក្នុង ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ (n=១ ៥២០)..........៦១

តារាង 10 ចរិតលក្ខណៈកត្តាភាពជឿជាក់លើខ្លួនឯង (n=១ ៥២០)..............................................................................៦២

តារាង 11 ចរិតលក្ខណៈកត្តាលទ្ធផលរំពឹងទុក (n=១ ៥២០).......................................................................................៦៤

តារាង 12 ចរិតលក្ខណៈកត្តាទេពកោសល្យផ្ទាល់ខ្លួន (n=១ ៥២០)..............................................................................៦៧

តារាង 13 ចរិតលក្ខណៈកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន (n=១ ៥២០)...............................................................................៦៩

តារាង 14 ភាពខុសគ្នានៃកត្តាខាងក្រៅ ផ្អែកលើភេទរបស់សិស្ស (n=១៥២០)..........................................................៧២

តារាង 15 ភាពខុសគ្នានៃកត្តាខាងក្រៅ ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)..........................................៧២

តារាង 16 ការលម្អិតពីភាពខុសគ្នានៃកត្តាខាងក្រៅ ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)..............៧៣

តារាង 17 ភាពខុសគ្នានៃកត្តាគ្រួសារ ផ្អែកលើភេទរបស់សិស្ស (n=១៥២០)..............................................................៧៥

តារាង 18 ភាពខុសគ្នានៃកត្តាគ្រួសារ ផ្អែកលើស្ថានភាពប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)...........................៧៥

តារាង 19 ការលម្អិតពីភាពខុសគ្នានៃកត្តាគ្រួសារ ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)....................៧៦

តារាង 20 ភាពខុសគ្នានៃកត្តាសាលារៀន ផ្អែកលើភេទរបស់សិស្ស (n=១៥២០) ........ ៧៧
តារាង 21 ភាពខុសគ្នានៃកត្តាសាលារៀន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៧៨
តារាង 22 ការលម្អិតពីភាពខុសគ្នានៃកត្តាសាលារៀន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៧៩
តារាង 23 ភាពខុសគ្នានៃកត្តាព័ត៌មានទីផ្សារការងារ ផ្អែកលើភេទរបស់សិស្ស (n=១៥២០) ........ ៨០
តារាង 24 ភាពខុសគ្នានៃកត្តាព័ត៌មានទីផ្សារការងារ ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៨១
តារាង 25 ភាពខុសគ្នានៃកត្តាសង្គម-សេដ្ឋកិច្ច ផ្អែកលើភេទរបស់សិស្ស (n=១៥២០) ........ ៨២
តារាង 26 ភាពខុសគ្នានៃកត្តាសេដ្ឋកិច្ច-សង្គម ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៨២
តារាង 27 ភាពខុសគ្នានៃកត្តា ខាងក្នុង ផ្អែកលើភេទរបស់សិស្ស (n=១៥២០) ........ ៨៣
តារាង 28 ភាពខុសគ្នានៃកត្តា ខាងក្នុង ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៨៣
តារាង 29 ភាពខុសគ្នានៃកត្តាភាពជឿជាក់លើខ្លួនឯង ផ្អែកលើភេទរបស់សិស្ស (n=១៥២០) ........ ៨៤
តារាង 30 ភាពខុសគ្នានៃកត្តាភាពជឿជាក់លើខ្លួនឯង ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៨៥
តារាង 31 ភាពខុសគ្នានៃកត្តាលទ្ធផលរំពឹងទុក ដោយផ្អែកលើភេទរបស់សិស្ស (n=១៥២០) ........ ៨៥
តារាង 32 ភាពខុសគ្នានៃកត្តាលទ្ធផលរំពឹងទុក ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៨៦
តារាង 33 ភាពខុសគ្នានៃកត្តាទេពកោសល្យផ្ទាល់ខ្លួន ផ្អែកលើភេទរបស់សិស្ស (n=១៥២០) ........ ៨៦
តារាង 34 ភាពខុសគ្នានៃកត្តាទេពកោសល្យផ្ទាល់ខ្លួន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៨៧
តារាង 35 ការលម្អិតភាពខុសគ្នានៃកត្តាទេពកោសល្យផ្ទាល់ខ្លួន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៨៧
តារាង 36 ភាពខុសគ្នានៃកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ផ្អែកលើភេទរបស់សិស្ស (n=១៥២០) ........ ៨៩
តារាង 37 ភាពខុសគ្នានៃកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០) ........ ៩០

# ជំពូកទី១

# សេចក្ដីផ្ដើម

# ជំពូកទី ១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ឆ្លើយតបនឹងបរិបទសាកលភាវូបនីយកម្ម និងចរន្តនៃបដិវត្តឧស្សាហកម្ម ៤.0 រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវក្រុបខណ្ឌគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសំខាន់ៗប្រទាក់ក្រឡាគ្នាក្នុងកម្រិតថ្នាក់ជាតិផង និងក្នុងកម្រិតបច្ចេកទេសតាមរយៈក្រសួង ស្ថាប័ន អង្គភាពជាសេនាធិការនានាផង សំដៅរុញច្រាននាវាកម្ពុជា ឱ្យឈានឆ្ពោះទៅសម្រេចបាននូវសេចក្តីប្រាថ្នា ក្នុងការប្រែក្លាយឋានៈរបស់កម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៧, ២០១៩)។

តាមរយៈចក្ខុវិស័យនេះ រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា បាននិងកំពុងឈានដល់ដំណាក់កាលថ្មីនៃការអភិវឌ្ឍផ្លាស់ប្តូរពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសពឹងផ្អែកលើវិស័យឧស្សាហកម្ម ដែលនឹងរួមចំណែកដ៏សំខាន់ដល់ការបង្កើតការងារ ការបង្កើនប្រាក់ចំណូល និងលើកកម្ពស់ផលិតភាពការងារ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៥a, ២០១៥b, ២០១៨)។ ការណ៍នេះ បានផ្តល់ឱ្យកម្ពុជាក្លាយជាប្រទេសដែលសម្រេចបាននូវផលកំណើនផ្នែកសេដ្ឋកិច្ចខ្ពស់ក្នុងតំបន់ ប្រកបដោយចីរភាព និងមានលក្ខណៈអំណោយផលលើកត្តាប្រជាសាស្ត្រសម្រាប់បន្តជំរុញកំណើន និងការអភិវឌ្ឍជាតិ ជាពិសេសក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថលូបនីយកម្ម (រាជរដ្ឋាភិបាលកម្ពុជា, ២០២១)។ ភាគលាភផ្នែកប្រជាសាស្ត្រ ជាផ្នែកមួយរួមចំណែកផ្តល់សក្តានុពលខ្ពស់ដល់កម្ពុជា ក្នុងការទាក់ទាញវិនិយោគិនពីបរទេសឱ្យចូលមកបណ្តាក់ទុនរកស៊ីជាបន្តបន្ទាប់ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៥b)។ ទីផ្សារការងាររបស់ប្រទេសកម្ពុជាដែលមានភាពបត់បែន និងផលិតកម្មការងារពឹងផ្អែកខ្លាំងលើកម្លាំងពលកម្មនេះ ជាកត្តាគន្លឹះមួយនៃនិន្នាការវិវត្តជាវិជ្ជមាន (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨) ដែលបង្កើតបាននូវឱកាសការងារសម្រាប់យុវជន និងស្ត្រី ក្នុងវិស័យឧស្សាហកម្មមានតម្រូវការកម្លាំងពលកម្មច្រើន ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ច និងប្រាក់ចំណូលខ្ពស់ដល់ប្រជាជនម្នាក់ៗ

ព្រមទាំងផ្ដល់ឱ្យនូវលក្ខខណ្ឌការងារល្អ ផ្សារភ្ជាប់នឹងការផ្ដោតយកចិត្តទុកដាក់លើសុខុមាលភាពកម្លាំងពលកម្មទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ (ក្រសួងអប់រំយុវជននិងកីឡា, ២០១៩; រាជរដ្ឋាភិបាលកម្ពុជា, ២០១៧, ២០១៩)។

យុវជន ដែលជាកម្លាំងពលកម្មស្នូល និងជាសសរទ្រូងប្រទេសជាតិផងនោះ ត្រូវទទួលបានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដោយផ្ដល់ឱកាសទទួលបាននូវការសិក្សារៀនសូត្រប្រកបដោយគុណភាព និងបរិយាបន្ន ដើម្បីបណ្ដុះបណ្ដាលពួកគេឱ្យមានសមត្ថភាពពេញលេញក្នុងការឈានចូលទៅកាន់ទីផ្សារការងារដោយងាយស្រួល។ និន្នាការនេះ បានឆ្លើយតបទៅនឹងបំណងប្រាថ្នា ឬអាចថាជាគោលដៅសំខាន់បំផុតរបស់យុវជនភាគច្រើន ចង់ទទួលបានឱកាសការងារល្អ មានគុណតម្លៃក្នុងសង្គម ភ្ជាប់ជាមួយនឹងក្ដីរំពឹងចង់បានប្រាក់កម្រៃសមរម្យសម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ (Bandura, 2002)។ ក្នុងន័យនេះ ក្រសួងអប់រំយុវជននិងកីឡា (២០១១) បានដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិស្ដីពី ការអភិវឌ្ឍយុវជនកម្ពុជា សំដៅរួមចំណែកអភិវឌ្ឍយុវជនឱ្យកាន់តែមានលក្ខណៈសម្បត្តិវិជ្ជមាន និងផ្ដល់ឱកាសឱ្យពួកគេអភិវឌ្ឍសក្ដានុពលផ្ទាល់ខ្លួននៅក្នុងការអប់រំ ការងារ សុខភាព ការចូលរួមធ្វើសេចក្ដីសម្រេចចិត្តនានា ព្រមទាំងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍មូលដ្ឋាន សង្គមជាតិ និងពិភពលោក។ ជាមួយគ្នានេះ ការបង្កើនភាពឆ្លើយតបឱ្យកាន់តែពេញលេញនៃការអប់រំ ទៅនឹងស្ថានភាពតម្រូវការទីផ្សារការងារបច្ចុប្បន្នតាមទិសស្លោក «យុវជនម្នាក់ មានជំនាញមួយយ៉ាងតិចប្រចាំជីវិត» គឺជាទស្សនាទានគន្លឹះក្នុងការជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធពិនិត្យលទ្ធភាពរៀបចំ និងចូលរួមបង្កើតគំនិតសហគ្រិនភាព បណ្ដុះភាសាបរទេស ពង្រឹងការអប់រំស្វែម ការអប់រំបំណិនជីវិត ការតម្រង់ទិសអាជីព និងភាពជាអ្នកដឹកនាំដល់យុវជន (ក្រសួងអប់រំយុវជននិងកីឡា, ២០២១b; រាជរដ្ឋាភិបាលកម្ពុជា, ២០១៩)។ ការអប់រំកម្រិតមធ្យមសិក្សាគឺជាដំណាក់កាលមួយដ៏មានសារៈសំខាន់សម្រាប់យុវជនយើង ក្នុងការផ្សារភ្ជាប់រវាងចំណេះដឹងមូលដ្ឋានពីសាលារៀន ឆ្ពោះទៅកាន់ការចាប់យកមុខជំនាញជាក់លាក់នៅកម្រិតឧត្ដមសិក្សា និងឈានទៅកាន់ពិភពការងារមួយពិតប្រាកដ (Amoah, 2015)។ លទ្ធភាពតោងចាប់ជំនាញជាក់លាក់នៅការអប់រំកម្រិតឧត្ដម

សិក្សារបស់យុវជនម្នាក់ៗ ដើម្បីអាចទទួលបានចំណេះដឹង ជំនាញ និងឥរិយាបថជាវិជ្ជមាន សម្រាប់ជាបច្ច័យដឹកនាំពួកគេទៅរកភាពជោគជ័យក្នុងអាជីពនាពេលអនាគត ពោលគឺការធ្វើសមាហរណកម្មខ្លួនពីសាលារៀនទៅទីផ្សារការងារប្រកបដោយភាពជឿជាក់ មានទំនុកចិត្ត អាចសម្រេចទៅបាន គឺត្រូវពឹងអាស្រ័យខ្លាំងទៅលើដំណាក់កាលត្រៀមឆ្លងភូមិសិក្សារបស់ពួកគេ នៅអំឡុងពេលកំពុងទទួលការអប់រំមធ្យមសិក្សាទុតិយភូមិ ជាពិសេសនៅថ្នាក់ទី១២។ គោលដៅមួយក្នុងចំណោមគោលដៅធំៗទាំងបីនៃអនុវិស័យការអប់រំមធ្យមសិក្សាកម្ពុជា គឺធ្វើយ៉ាងណាបង្កលក្ខណៈបើកទូលាយ និងពង្រីកគន្លងចំណេះដឹងរបស់សិស្សកម្រិតមធ្យមសិក្សា ដើម្បីពួកគេមានលទ្ធភាពពេញលេញបន្តទៅឧត្តមសិក្សា ឬការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ឬចូលធ្វើការងារដែលផ្តល់ឱ្យនិយោជកនូវផលិតភាពខ្ពស់ (ក្រសួងអប់រំយុវជននិងកីឡា, ២០២១b)។ ទន្ទឹមនេះ ក្រសួងអប់រំយុវជននិងកីឡា (២០២១a) បានដាក់ឱ្យដំណើរការការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមគ្រឹះស្ថានមធ្យមសិក្សាពីឆ្នាំ២០១៥ ដោយរំលេចវត្ថុបំណងសំខាន់នៃកម្មវិធីគឺដើម្បីពង្រឹងគុណសម្បទាផ្ទាល់ខ្លួនរបស់យុវជនម្នាក់ៗ មានជាអាទិ៍៖ ការជំរុញវឌ្ឍនភាពលើលទ្ធផលសិក្សា (អភិវឌ្ឍការអប់រំ) មានលទ្ធភាពកំណត់ជម្រើសមុខជំនាញបន្តការសិក្សា ឈានឆ្ពោះទៅចាប់យកការងារ-អាជីពជាក់លាក់ (អភិវឌ្ឍអាជីព) និងមានឥរិយាបថវិជ្ជមានក្នុងការដឹកនាំជីវិតផ្ទាល់ខ្លួនក្នុងសង្គមស៊ីវិល័យ (អភិវឌ្ឍបុគ្គលិកលក្ខណៈ/ទំនាក់ទំនងសង្គម) របស់យុវជនក្នុងដំណាក់កាលពួកគេស្ថិតក្នុងសាលារៀន គឺជាការរួមចំណែកមួយនៃការទទួលខុសត្រូវខ្ពស់ក្នុងការពង្រឹងសមត្ថភាព គុណភាពនៃជីវិតផ្ទាល់ខ្លួន សម្រាប់ជាមាគ៌ារឹងមាំដឹកនាំឆ្ពោះទៅកាន់វិថីអាជីពត្រចះត្រចង់នាពេលអនាគត (នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ, ២០២១)។ ក្នុងន័យនេះ ការអភិវឌ្ឍអាជីព គឺជាចំណែកមួយដែលនឹងត្រូវផ្តល់ឱ្យយុវជនកម្រិតមធ្យមសិក្សានូវមូលដ្ឋានគ្រិះរិះពិចារណាឱ្យបានច្បាស់លាស់ មុននឹងសម្រេចចិត្តជ្រើសរើសអាជីពការងារ និងមុខជំនាញសិក្សាកម្រិតឧត្តមសិក្សា ក្រោយពេលពួកគេបញ្ចប់ការសិក្សាថ្នាក់ទី១២ តាមរយៈកញ្ចប់កម្មវិធីតម្រង់ទិសវិជ្ជាជីវៈ។ Hiebert (2009) បានបង្ហាញការគាំទ្រលើគុណប្រយោជន៍នៃការផ្តល់ប្រឹក្សាអាជីព ដោយលើកឡើងថា ការសម្រេចចិត្តជ្រើសរើសអាជីព នៅតែជាបញ្ហាដ៏ស្មុគស្មាញ និងផ្តល់ផលវិបាក ឬ

ជះឥទ្ធិពលរយៈពេលវែង មានលក្ខណៈមិនប្រាកដប្រជា។ ដូច្នេះហើយ បុគ្គលជាច្រើនត្រូវការជំនួយអន្តរាគមន៍ក្នុងការស្វែងរកជម្រើសសមរម្យ និងថ្លឹងថ្លែងអំពីបញ្ហាដែលអាចកើតមាននៅថ្ងៃអនាគត ជុំវិញជម្រើសអាជីពដែលពួកគេត្រូវសម្រេចចិត្តជ្រើសរើស។ ការសម្រេចចិត្តជ្រើសរើសអាជីព គឺជាអ្វីដែលបុគ្គលគ្រប់រូបគប្បីពិចារណាឱ្យបានល្អិតល្អន់សព្វគ្រប់ជ្រុងជ្រោយ ជាពិសេសក្នុងដំណាក់កាលត្រៀមឆ្លងភូមិសិក្សាពីមធ្យមសិក្សាទៅកាន់ឧត្តមសិក្សាតែម្តង ព្រោះថាវាជាចំណែកមួយដែលស្ថិតនៅជាប់នឹងជីវិតប្រចាំថ្ងៃរបស់បុគ្គលម្នាក់ៗ ពោលគឺវាអាចធ្វើឱ្យជីវិតពោរពេញដោយមោទនភាព ឬជួបនឹងការមិនសប្បាយចិត្ត ជីវិតស្ថិតក្នុងស្ថានភាពសម្ពាធផ្លូវចិត្តច្រើនជាដើម។ ក្នុងន័យនេះ មានយុវជនមួយចំនួនមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលបានឱកាសបំពេញការងារត្រូវនឹងមុខជំនាញដែលខ្លួនរៀន ឆ្លើយតបទៅនឹងគោលដៅអាជីពដែលចង់បាន។ ដោយឡែក ក៏មានយុវជនមួយចំនួនផងដែរ ដែលបានសម្រេចចិត្តធ្វើការខុសជំនាញឯកទេស ដោយហេតុមានការលំបាកក្នុងការរកឱ្យឃើញនូវអ្វីដែលជាអាជីពក្នុងក្តីសុបិនពិតប្រាកដរបស់ខ្លួន។ ជាមួយគ្នានេះ មានយុវជនដែលបញ្ចប់ការសិក្សាមួយចំនួនទៀត ឈោងចាប់វិថីនៃការប្រកបមុខជំនួញអាជីវកម្មថ្មី ឬបន្តមត៌កចាស់ពីក្រុមគ្រួសារ។ ដទៃពីនេះ នៅមានក្រុមយុវជនខ្លះទៀត បានសម្រេចចិត្តត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញក្រោយពេលរៀនចប់ ក្នុងបំណងទៅជួយសម្រាលបន្ទុកការងារក្នុងគ្រួសារ (សាំង សុចិន្តា, ២០១៩)។ ស្ថានភាពទាំងនេះ បាននិងកំពុងកើតមានឡើងក្នុងចំណោមយុវជនកម្ពុជាដែលបញ្ចប់ការសិក្សាកម្រិតជំនាញនៅឧត្តមសិក្សា ឬអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ តាមរយៈការសិក្សាស្រាវជ្រាវពីមុនមកនៅតាមបណ្តាប្រទេសមួយចំនួនបង្ហាញថា លទ្ធភាពនៃការធ្វើសមាហរណកម្មរបស់យុវជនទៅកាន់ទីផ្សារការងារ ឬទៅកាន់អាជីពការងារច្បាស់លាស់ គឺមានជាប់ពាក់ព័ន្ធទៅនឹងការរៀបចំប្រព័ន្ធអន្តរាគមន៍កម្រិតសាលារៀន ដើម្បីជួយសិស្សក្នុងការរៀបចំផែនការសិក្សា ការជ្រើសរើសអាជីពដែលវាប្រមូលផ្តុំទៅដោយកត្តាពាក់ព័ន្ធជាច្រើន គួរតែត្រូវបានលើកយកមកសិក្សា (Jim E.H. Bright, 2005; Laursen, 2004; Schmitt, 2012; Susan C. Whiston, 2004; Thomas P. Dick, 1991; Watters, 2010; Zahra Hazari, 2010)។ ស្រដៀងគ្នានេះ លោក Naude (2014) បានចូលរួម

យោបល់ដែរថា ស្របពេលយុវជនដែលកំពុងសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ មានតម្រូវការចាំបាច់នូវវិធីសាស្ត្រ ការត្រៀមលក្ខណៈសម្បត្តិចូលទីផ្សារការងារ និងព័ត៌មានអំពីអាជីព ឬមុខជំនាញសិក្សាកម្រិតឧត្តមសិក្សា ដើម្បីជាមូលដ្ឋាននៃការសម្រេចចិត្តជ្រើសរើសអាជីពមួយបានសមស្រប។ ដូច្នេះ ការណែនាំអំពីអាជីព គឺជាមធ្យោបាយមួយដ៏ល្អបំផុត ក្នុងការជួយសិស្សឱ្យស្គាល់ពីខ្លួនឯង។ បន្ទាប់មក ពួកគេនឹងត្រូវសាកល្បង ធ្វើការបន្ស៊ីស្ថានភាពបុគ្គលផ្ទាល់ខ្លួនទៅនឹងចរិតលក្ខណៈនៃអាជីពណាមួយ ដើម្បីធ្វើឱ្យប្រាកដថាអាជីពនោះ ជាជម្រើសដ៏សក្តិសមបំផុតសម្រាប់រូបគេ។ ផ្អែកលើមូលដ្ឋានទ្រឹស្តីនៃការជ្រើសរើសអាជីព បុគ្គលម្នាក់ៗគប្បីសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅទៅលើទិដ្ឋភាពចម្បងៗចំនួនបួនជាអាទិ៍៖ ការឈ្វេងយល់ពីបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ចំណូលចិត្ត ឬចំណាប់អារម្មណ៍ការងារ ជំនាញនិងភាពខ្លាំង និងគុណតម្លៃការងារ (Liptak, 2008)។ មូលដ្ឋានចេញពីការឈ្វេងយល់នូវកត្តាទាំងបួននេះ ជាការរួមចំណែកផ្តល់ទស្សនាទានដ៏សំខាន់សម្រាប់បុគ្គលម្នាក់ៗមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលបានភាពជោគជ័យរីកចម្រើនក្នុងអាជីពការងារវិជ្ជាជីវៈដែលពួកគេបំពេញ រាប់ចាប់តាំងពីពេលចាប់ផ្តើមរហូតដល់ពេលចូលនិវត្តន៍លាឈប់ពីអាជីពការងារនោះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា២០១៥-២០២៥ បានបង្ហាញពីឧបសគ្គមួយក្នុងចំណោមឧបសគ្គសំខាន់ៗដែលរំខានដល់ការជំរុញវឌ្ឍនភាពសង្គម-សេដ្ឋកិច្ចជាតិ នោះគឺ៖ បញ្ហាកង្វះមូលធនមនុស្សមានចំណេះដឹង និងជំនាញបច្ចេកទេស ដែលជាបុរេលក្ខខណ្ឌចាំបាច់ដើម្បីប្រែក្លាយកម្លាំងពលកម្មឱ្យមានជំនាញនិងមានសមត្ថភាពឈោងចាប់យកបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗមានតម្លៃខ្ពស់ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៥b)។ ជាមួយគ្នានេះ គោលនយោបាយជាតិស្តីពី មុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ ក៏បានបង្ហាញពីបញ្ហាប្រឈមមួយពាក់ព័ន្ធនឹងការធ្វើពិពិធកម្មកម្លាំងពលកម្មជំនាញ ធានាឱ្យបាននូវកំណើនប្រាក់ឈ្នួល និងផលិតភាពការងារខ្ពស់ ដើម្បីមានលទ្ធភាពដោះស្រាយបញ្ហាប្រឈមក្នុងទីផ្សារការងារ និងជំរុញភាពប្រកួតប្រជែង ឆ្លើយតបទៅនឹងការអភិវឌ្ឍវិស័យឧស្សាហកម្មដ៏លឿនរហ័សនៃបណ្តាប្រទេសក្នុងតំបន់ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៥a)។

កម្ពុជា ជាប្រទេសដែលមានកំណើនប្រជាជនសកម្ម ត្រូវចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចច្រើនគួរឱ្យកត់សម្គាល់ជារៀងរាល់ឆ្នាំ។ កម្លាំងពលកម្មសកម្មទាំងនោះ នឹងនៅតែមានសក្តានុពលសកម្មភាពសេដ្ឋកិច្ចអំណោយផលដល់ការវិនិយោគនៅកម្ពុជាសម្រាប់រយៈពេល ៣០ ទៅ ៤០ ឆ្នាំខាងមុខទៀត (Bank, 2010)។ យោងតាមរបាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បង្ហាញថា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាមានប្រជាជនដែលគ្រប់អាយុចូលធ្វើការ (ស្ថិតក្នុងក្រុមអាយុចាប់ពី ១៥-៦៤ឆ្នាំ) កើនឡើងជិត ១.៦ លាននាក់ ដែលប្រហាក់ប្រហែលនឹង ៨៧ ភាគរយនៃចំនួនប្រជាជនសរុប(វិទ្យាស្ថានជាតិស្ថិតិ, ២០២០)។ តួលេខនេះ គឺជាសញ្ញាវិជ្ជមានក្នុងក្របខណ្ឌនៃការកៀរគរទាក់ទាញវិនិយោគិនពីខាងក្រៅឱ្យមកបណ្តាក់ទុកនៅកម្ពុជា។ ប៉ុន្តែអ្វីដែលជាបញ្ហាប្រឈមនៅពីក្រោយកម្លាំងពលកម្មសកម្មនេះ គឺបញ្ហាកង្វះជំនាញ កង្វះគុណវុឌ្ឍិ ក្នុងការដណ្តើមបានជោគជ័យក្នុងវិថីនៃការបំពេញការងារប្រកបដោយផលិតភាព និងប្រាក់ចំណូលខ្ពស់ (NEA, 2018b)។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញពីបញ្ហាកង្វះជំនាញ កង្វះគុណវុឌ្ឍិ ក្នុងចំណោមយុវជនកម្ពុជាដែលត្រូវចូលទៅកាន់ទីផ្សារការងារ ដែលជាហេតុធ្វើឱ្យកម្ពុជាមានការលំបាកក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាង ដើម្បីទាក់ទាញ និងដណ្តើមយកការវិនិយោគផ្ទាល់ពីបរទេស (Bank, 2010; BRONH Sopheana, 2021; NEA, 2018a, 2018b; រាជរដ្ឋាភិបាលកម្ពុជា, ២០១៥a, ២០១៥b; វិទ្យាស្ថានជាតិស្ថិតិ, ២០២០)។ ទឡ្ហីករណ៍ជាក់ស្តែងចេញពីការសិក្សាស្រាវជ្រាវមួយ បោះពុម្ពផ្សាយដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដែលមានអ្នកចូលរួមឆ្លើយសម្ភាសស្ថិតក្នុងក្រុមអាយុ២១-៣៤ ឆ្នាំ កំពុងធ្វើការងារនៅកម្ពុជាក្នុង ១៤ វិស័យផ្សេងគ្នាចំនួន ៣ ១៣៩ នាក់ ដែលពាក់ព័ន្ធនឹងបញ្ហាកង្វះជំនាញបានបង្ហាញថា មានចំនួនប្រមាណ ៧០ ភាគរយនៃអ្នកទាំងនោះបាននិងកំពុងធ្វើការស្ថិតក្នុងស្ថានភាពខុសជំនាញ (BRONH Sopheana, 2021)។ បន្ថែមលើនេះ ការសិក្សាស្រាវជ្រាវមួយទៀតរបស់ស្ថាប័នដដែលខាងលើក៏បានបង្ហាញដែរថា ក្នុងចំណោមដំណឹងជ្រើសរើសបុគ្គលិកសរុប ១ ៦៩៦ ក្នុងនោះមាន ៣១ ភាគរយដំណឹងដែលលំបាកជ្រើសរើសបុគ្គលិកឱ្យចូលធ្វើការ (NEA, 2018b)។ ការណ៍នេះអាចបញ្ជាក់បានថា មានឱកាសការងារទំនេរជាច្រើនកំពុងត្រូវបានផ្សព្វផ្សាយ

ហើយក៏មានយុវជនច្រើនដែរកំពុងស្វែងរកការងារធ្វើ ប៉ុន្តែជាលទ្ធផល និយោជកនៅតែមានការលំបាកក្នុងការស្វែងរកបុគ្គលិក ដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវទៅនឹងតម្រូវការការងាររបស់ពួកគេ (BRONH Sopheana, 2021; Gordon, 2000; NEA, 2018b)។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (២០១៩) បានបង្ហាញពីសក្តានុពលតម្រូវការធនធានមនុស្សក្នុងផ្នែកឧស្សាហកម្ម កើនឡើងប្រមាណជិត ៧០ភាគរយក្នុងចំណោមតម្រូវការកម្លាំងពលកម្មសរុបជាង ១០ម៉ឺនកន្លែង។ លោក Gordon (2000) បានលើកឡើងថាមានការងារល្អរាប់ពាន់កន្លែងក្នុងវិស័យបច្ចេកទេសឧស្សាហកម្ម មិនអាចត្រូវបានផ្គត់ផ្គង់កម្លាំងពលកម្មសមស្រប។ ការណ៍នេះ អាចដោះស្រាយទៅបានល្អកណាភាគីនិយោជកនិងសាលារៀន អាចធ្វើការងារជាមួយគ្នាបានល្អប្រសើរក្នុងការរៀបចំអប់រំតម្រង់ទិសសិស្ស សម្រាប់បំពេញតម្រូវការពិតប្រាកដនៃកន្លែងការងារទាំងនោះ នាពេលអនាគត។ ស្ថានភាពនេះ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា (២០១៩) ទទួលស្គាល់ថាកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនលើការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញ ក្នុងទីផ្សារការងារបច្ចុប្បន្នដូចជាការបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់នៅមិនទាន់គ្រប់គ្រាន់ ការបង្កើនសមត្ថភាពជំនាញនៃកម្លាំងពលកម្មដើម្បីបង្កើនផលិតភាពនៅមិនទាន់ទូលំទូលាយ ភាពមិនទាន់ឆ្លើយតបបានពេញលេញទាំងផ្នែកមុខជំនាញ កម្មវិធីសិក្សា មនសិការវិជ្ជាជីវៈ និងគុណភាពនៃការបណ្តុះបណ្តាលបច្ចេកទេសទៅនឹងតម្រូវការទីផ្សារជាក់ស្តែង។ ទន្ទឹមនេះ លទ្ធផលនៃការសិក្សានៅគ្រប់កម្រិត នៅមិនទាន់បានល្អតាមការរំពឹងចង់បាន អត្រាសិស្សបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សានៅតែខ្ពស់ អភិបាលកិច្ចតាមសាលារៀននៅមានកម្រិត វិសាលភាពគ្របដណ្តប់នៃការអប់រំបច្ចេកទេសនៅមានកម្រិត គុណភាពឧត្តមសិក្សានៅមានគម្លាតខ្ពស់ធៀបទៅនឹងតម្រូវការ និងស្តង់ដាតំបន់ ដែលប្រការទាំងអស់នេះ ទាមទារឱ្យមានការផ្តោតយកចិត្តទុកដាក់ពង្រឹង និងបង្កើនការវិនិយោគបន្ថែមទៀត(រាជរដ្ឋាភិបាលកម្ពុជា, ២០១៩)។ ក្រសួងអប់រំយុវជននិងកីឡា (២០២១c) បានដាក់ចេញនូវចំណោទបញ្ហា មួយដែលនឹងត្រូវរួមគ្នាដោះស្រាយក្នុងកម្រិតអនុវិស័យអប់រំមធ្យមសិក្សា គឺការជួយដល់សិស្សកម្រិតមធ្យមសិក្សា (ទុតិយភូមិ) ដើម្បីពួកគេមានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ក្នុងការត្រៀមលក្ខណៈសម្បត្តិបន្តឈានឆ្ពោះទៅការចាប់យកមុខជំនាញ នៅតាមគ្រឹះស្ថាន

ឧត្តមសិក្សា ឬចូលទៅកាន់ទីផ្សារការងារក្នុងដំណាក់កាលឆ្លងភូមិសិក្សា។ ស្របគ្នានេះ ទិន្នន័យវិទ្យាសាស្ត្រ ដែលទទួលបានពីរបាយការណ៍អង្កេតជដែលខាងលើ ក៏បានបង្ហាញពីកម្រិតសិក្សាអប់រំនៃកម្លាំងពលកម្ម សកម្មដែរថា កម្ពុជាមានកម្លាំងពលកម្មសរុបត្រឹម ១៤.៦ ភាគរយប៉ុណ្ណោះ ដែលបានទទួលការអប់រំបញ្ចប់ ថ្នាក់មធ្យមសិក្សាឡើងទៅ (វិទ្យាស្ថានជាតិស្ថិតិ, ២០២០)។ ជាការពិត ក្រសួងអប់រំយុវជននិងកីឡា (២០២១b) យល់ឃើញថា ការទទួលបានការអប់រំប្រកបដោយគុណភាព ពិតជារឿងមួយដ៏ចាំបាច់ណាស់ សម្រាប់បុគ្គលម្នាក់ៗ ដែលវានឹងបំពេញតួនាទីដ៏សំខាន់ក្នុងដំណើរផ្លូវឆ្ពោះទៅសម្រេច កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជាតិរបស់ប្រទេសលើគ្រប់វិស័យ (ក្រសួងអប់រំយុវជននិងកីឡា, ២០២១b; ណារ៉ុន, 2020)។ ទោះជាយ៉ាងនេះក្តី បញ្ហាគុណភាព និងភាពឆ្លើយតបនៃការអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជា ដែលជា មូលដ្ឋានបំពាក់ជំនាញដល់យុវជនជាកម្លាំងពលកម្មសកម្មរបស់ប្រទេស នៅតែជាបញ្ហាចោទ ដោយនិស្សិត ដែលបញ្ចប់ការសិក្សា ពុំទាន់មានសមត្ថភាពឆ្លើយតបបានពេញលេញទៅនឹងតម្រូវការទីផ្សារការងារ និង តម្រូវការសង្គមនៅឡើយ។ ជាមួយគ្នានេះ និស្សិតភាគច្រើនប្រមូលផ្តុំចូលរៀនលើមុខវិជ្ជា វិទ្យាសាស្ត្រសង្គម ធុរកិច្ច ច្បាប់ និងមនុស្សសាស្ត្រ ដែលមានចំនួនរហូតដល់បីភាគបួននៃនិស្សិតសរុប ខណៈនិស្សិតចូល រៀនមុខជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រតិដ្ឋ និងគណិតសាស្ត្រ ដែលជាតម្រូវការចាំបាច់ បម្រើដល់ឧស្សាហកម្មនៅមានចំនួនតិចតួចប៉ុណ្ណោះ (ក្រសួងអប់រំយុវជននិងកីឡា, ២០១៩, ២០២២a)។ ស្ថានភាពទាំងនេះ ដោយសារកម្ពុជានៅមិនទាន់មានប្រព័ន្ធអន្តរាគមន៍ ពេញលេញនៅកម្រិតសាលារៀន ដែលបង្ហាញពីគន្លងអប់រំបណ្តុះបណ្តាល និងអាជីពសម្រាប់ជាមូលដ្ឋាន ព្រមទាំងផ្តល់ព័ត៌មានជួយឱ្យសិស្ស និងក្រុមគ្រួសាររបស់ពួកគេ អាចធ្វើការសម្រេចចិត្តបានត្រឹមត្រូវអំពីជម្រើសមុខវិជ្ជាសិក្សា ជម្រើសអាជីព នាពេលអនាគត និងលទ្ធភាពនៃការចាប់យកឱកាសផ្សេងទៀត សម្រាប់ភាពជោគជ័យក្នុងជីវិត (ក្រសួង អប់រំយុវជននិងកីឡា, ២០២១b)។ លោក Maluwa-banda (1998) បានគូសបញ្ជាក់ក្នុងការសិក្សា ស្រាវជ្រាវរបស់ខ្លួនថា ការបរាជ័យរបស់សិស្សក្នុងការសម្រេចចិត្តជ្រើសរើសអាជីពឱ្យបានត្រឹមត្រូវ អាចនាំ ពួកគេទៅរកការមិនសប្បាយចិត្តធ្វើការងារ និងមានការយល់ឃើញអវិជ្ជមានទៅលើសង្គម។ សិស្សភាគ

ច្រើនបានឆ្លងកាត់ដំណាក់កាលជ្រើសរើសអាជីពនេះ ដោយមិនមានភាពប្រាកដប្រជាច្បាស់លាស់សម្រាប់ការអប់រំបន្តនៅកម្រិតឧត្តមសិក្សា និងមិនបានដឹង ឬទទួលបានព័ត៌មានច្រើនពីអ្វីដែល ពួកគេចង់បន្តនោះឡើយ ( Amininiye M. Manuel, 2009 )។

ឈរលើមូលដ្ឋានបញ្ហាប្រឈមដូចបានលើកឡើងខាងលើនេះ ការសិក្សាស្រាវជ្រាវលើប្រធានបទ **«កត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា»** ជាការចាំបាច់។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺធ្វើឡើងដើម្បី៖

១. ស្វែងរកពីកត្តាជះឥទ្ធិពលទៅលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ

២.សិក្សាពីភាពខុសគ្នានៃកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ដោយផ្អែកលើភេទ និងប្រភេទមុខរបរឪពុកម្តាយ។

## ១.៤. សំណួរស្រាវជ្រាវ

ជាការឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវដូចបានកំណត់ខាងលើ ការសិក្សាស្រាវជ្រាវនេះនឹងត្រូវធ្វើឡើងដើម្បីបកស្រាយនូវសំណួរខាងក្រោម៖

១. តើមានកត្តាអ្វីខ្លះ ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ?

២. តើកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា មានភាពខុសគ្នាដូចម្តេច ដោយផ្អែកលើភេទ និងប្រភេទមុខរបរឪពុកម្តាយ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ នឹងរួមចំណែកជាវិភាគទានស្តួចស្តើងក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខដូចបានរៀបរាប់ខាងលើ និងទាញបានជាប្រយោជន៍ក្នុងការ៖

- ផ្តល់ព័ត៌មានជារបកគំហើញវិទ្យាសាស្ត្រច្បាស់លាស់ និងជាតុចូលថ្មី ដល់អ្នកតាក់តែងគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកំណត់យន្តការអន្តរាគមន៍តាមរូបភាព

ផ្សេងៗ ក្នុងន័យរួមចំណែកអប់រំតម្រង់ទិសអាជីព និងវិជ្ជាជីវៈដល់សិស្សវិទ្យាល័យ នៅកម្ពុជា ឱ្យបានសមស្របទៅនឹងស្ថានភាពវិវត្តផ្នែកសង្គម-សេដ្ឋកិច្ចនាពេលបច្ចុប្បន្ន

- ផ្តល់មូលដ្ឋានដល់សាលារៀន រួមមានគណៈគ្រប់គ្រង គ្រូមុខវិជ្ជា គ្រូប្រឹក្សាតាមសាលារៀន និងអ្នកពាក់ព័ន្ធ អាចរៀបចំផែនការសកម្មភាពរបស់ខ្លួនបានត្រឹមត្រូវ ក្នុងការជួយសិស្សនៅដំណាក់កាលពួកគេជ្រើសរើសមុខជំនាញបន្តការសិក្សានៅកម្រិតឧត្តមសិក្សា។
- ផ្តល់ទស្សនាទានបន្ថែមដល់សិស្សមធ្យមសិក្សាទុតិយភូមិ បង្កើនការយល់ដឹងផ្ទាល់ខ្លួនពីកត្តាពាក់ព័ន្ធនានាដែលមានឥទ្ធិពលដល់ការសម្រេចចិត្តជ្រើសរើសអាជីព ដើម្បីពួកគេអាចរៀបចំខ្លួនបានពេញលេញក្នុងការចាប់យកជម្រើសអាជីពជាក់លាក់
- ផ្តល់មូលដ្ឋានដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗ អាចលើកយកប្រធានបទនេះ មកធ្វើការសិក្សាស្រាវជ្រាវបន្ថែមនាពេលអនាគត ឱ្យកាន់តែស៊ីជម្រៅគ្របដណ្តប់លើទិដ្ឋភាពផ្សេងៗទៀតដែលអាចមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា។

## ១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានវិសាលភាពឆ្លុះបញ្ចាំងពីកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅទូទាំងប្រទេសកម្ពុជា។

ដើម្បីអាចបកស្រាយលទ្ធផលខាងលើ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវធ្វើឡើងក្នុងទម្រង់ជាបរិមាណវិស័យ ដោយអ្នកស្រាវជ្រាវបានកំណត់យកសិស្សដែលកំពុងសិក្សានៅថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា២០២១-២០២២ ចំនួន ២ វិទ្យាល័យ នៃរាជធានី ខេត្តចំនួន ៩ ក្នុងប្រទេសកម្ពុជារួមមានៈ រាជធានីភ្នំពេញ ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះវិហារ ខេត្តរតនគិរី និង ខេត្តព្រះសីហនុ ដើម្បីតំណាងឱ្យសិស្សវិទ្យាល័យទូទាំងប្រទេស។ សិស្សថ្នាក់ទី១២ ដែលបានចូលរួមឆ្លើយកម្រងសំណួរស្រាវជ្រាវតាមទម្រង់ប្រមូលព័ត៌មានអនឡាញ Google Form មានចំនួនសរុប ១ ៥៦៧ នាក់។

ក្របខណ្ឌពេលវេលានៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានចាប់ផ្តើមពីខែឧសភា ដល់ខែតុលា ឆ្នាំ២០២២។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើទម្រង់ទូទៅនៃការសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ របស់វិទ្យាស្ថានជាតិអប់រំ ដែលបែងចែកជា ៥ ជំពូកធំៗ៖

**ជំពូកទី១ សេចក្តីផ្តើម៖** នៅក្នុងជំពូកនេះ មានធាតុស្នូលជាចំណងជើងរងចំនួន ៧ ចំណុចសំខាន់ៗជាអាទិ៍៖ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ និយមន័យពាក្យគន្លឹះ និងក្របខណ្ឌទស្សនាទាន។

**ជំពូកទី២ រំលឹកទ្រឹស្តី៖** ក្នុងជំពូកនេះ ជាជំពូកសំខាន់ដែលអ្នកសិក្សាស្រាវជ្រាវនឹងលើកយកមកបង្ហាញនូវទ្រឹស្តី ទស្សនាទានសំខាន់ៗ ក្របខណ្ឌគំនិត បញ្ញត្តិផ្សេងៗ និងលទ្ធផលដែលអ្នកស្រាវជ្រាវមុនៗរកឃើញ ហើយមានភាពពាក់ព័ន្ធទៅនឹងខ្លឹមសារប្រធានបទស្រាវជ្រាវ មកធ្វើអត្ថាធិប្បាយពន្យល់បកស្រាយបង្ហាញជាតឹកតាង ដើម្បីកំណត់ក្របខណ្ឌទស្សនាទាន និងជាមូលដ្ឋានក្នុងការរៀបចំឧបករណ៍ស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយ ឆ្លើយតបទៅនឹងគោលវិធីនៃការស្រាវជ្រាវបែបវិទ្យាសាស្ត្រ។

**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** ក្នុងជំពូកនេះ ការសិក្សាស្រាវជ្រាវនឹងត្រូវធ្វើឡើងតាមវិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណ ដោយបង្ហាញពីការឌីហ្សាញការសិក្សាស្រាវជ្រាវចំនួនបីចំណុចសំខាន់រួមមាន៖ ការឌីហ្សាញភាគសំណាក ការឌីហ្សាញឧបករណ៍ស្រាវជ្រាវនិងការប្រមូលទិន្នន័យ និងការឌីហ្សាញការវិភាគទិន្នន័យ។

**ជំពូកទី៤ លទ្ធផល និងការពិភាក្សា៖** ក្នុងជំពូកនេះ អ្នកសិក្សានឹងធ្វើការបកស្រាយបង្ហាញនូវលទ្ធផលស្រាវជ្រាវរបស់ខ្លួន ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់ក្នុងជំពូកទី១ខាងលើ។ បន្ថែមលើនេះ អ្នកស្រាវជ្រាវ ក៏ត្រូវធ្វើការពិភាក្សាអំពីស្ថានភាពពាក់ព័ន្ធជុំវិញលទ្ធផលដែលបានរកឃើញ ធៀបទៅនឹងទ្រឹស្តីដែលបានរៀបរាប់ក្នុងជំពូកទី២។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** ក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ដោយសំយោគមតិចេញពីក្របខណ្ឌទ្រឹស្តីក្នុងជំពូកទី២ លទ្ធផលទទួលបានក្នុងជំពូកទី៤ ដើម្បីបង្ហាញឱ្យកាន់តែស៊ីជម្រៅនូវអ្វីដែលបានស្រាវជ្រាវរកឃើញ ថាតើមានភាពឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវកម្រិតណា។ អ្នកស្រាវជ្រាវ ក៏នឹងដាក់ចេញនូវសំណូមពរមួយចំនួនជូនដល់អ្នកពាក់ព័ន្ធក្នុងការកែលម្អ ឬរៀបចំសកម្មភាពការងាររបស់ខ្លួនឱ្យបានកាន់តែល្អប្រសើរ ព្រមទាំងផ្តល់ជាការណែនាំបង្ហាញផ្លូវដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗមានមូលដ្ឋានកាន់តែច្បាស់លាស់ក្នុងការសិក្សាស្រាវជ្រាវបន្ត។

## ១.៨. និយមន័យពាក្យគន្លឹះ

កត្តាជះឥទ្ធិពល សំដៅលើកត្តាខាងក្នុង និងកត្តាខាងក្រៅដែលមានឥទ្ធិពលលើការជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ។

កត្តាខាងក្នុង សំដៅលើកត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន។

កត្តាខាងក្រៅ សំដៅលើកត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច។

សិស្សវិទ្យាល័យ សំដៅលើសិស្សានុសិស្សដែលកំពុងសិក្សានៅថ្នាក់ទី១២ នៃវិទ្យាល័យនានា ក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំសិក្សា២០២១-២០២២។

ការជ្រើសរើសអាជីព សំដៅលើការជ្រើសរើសប្រភេទការងារ ឬមុខរបរទៅថ្ងៃអនាគត ក្នុងលក្ខណៈយូរអង្វែង។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២

# រំលឹកទ្រឹស្តី

ក្នុងជំពូកនេះ ជាជំពូកសំខាន់ដែលអ្នកសិក្សាស្រាវជ្រាវនឹងលើកយកមកបង្ហាញនូវទ្រឹស្តី ទស្សនាទានសំខាន់ៗ ក្របខណ្ឌគំនិត បញ្ញត្តិផ្សេងៗ និងលទ្ធផលដែលអ្នកស្រាវជ្រាវមុនៗបានរកឃើញ ដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងប្រធានបទស្រាវជ្រាវ មកធ្វើអត្ថាធិប្បាយពន្យល់បកស្រាយ បង្ហាញជាតឹកតាង ដើម្បីកំណត់ក្របខណ្ឌទស្សនាទាន និងជាមូលដ្ឋានក្នុងការរៀបចំឧបករណ៍ស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយឆ្លើយតបទៅនឹងគោលវិធីនៃការស្រាវជ្រាវបែបវិទ្យាសាស្ត្រ។

## ២.១. ទ្រឹស្តីអភិវឌ្ឍអាជីព

អាជីព សំដៅដល់ការបំពេញការងារក្នុងរយៈពេលដ៏យូរ ដែលផ្តើមចេញពីគោលបំណងដាក់លាក់ពេញមួយជីវិត ឬឆ្លុះបញ្ចាំងពីបែបផែនជីវិតរបស់បុគ្គលម្នាក់ក្នុងការងារនោះ (ហ៊ុនឡេង, 2018)។ អាជីពមួយត្រូវបានកំណត់ថា ជាការរួមបញ្ចូលគ្នានៃលំដាប់តួនាទីដែលបុគ្គលម្នាក់បានអនុវត្តក្នុងអំឡុងពេលពេញមួយជីវិត (Super, 1980)។ លោក Michael B. Arthur (1989) បានលើកឡើងដែរថា អាជីព ជាការឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងមនុស្ស និងការបំពេញការងាររបស់មនុស្សក្នុងស្ថាប័នមួយ ដែលអាចប្រែប្រួលតាមពេលវេលា។ ការសិក្សាអំពីអាជីព ជាការសិក្សាទាំងការផ្លាស់ប្តូរបុគ្គល និងស្ថាប័នការងារ ដោយរួមបញ្ចូលទាំងការវិវត្តផ្លាស់ប្តូរក្នុងសង្គមផងដែរ (Michael B. Arthur, 1989)។

ការអភិវឌ្ឍអាជីព សំដៅលើដំណើរការផ្លូវចិត្ត និងអាកប្បកិរិយាពេញមួយជីវិត ក៏ដូចជាឥទ្ធិពលពីបរិបទដែលកំណត់អាជីពរបស់មនុស្សម្នាក់ពេញមួយជីវិត។ ដូច្នេះការអភិវឌ្ឍអាជីព ពាក់ព័ន្ធនឹងការបង្កើតគំរូអាជីព ការសម្រេចចិត្តរបស់មនុស្ស រចនាបថ ការរួមបញ្ចូលនៃតួនាទីជីវិត ការបង្ហាញនូវគុណតម្លៃ និងតួនាទីជីវិតជាដើម (Spencer G. Niles, 2013)។ បើតាម Spencer G. Niles (2013) ទ្រឹស្តីអភិវឌ្ឍអាជីព «លំហជីវិត (Life-space)» របស់លោក Donald Super មានការវិវត្តនិងត្រូវបានរកឃើញក្នុងរយៈពេលប្រមាណ ៤០ ឆ្នាំមកហើយ ដោយលោក Super និងសហការីរបស់គាត់ បានសិក្សាយ៉ាងល្អិតល្អន់ និង

កែលម្អទិដ្ឋភាពផ្សេងៗនៃទ្រឹស្តីនេះផ្អែកលើលក្ខណៈចិត្តសាស្ត្ររបស់មនុស្សទូទៅ។ Super (1969) យល់ឃើញថា ការពិពណ៌នាអំពីដំណើរការដ៏ស្មុគស្មាញនៃអាជីព ទាមទារឱ្យមានការធ្វើសំយោគលើលទ្ធផលការងាររបស់អ្នកប្រាជ្ញពីមុខវិជ្ជាផ្សេងៗដូចជា ចិត្តវិទ្យា និងសង្គមវិទ្យាជាដើម ដើម្បីឈានដល់ការបង្កើតទស្សនាទានថ្មីស្តីពី ការអភិវឌ្ឍអាជីព។ ទ្រឹស្តី «លំហជីវិត (Life-space)» ជាការរួមបញ្ចូលនូវតួនាទីជីវិតដែលមនុស្សបានប្រព្រឹត្តជាប្រចាំថ្ងៃ បង្កើតបានជារបៀបរស់នៅក្នុងសង្គម ដែលវាជាតុផ្សំក្នុងរចនាសម្ព័ន្ធបង្កើតបានជា «គំរូអាជីព» (Super, 1980)។ តួនាទីជីវិត មានអន្តរកម្មក្នុងសង្គមតាមរបៀបដែលមនុស្សម្នាក់ៗប្រព្រឹត្តរៀងៗខ្លួន។ ផ្នែកលំហជីវិតនៃទ្រឹស្តីរបស់ Super ទទួលស្គាល់ថា មនុស្សខុសគ្នាក្នុងកម្រិតនៃសារៈសំខាន់ដែលពួកគេភ្ជាប់ជាមួយការងារ។ Super (1980) បានកត់សម្គាល់ថា ក្នុងដំណើររស់នៅពេញមួយជីវិត មនុស្សម្នាក់ៗនឹងត្រូវដើរតួនាទីសំខាន់ចំនួនប្រាំបួនតាមលំដាប់លំដោយបន្តបន្ទាប់គ្នាជាអាទិ៍៖ (១) កូនក្នុងក្រុមគ្រួសារ, (២) សិស្ស, (៣) ការសម្រាកលំហែ, (៤) ពលរដ្ឋក្នុងសង្គម, (៥) និយោជិត, (៦) សាងគ្រួសារប្តីប្រពន្ធ, (៧) មេផ្ទះ, (៨) ឪពុកម្តាយ, (៩) និវត្តន៍ជន។ ជាទូទៅ តួនាទីជីវិតដូចបានរៀបរាប់ខាងលើ ហាក់ដូចជាស្ថិតក្នុងការសម្តែងខ្សែភាពយន្តមួយដូច្នោះដែរ ដែលដំណើររឿងនឹងត្រូវសម្តែងនៅផ្ទះ សាលារៀន កន្លែងធ្វើការ សហគមន៍... (Arnold R. Spokane, 2002)។ ដើម្បីមានភាពងាយស្រួលក្នុងការពណ៌នាអំពីគំរូតួនាទីជីវិតនេះ ការប្រើប្រាស់ឥន្ទធនូអាជីព (Life-Career Rainbow) គឺជាវិធីសាស្ត្រសង្ខេបមួយដ៏សមស្រប ដើម្បីពន្យល់នូវគោលគំនិតនៃជីវិត - អាជីព រួមទាំងសញ្ញាណនៃជីវិត ដំណាក់កាលលំហជីវិត និងរបៀបរស់នៅ ជួយសិស្ស និងមនុស្សពេញវ័យឱ្យមើលឃើញធម្មជាតិអន្តរកម្មនៃភាពខុសគ្នានៃតួនាទីដែលបង្កើតជាអាជីព និងការបង្ហាញរបៀបដែលការធ្វើឱ្យខ្លួនឯងអាចសម្រេចបាននៅក្នុងបន្សំផ្សេងៗគ្នានៃជីវិតតួនាទី(Super, 1980)។ Dalton (1989) បានធ្វើការពន្យល់ពីដំណាក់កាលទាំង ៥ នៃទ្រឹស្តីអភិវឌ្ឍអាជីពដែល Super (1969) បានលើកឡើងដូចខាងក្រោម៖

**១.ដំណាក់កាលលូតលាស់** ចាប់ពីពេលមានគភ៌ដល់អាយុប្រហែល ១៤ឆ្នាំ៖ ក្នុងអំឡុងពេលនេះ គំនិតខ្លួនឯងចាប់ផ្តើមបង្កើតតាមរយៈការកំណត់អត្តសញ្ញាណ ជាមួយនឹងតួលេខសំខាន់ៗក្នុងគ្រួសារ និង

សាលារៀន។ ចំណាប់អារម្មណ៍ និងសមត្ថភាព កាន់តែមានសារៈសំខាន់ជាមួយនឹងការបង្កើនការចូលរួមក្នុងសង្គម។

**២.ដំណាក់កាលរុករក** ជាធម្មតារាប់បញ្ចូលទាំងរយៈពេលចាប់ពីអាយុ ១៥ ឆ្នាំដល់ ២៥៖ រយៈពេលនេះ បើយោងតាម Super ត្រូវបានកំណត់លក្ខណៈដោយការលេចឡើងនៃគំនិតខ្លួនឯងតាមរយៈដំណើរការនៃការពិសោធ និងការធ្វើតេស្ត។ គំនិតខ្លួនឯងផុសចេញពីអ្វីដែល Super ហៅថា «ការសាកល្បងការពិត» ជាដំណើរការដែលយុវជនសាកល្បងគំនិតខ្លួនឯងលើមជ្ឈដ្ឋានរស់នៅ។

**៣.ដំណាក់កាលនៃការបង្កើត** ចាប់ផ្ដើមពីអាយុចន្លោះពី ២៥ ទៅ ៤៥ ឆ្នាំ៖ ជាពេលវេលាដែលបុគ្គលម្នាក់ៗខិតខំប្រឹងប្រែងក្នុងការបង្កើតស្នាដៃផ្ទាល់ខ្លួន (បង្កើតមុខរបរ កសាងគ្រួសារ គិតគូរពីជីវភាពរស់នៅ) សាងភាពជាអចិន្ត្រៃយ៍នៃជីវិត។

**៤.ដំណាក់កាលថែទាំ** ចាប់ផ្ដើមពីអាយុចន្លោះពី ៤៥ឆ្នាំ រហូតដល់ពេលចូលនិវត្តន៍ពីការងារ៖ ក្ដីបារម្ភនៅដំណាក់កាលនេះ គឺការរក្សាស្ថិរភាពលំនឹងនៃជីវិត (ការងារ គ្រួសារ ជីវភាព)។

**៥.ដំណាក់កាលធ្លាក់ចុះ** ត្រូវបានរាប់ពីចន្លោះពេលនៃការចូលនិវត្តន៍ពីការងាររហូតដល់ថ្ងៃស្លាប់៖ ជាពេលវេលានៃការថមថយទាំងកម្លាំង ទាំងលទ្ធភាពនៃការបង្កើតថ្មី។ អាចនិយាយបានថា ដំណាក់កាលនេះមានរឿងជាច្រើនទៀតដែលត្រូវនិយាយអំពីការជាប់ទាក់ទងគ្នានៃការងារ និងការកម្សាន្ត ដែលបុគ្គលម្នាក់ៗទទួលអារម្មណ៍ដឹងដោយខ្លួនឯង។

## ២.២. កត្តាជះឥទ្ធិពលលើជម្រើសអាជីព

### ២.២.១. កត្តាខាងក្រៅខ្លួន

#### ២.២.១.១. កត្តាគ្រួសារ

គ្រួសារ ត្រូវបានចាត់ទុកជាផ្នែកមួយដ៏សំខាន់នៅក្នុងដំណើរនៃការអភិវឌ្ឍអាជីពរបស់យុវជន។ ផ្ដើមចេញពីទំនាក់ទំនងវិជ្ជមានដ៏រឹងមាំក្នុងក្រុមគ្រួសារ វាអាចនឹងដើរតួនាទីជាកម្លាំងស្នូលក្នុងការជំរុញទឹកចិត្តនៅពីក្រោយការស្វែងយល់ពីជម្រើសអាជីព ដោយផ្ដល់នូវមូលដ្ឋានគ្រឹះដែលជួយឱ្យបុគ្គលម្នាក់ធ្វើការសម្រេចចិត្ត

ជ្រើសរើសអាជីពមួយជាក់លាក់ (Nadya A. Fouad, 2008)។ ចិត្តវិទូជាច្រើន បានបង្ហាញការចាប់អារម្មណ៍កាន់តែខ្លាំងឡើងអំពីតួនាទីរបស់ក្រុមគ្រួសារ ទៅលើការអភិវឌ្ឍអាជីពរបស់យុវជន (Nadya A. Fouad, 2010)។ កន្លងមក មានការសិក្សាស្រាវជ្រាវជាច្រើនត្រូវបានធ្វើឡើង ដើម្បីរកឱ្យឃើញនូវឥទ្ធិពលនៃទំនាក់ទំនងជាតុផ្សំតូចៗចេញ ពីក្រុមគ្រួសារ ទៅលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់យុវជន។

នៅក្នុងការពិនិត្យឡើងវិញដ៏ទូលំទូលាយរបស់ Susan C. Whiston (2004)បង្ហាញថា ក្រុមគ្រួសារ មានឥទ្ធិពលលើដំណើរអភិវឌ្ឍន៍អាជីពរបស់យុវជនតាមវិធីជាច្រើនដែលត្រូវបានកត់សម្គាល់ដូចជាៈ ការផ្តល់នូវភាពជាគំរូតាមរយៈអាជីពដែលឪពុកម្តាយកំពុងបំពេញការងារជាប្រចាំ និងការគាំទ្រផ្នែកអារម្មណ៍មនោសញ្ចេតនា ដោយការផ្តល់ឱ្យនូវភាពកក់ក្តៅ កម្លាំងចិត្តជាប្រចាំដល់កូនៗ រាប់ចាប់ពីដំណាក់កាលកុមារភាព រហូតដល់ពួកគេក្លាយជាយុវជនពេញវ័យ (Cindy L. Juntunen, 2001; David L. Blustein & Selcuk Sirin, 2002; Susan C. Whiston, 2004)។ ការសន្និដ្ឋានដ៏សំខាន់មួយនៃការពិនិត្យឡើងវិញនេះគឺថាខណៈពេលដែលការស្រាវជ្រាវជាច្រើនបានត្រូវបានធ្វើឡើងដើម្បីរកឱ្យឃើញនូវតួនាទី និងឥទ្ធិពលរបស់គ្រួសារលើការអភិវឌ្ឍអាជីពរបស់កូនៗ បានបង្ហាញដែរថាកត្តាគ្រួសារតែម៉្យាង គឺមិនមានឥទ្ធិពលពេញលេញទៅលើជម្រើសអាជីពរបស់កុមារ ឬយុវជនក្នុងដំបូលគ្រួសារតែមួយនោះទេ ពោលគឺគេក៏ត្រូវមើលទៅលើកត្តាសេដ្ឋកិច្ច ស្ថានភាពសង្គម ភេទជាដើម ក៏ផ្តល់ផលជះទៅលើជម្រើសអាជីពផងដែរ (Susan C. Whiston, 2004)។ Nadya A. Fouad (2008) បានផ្តោតការសិក្សាទៅលើឥទ្ធិពលនៃភាពជាគំរូដែលកើតចេញអំពីក្រុមគ្រួសារដោយអះអាងថា វាបានដើរតួជាទឡ្ហីករណ៍មួយដ៏សំខាន់ ឬអាចថាជាអ្នកណែនាំផ្តល់ព័ត៌មានអំពីលទ្ធផលទាក់ទងនឹងអាជីពជាក់លាក់មួយដល់សមាជិកគ្រួសារដទៃទៀត។ អាកប្បកិរិយា និងសកម្មភាពប្រចាំថ្ងៃរបស់ឪពុកម្តាយនៅក្នុងគ្រួសារ គឺបានជះឥទ្ធិពលដល់ការគិតរបស់កូនៗដែលពួកគេនឹងកត់ចំណាំរៀនសូត្រតាម (Laursen, 2004)។ ស្ថានភាពសេដ្ឋកិច្ចសង្គមគ្រួសារត្រូវបានផ្សារភ្ជាប់ទៅនឹងគន្លងអាជីពរបស់កុមារដោយប្រយោល តាមរយៈឥទ្ធិពលរបស់វាទៅលើប្រសិទ្ធភាពនៃការយល់ឃើញរបស់ឪពុកម្តាយ និងសេចក្តីប្រាថ្នាសិក្សា(Albert Bandura, 2001)។ ជាមួយគ្នានេះ ផ្គត់ផ្គង់ធនធាន

ហិរញ្ញវត្ថុបានគ្រប់គ្រាន់ សម្រាប់ការចម្រើនវ័យលូតលាស់តាមដំណាក់កាលនីមួយៗរបស់កូនៗពីសំណាក់ក្រុមគ្រួសារ ក៏ជាផ្នែកមួយដែលមានឥទ្ធិពលទៅលើជម្រើសអាជីពរបស់ពួកគេផងដែរ (Chan, 2020; Fouad, 2007; Nadya A. Fouad, 2008)។ បើតាម Fouad (2007) ឪពុកម្ដាយមួយចំនួន បានកំណត់ជ្រើសរើសទុក ឬបង្ហាញផ្លូវអាជីពដល់កូនៗរបស់ខ្លួនតាំងពីពួកគេនៅកុមារភាពមកម្ល៉េះ ដែលការណ៍នេះ វាបានផ្ដល់ឱ្យកូនៗនូវរូបភាពអាជីពមុខរបរ វប្បធម៌នៃការបំពេញការងារ និងកម្រិតអប់រំ ដើម្បីឈានទៅសម្រេចបាននូវគោលដៅអាជីពណាមួយនោះរួចទៅហើយ។ បន្ថែមលើនេះ ការទំនុកបម្រុងផ្គត់ផ្គង់អាហារចាយវាយគ្រប់គ្រាន់អំឡុងពេលសិក្សារៀនសូត្ររបស់ក្រុមគ្រួសារ ក៏ជាផ្នែកមួយពាក់ព័ន្ធទៅនឹងផលសម្រេចបាននូវអាជីពជាក់លាក់របស់កូនៗដែរ (Fouad, 2007)។ ការសិក្សាស្រាវជ្រាវរបស់លោក Asad Afzal Humayon (2018) បានលើកឡើងដែរថា ការផ្ដល់ការគាំទ្រ និងទំនុកបម្រុងគ្រប់គ្រាន់ពីក្រុមគ្រួសារ គឺមានសារៈសំខាន់ណាស់ ក្នុងការធ្វើឱ្យបុគ្គលម្នាក់អាចសម្រេចបានផ្លូវអាជីពច្បាស់លាស់មួយនាថ្ងៃអនាគត។ ការរួមចំណែករបស់សមាជិកគ្រួសារដូចជា ឪពុកម្ដាយ បងប្អូន មាមីង ក្នុងការផ្ដល់នូវព័ត៌មានផ្សេងៗជុំវិញអាជីពមុខរបរដែលពួកគេកំពុងធ្វើ គឺជាផលជះវិជ្ជមានមានឥទ្ធិពលលើដំណើរអភិវឌ្ឍន៍អាជីពរបស់បុគ្គលក្នុងក្រុមគ្រួសារ (Asad Afzal Humayon, 2018; David L. Blustein & Selcuk Sirin, 2002)។ ទំនាក់ទំនងអាចមានឥទ្ធិពលលើការអភិវឌ្ឍវិជ្ជាជីវៈតាមវិធីជាច្រើន។ ការស្រាវជ្រាវថ្មីៗភាគច្រើនបានគូសបញ្ជាក់ពីភាពវិជ្ជមានការផ្សារភ្ជាប់គ្នារវាងទំនាក់ទំនងដ៏រឹងមាំ ជាពិសេសក្នុងគ្រួសារ និងការអភិវឌ្ឍវិជ្ជាជីវៈ។ ការស្រាវជ្រាវបែបគុណភាព និងបរិមាណ បានរកឃើញប្រហាក់ប្រហែលគ្នាថា ទំនាក់ទំនងរឹងមាំអាចផ្ដល់អំណាចបុគ្គលដើម្បីបង្កើតជីវិតការងារដែលពេញចិត្ត (Fouad, 2007)។

សរុបមក ផ្ដើមចេញពីការយកចិត្តទុកដាក់របស់ក្រុមគ្រួសាររួមមាន ឪពុកម្ដាយ សាច់ញាតិបងប្អូនតាមរយៈការផ្ដល់ភាពកក់ក្ដៅ ការគាំទ្រផ្លូវអារម្មណ៍ ការរំពឹងទុកច្បាស់លាស់ ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ការផ្ដល់ឱ្យនូវកញ្ចប់ព័ត៌មានចាំបាច់ និងភាពជាគំរូក្នុងការបំពេញការងារ គឺសុទ្ធតែជាការរួមចំណែកដ៏សំខាន់ក្នុងការផ្ដល់ជាមូលដ្ឋានច្បាស់លាស់ដល់បុគ្គលដែលស្ថិតក្នុងដំណាក់កាលអភិវឌ្ឍអាជីព អាចធ្វើសេចក្ដី

សម្រេចចិត្តមួយសមរម្យលើវិថីអាជីពរបស់ខ្លួននាពេលអនាគត។ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានធ្វើឡើងដើម្បីបញ្ជាក់បន្ថែមថា តើកត្តាគ្រួសារពិតជាមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជាមែន ឬយ៉ាងណា?

### ២.២.១.២. កត្តាសាលារៀន

សាលារៀន ជាប្រព័ន្ធសង្គមបើកចំហ ដែលមានទំនាក់ទំនងជាមួយបរិស្ថានខាងក្រៅ និងមានគោលដៅ អភិវឌ្ឍសិស្សប្រកបដោយគុណភាពលើផ្នែកចំណេះដឹង ជំនាញរឹង-ទន់ បំណិនជីវិត សេដ្ឋកិច្ច សង្គម នយោបាយ និងឈោងចាប់យកឱ្យខាងតែបាននូវភាពជាពលរដ្ឋសកលប្រកបដោយគុណភាព និងការទទួលខុសត្រូវខ្ពស់ (ណារ៉ុន, 2020, p. 85)។

ក្រៅតែពីដំបូលគ្រួសារ ដែលផ្តល់នូវទស្សនាទានមានឥទ្ធិពលលើដំណើរជីវិតរបស់បុគ្គលម្នាក់ (សិស្ស) សាលារៀនគឺជាទីកន្លែងទី២ ដែលបុគ្គល (សិស្ស) អាចធ្វើសង្គមកម្ម បង្កើតទំនាក់ទំនង ឥរិយាបថរស់នៅ ការទទួលបានចំណេះដឹងថ្មី ការត្រៀមខ្លួនឈោងចាប់យករបត់ថ្មីនៃជីវិតប្រកបដោយភាពជឿជាក់តាមរយៈការអប់រំផ្លូវការដែលសាលារៀនបានផ្តល់ដល់ពួកគេ (Chen, 2005)។ ចាប់ពីពេលដែលបុគ្គលម្នាក់ចូលរៀននៅថ្ងៃដំបូង រហូតដល់ពួកគេបញ្ចប់ការសិក្សាជាផ្លូវការ កុមារ និងក្មេងជំទង់ចំណាយពេលនៅក្នុងសាលារៀន ច្រើនជាងកន្លែងផ្សេងទៀតនៅខាងក្រៅផ្ទះរបស់ពួកគេ។ ពេលវេលាដ៏យូរនេះ បានផ្តល់ឱ្យកុមារ ឬយុវជនម្នាក់ៗអាចស្វែងយល់ពីមធ្យោបាយដែលស្ថាប័នអប់រំមួយនេះ ផ្តល់នូវការអភិវឌ្ឍដ៏ពិតប្រាកដមួយ និងមានឥទ្ធិពលក្នុងការលើកទឹកចិត្តដល់ពួកគេផ្ទាល់ (Eccles, 2004)។ អ្វីដែលជាការកត់សម្គាល់នោះ បុគ្គលិកលក្ខណៈ អាកប្បកិរិយា ទំនាក់ទំនងប្រចាំថ្ងៃ រចនាសម្ព័ន្ធសាលារៀន និងភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង ក៏អាចមានភាពទាក់ទង ឬផលជះដល់របៀបដែលសិស្សគិតអំពីការជ្រើសរើសអាជីព ដ្បិតថាទស្សនៈស្តីពីការងារត្រូវបានបង្កើតឡើង និងអនុវត្តផ្ទាល់ក្នុងដំណើរការសាលារៀនប្រចាំថ្ងៃ (Fouad, 2007)។ តាមរយៈការសិក្សាស្រាវជ្រាវនានាបង្ហាញថា គ្រូបង្រៀនត្រូវបានកត់សម្គាល់ថា ជាបុគ្គលដែលមានឥទ្ធិពលដល់ការជ្រើសរើស អាជីពរបស់សិស្សលើទិដ្ឋភាពផ្សេងៗ(Carlos

L. Aguado, 2015; Gheorghita M Faitar, 2013)។ ការសិក្សាមួយចំពោះសិស្សវិទ្យាល័យមិកស៊ិក អាមេរិកបង្ហាញថា សិស្សភាគច្រើនបានកំណត់បុគ្គលគំរូក្នុងសាលារៀន ដែលមានឥទ្ធិពលលើការជ្រើសរើសអាជីពរបស់ពួកគេ តាមរយៈគំរូភាពជាអ្នកដឹកនាំ ដែលផ្តល់នូវការគាំទ្រ និងការណែនាំដោយផ្ទាល់អំពីអាជីព ដែលវាមានឥទ្ធិពលវិជ្ជមានលើការសម្រេចចិត្តលើអាជីពរបស់ពួកគេ (Julius Koech, 2016)។ ជាមួយគ្នានេះ Jim E.H. Bright (2005) បានផ្តល់ការគាំទ្រដល់សារៈសំខាន់របស់គ្រូបង្រៀន ក្នុងការណែនាំអំពីអាជីព នៅពេលដែលសិស្សមានតម្រូវចង់បានព័ត៌មានបន្ថែមអំពីការជ្រើសរើសអាជីពរបស់ខ្លួន។ ការផ្សារភ្ជាប់វិធីសាស្ត្របង្រៀនតាមក្បួនគរុកោសល្យត្រឹមត្រូវ ទៅនឹងស្ថានភាពផ្លូវអារម្មណ៍របស់សិស្ស បានធ្វើឱ្យសិស្សទទួលបាននូវផាសុកភាព ពេញចិត្តនឹងរៀនមុខវិជ្ជានោះ ឆាប់យល់ចាប់បានខ្លឹមសារមេរៀន។ បន្ថែមពីនេះ ចំណេះដឹងគ្រូបូករួមនឹងបទពិសោធជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃដែលគ្រូមាន គឺជាកត្តារួមផ្សំញ៉ាំងឱ្យសមិទ្ធផលថ្មីៗក្នុងការបង្រៀន និងរៀនក្នុងថ្នាក់រៀនកាន់តែត្រូវបានរំលេចឡើងនូវភាពទាក់ទាញដែលផ្តល់ឱ្យសិស្សនូវការរំពឹងទុកខ្ពស់ ក្នុងការសម្រេចបានចំណេះដឹងមុខវិជ្ជាកាន់តែច្បាស់លាស់ថែមទៀត (Eccles, 2004; Watters, 2010)។ កត្តាគុណភាពនៃការបង្រៀន ការចូលរួមរបស់សិស្សក្នុងសកម្មភាពសាលារៀន ការដាក់ចេញនូវគោលនយោបាយប្រសិទ្ធភាពសាលារៀន និងការផ្គត់ផ្គង់សម្ភារៈសិក្សាសម្រាប់សិស្ស ការបង្កើតឱ្យមានឱកាសទស្សនកិច្ចសិក្សា កម្មវិធីពិសោធន៍ផ្សេងៗ ត្រូវបានរកឃើញថាមានឥទ្ធិពលលើអាជីពជម្រើសក្នុងចំណោមសិស្សវិទ្យាល័យ (Almon Shumba, 2012; Devwy, 1966; Kniveton, 2004)។ ដទៃពីនេះ ការរៀបចំឱ្យមានកម្មវិធីផ្តល់ប្រឹក្សាអាជីពនៅកម្រិតសាលារៀន ពិតជាបានជួយដល់សិស្សដែលមានបញ្ហាលំបាកក្នុងការស្វែងរកព័ត៌មានអំពីអាជីព ឱ្យមានឱកាសសិក្សារៀនសូត្រនិងពិភាក្សាផ្ទាល់ជាមួយគ្រូប្រឹក្សា។ ការសិក្សាដែលត្រូវបានធ្វើឡើងក្នុងបរិបទសាលារៀននៅសហរដ្ឋអាមេរិក កាណាដា និងស្វីស បានបង្ហាញពីសារៈសំខាន់នៃការផ្តល់ប្រឹក្សាអាជីពដល់សិស្ស ដែលជាផ្នែកជួយពួកគេឱ្យមានជំនឿចិត្ត ទំនាក់ទំនងជាវិជ្ជមានក្នុងសាលារៀន យល់ដឹងនិងស្គាល់ពីខ្លួនឯង ផ្តល់ព័ត៌មានអំពីដំណាក់កាលនៃការសម្រេចចិត្តពាក់ព័ន្ធ ការធ្វើផែនការអាជីព និងការណែនាំពួកគេក្នុងការស្វែងរកព័ត៌មានអំពី

អាជីពរបស់ពួកគេក្នុងក្តីសុបិន (Angela D. Bardick, 2004; Elif Balin, 2010; Rowland, 2004)។ បន្ថែមលើនេះ ចំពោះទំនាក់ទំនងនៅសាលារៀនវិញ មិត្តភក្តិដែលដើរជាមួយគ្នាកៀកកិតក៏ពិតជាមានឥទ្ធិពលដល់ការជ្រើសរើសអាជីពរបស់សិស្សផងដែរ។ សិស្ស ត្រូវបានរងឥទ្ធិពលដោយមិត្តភ័ក្តិរបស់ពួកគេតាមវិធីជាច្រើនដូចជា ការប្រឹក្សាជាមួយមិត្តភក្តិ អន្តរកម្មជាមួយមិត្តភក្តិ ទទួលជំបូន្មានពីមិត្តភក្តិជាដើម។ ការប្រឹក្សាពីមិត្តភក្តិ គឺជាវិធីនៃការទាក់ទង ឆ្លើយតបដ៏សាមញ្ញរបស់សិស្ស ក្នុងគោលបំណងស្វែងយល់ពីអារម្មណ៍ គំនិត កង្វល់ផ្សេងៗ និងការផ្តល់ក្តីសង្ឃឹមឱ្យគ្នាទៅវិញទៅមក (Gheorghita M Faitar, 2013)។ លោក Bett (2013) បានបន្ថែមថា នៅក្នុងសាលារៀន ការជួបប្រាស្រ័យប្រឹក្សាគ្នាជាមួយមិត្តភក្តិ គឺជាបាតុភូតមួយដែលត្រូវបានបង្កើតឡើងដើម្បីជួយគ្នា និងមានឥទ្ធិពលលើគ្នាមិនអាចប្រកែកបាន។

សរុបសេចក្តីមក សាលារៀនជាទីកន្លែងមួយមិនត្រឹមតែបានផ្តល់នូវចំណេះដឹង ជំនាញ និងឥរិយាបថនៃការរស់នៅរបស់សិស្សប៉ុណ្ណោះទេ គឺថែមទាំងបានជះឥទ្ធិពលលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សផងដែរ។ តាមរយៈខ្លឹមសារខាងលើ ជាតុផ្សំសំខាន់ៗដែលមាននៅក្នុងសាលារៀននិងបានផ្តល់ផលជះលើជម្រើសអាជីពរបស់សិស្សរួមមាន ឥទ្ធិពលរបស់គ្រូបង្រៀន មិត្តភក្តិ លទ្ធផលនៃការសិក្សាសិស្ស កម្មវិធីប្រឹក្សាអាជីព សម្ភារៈគាំទ្រដល់ដំណើរការបង្រៀននិងរៀន ព្រមទាំងភាពជាគំរូរបស់គ្រូនិងគណៈគ្រប់គ្រងសាលារៀន។ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានធ្វើឡើងដើម្បីបញ្ជាក់បន្ថែមថាតើ តើកត្តាសាលារៀន ពិតជាមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជាមែន ឬយ៉ាងណា។

### ២.២.១.៣. កត្តាព័ត៌មានទីផ្សារការងារ

បុគ្គលគ្រប់រូបក្នុងសង្គម មានក្តីប្រាថ្នាចង់បានស្ថិរភាពការងារជាក់លាក់ ជាគុណតម្លៃនៃជីវិតរស់នៅក្នុងសង្គម។ ការសម្រេចចិត្តជ្រើសរើសអាជីពការងាររបស់បុគ្គលទូទៅ អាចផ្តោតការចាប់អារម្មណ៍ពីជ្រុងផ្សេងៗគ្នា។ អ្នកខ្លះជ្រើសរើសអាជីពការងារ ដែលជាមត៌កបន្តជំនាញនៃក្រុមគ្រួសារ ខ្លះជ្រើសរើសដោយហេតុផលតម្រូវការសេដ្ឋកិច្ចជាដើម។ ជាទូទៅ រចនាសម្ព័ន្ធនៃឱកាសទីផ្សារការងារនៅជុំវិញខ្លួន គឺមានឥទ្ធិពលខ្លះៗទៅដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់បុគ្គលនោះ។

ជម្រើសអាជីពរបស់មនុស្ស អាចមានទំនោរទទួលឥទ្ធិពលពីស្ថានភាពព័ត៌មានទីផ្សារការងារ ដែលពួកគេបានដឹង និងមានបទពិសោធ (Amininiye M. Manuel, 2009)។ ជាការពិត ក្ដីស្រមៃ និងការប្រាថ្នាចង់បានរបស់មនុស្សក្នុងសង្គមរមែងតែងតែប៉ងយកឱកាសធ្វើការងារល្អ មានប្រាក់កម្រៃច្រើនដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅបានសមរម្យក្នុងសង្គមស៊ីវិល័យ។ ជាមួយគ្នានេះ ស្ថិរភាពការងារបានយូរអង្វែងក៏ជាកត្តាសំខាន់សម្រាប់បុគ្គលមួយចំនួនលើកមកគិតពិចារណាថ្លឹងថ្លែងជាមុនផងដែរ មុននឹងរូបគេសម្រេចចិត្តថាគួរចាប់អាជីពការងារអ្វីនោះ (Nadya A. Fouad, 2008)។ Monica Kirkpatrick Johnson (2002) លើកឡើងថា សង្គមវិទូបានធ្វើការសិក្សាពិចារណាអំពីភាពជាប់ពាក់ព័ន្ធគ្នានៃរចនាសម្ព័ន្ធស្ថាប័នអប់រំ និងស្ថាប័នទីផ្សារការងារ ដើម្បីស្វែងយល់នូវសារៈសំខាន់ដែលស្ថាប័នទាំងពីរនេះបំពេញឱ្យគ្នាទៅវិញទៅមក។ ពួកគេសិក្សាស្វែងរក និងកំណត់នូវវិធីដែលស្ថាប័នទាំងពីរផ្ដល់ផលជះទៅលើការកំណត់គោលដៅអាជីពរបស់សិស្ស។ ស្ថាប័នអប់រំ ទទួលបានព័ត៌មានអំពីនិន្នាការវិវត្តនៃទីផ្សារការងារ តម្រូវការកម្លាំងពលកម្ម និងការពិពណ៌នាអំពីប្រភេទអាជីពការងារផ្សេងៗ ដែលក្នុងនោះមានរួមបញ្ចូលនូវលក្ខខណ្ឌការងារ ការពិពណ៌នាអំពីមុខតំណែង ប្រាក់បៀវត្សទទួលបាន និងអត្ថប្រយោជន៍ផ្សេងៗ នៅអំឡុងពេលធ្វើការងារ ឬចូលនិវត្តន៍(NEA, 2018a; ហ៊ុនឡេង, 2018)។ ព័ត៌មានទាំងនេះ ជាមូលដ្ឋានច្បាស់លាស់ក្នុងការរួមចំណែកផ្ដល់ដល់សិស្ស ដើម្បីឱ្យពួកគេពិចារណាថ្លឹងថ្លែង ព្រមទាំងឆ្លុះបញ្ចាំងទៅលើស្ថានភាពបុគ្គលផ្ទាល់ខ្លួន ថាតើសក្ដិសមនឹងខ្លួន ត្រូវនឹងចំណាប់អារម្មណ៍ចំណូលចិត្តកម្រិតណា។ រចនាសម្ព័ន្ធឱកាសការងារទាំងនេះ បានផ្ដល់វិបាកក្នុងការសម្រេចចិត្តអាជីពរបស់មនុស្ស ដែលពេលខ្លះមនុស្សសម្រេចជ្រើសរើសធ្វើការក្នុងអាជីពណាមួយផ្អែកលើបរិយាកាសការងារ ដែលពួកគេបានដឹងឮ និងមានភាពឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ខ្លួន (Nadya A. Fouad, 2008)។ ស្ថានភាពគ្រួសារ សេដ្ឋកិច្ចសង្គម ជីវភាពរស់នៅរបស់មនុស្សមិនដូចគ្នាទាំងស្រុងនោះទេ ដែលការណ៍នេះនាំឱ្យការគិតក៏មានភាពខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតផងដែរ។ ជាទូទៅ អ្នកដែលរស់នៅតំបន់ជនបទ នៅឆ្ងាយពីប្រភពព័ត៌មានជាងអ្នកដែលនៅទីប្រជុំជន ឬទីក្រុង។ ដូច្នេះហើយ បើផ្អែកលើទីតាំងភូមិសាស្ត្រ យុវជនដែលរស់នៅជនបទ អាចមានលទ្ធភាព

ទទួលព័ត៌មានអំពីឱកាសសម្បូរបែបពាក់ព័ន្ធការអប់រំបន្តនៅកម្រិតឧត្តមសិក្សា ការទទួលបានគុណវុឌ្ឍិ តម្រូវការជំនាញ ឱកាសការងារ តិចតួចជាងយុវជននៅទីប្រជុំជន (Monica Kirkpatrick Johnson, 2002)។ ប្រការនេះ បានជះឥទ្ធិពលដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់យុវជន ដែលពេលខ្លះពួកគេសម្រេចចិត្តចូលធ្វើការងារដែលមានស្រាប់នៅមូលដ្ឋានក្បែរៗផ្ទះ។ ជាមួយគ្នានេះ អ្នកខ្លះសម្រេចចិត្តជ្រើសរើសអាជីពការងារផ្អែកលើស្ថានភាពស្ថិរភាពរឹងមាំ តួយ៉ាងដូចជាអាជីពជាមន្ត្រីរាជការនៅកម្ពុជាជាដើម។ កម្រិតខ្ពស់នៃការធ្វើសមាហរណកម្មចូលទៅកាន់ទីផ្សារការងាររបស់ពួកគេ អាចត្រូវបានកំណត់ថាជាការកាន់ការងារដែលមានស្ថិរភាព។ ជាធម្មតា វាជាការងារពេញម៉ោងអចិន្ត្រៃយ៍ផ្តល់ឱ្យនូវប្រាក់ឈ្នួល មុខតំណែង និងតម្លៃសង្គមសមស្របទៅនឹងប្រភេទ និងកម្រិតនៃជំនាញរបស់បុគ្គលម្នាក់ៗ (Schmitt, 2012)។ ដទៃពីនេះ Karin L. Brewster (2000) យល់ឃើញថា ការចាប់ផ្តើមគ្រួសារនៅក្នុងបរិយាកាសមិនច្បាស់លាស់នៃអាជីពការងារជាបញ្ហាលំបាកមួយសម្រាប់បុរសៗដែលត្រូវឈរជាបង្គោលគ្រួសារ។ ហេតុផលនេះ បានធ្វើឱ្យបុរសស្ត្រីជាច្រើនក្នុងពេលបច្ចុប្បន្ន ទំនងជាត្រូវការពេលវេលាសមរម្យវិនិយោគក្នុងការអប់រំ និងមានទំនោរចង់ទទួលបានការងារមួយដែលមានស្ថិរភាព មានទីតាំងធ្វើការងារជាក់លាក់ មុនពេលពួកគេបង្កើតគ្រួសារ (Karin L. Brewster, 2000)។ ការចូលក្នុងទីផ្សារការងារសមរម្យ មានប្រាក់ខែគ្រប់គ្រាន់ មានពេលវេលាកម្សាន្តមានចំណង់ចង់បង្កើតកសាងគ្រួសារ ទាំងនេះជាធាតុផ្សំដំបូងនៃអត្តសញ្ញាណមនុស្សពេញវ័យ (Jeremy Staff, 2004)។ ជាមួយគ្នានេះ មានយុវជនមួយចំនួនដែលសម្រេចចិត្តជ្រើសរើសអាជីព ឬផ្លាស់ប្តូរការងារពីកន្លែងមួយទៅកន្លែងមួយថ្មី អាស្រ័យដោយការមើលឃើញពីកម្រិតប្រាក់កម្រៃដែលពួកគេទទួលបាន។ ការសិក្សារបស់ German Cubas (2017) បានឯកភាព លើចំណុចនេះ ដែលថាបុគ្គលិកដែលធ្វើការងារទាំងអស់ក្នុងសង្គម នឹងអាចទទួលបានកម្រិតប្រាក់ឈ្នួល អាស្រ័យលើប្រភេទអាជីពការងារ ឬឧស្សាហកម្មដែលពួកគេបានជ្រើសរើស(George Farkas, 1988; German Cubas, 2017)។ នាពេលបច្ចុប្បន្នគេសង្កេតឃើញថា អ្នកធ្វើការក្នុងវិស័យឧស្សាហកម្មមានលទ្ធភាពទទួលបានប្រាក់បៀវត្សខ្ពស់ជាងវិស័យផ្សេងៗ ទៀត (NEA, 2018a)។ ដទៃពីនេះ ការផ្លាស់ប្តូររចនាសម្ព័ន្ធទីផ្សារការងារ និងសកលភាវូបនីយ

កម្មក៏មានឥទ្ធិពលលើរបៀបដែលបុគ្គលមើលឃើញអាជីព បង្កើតអារម្មណ៍នៃពិភពការងារ និងកសាងអត្តសញ្ញាណវិជ្ជាជីវៈរបស់ពួកគេផងដែរ។ បុគ្គលដែលមានអារម្មណ៍អសន្តិសុខអំពីការងារ ត្រូវបានទទួលការណែនាំឱ្យពង្រឹងវិជ្ជាជីវៈ និងរៀនជំនាញថ្មីបន្ថែមដើម្បីបញ្ចៀសនូវការបាត់បង់ឱកាសការងារ នៅពេលដែលតម្រូវការថ្មីក្នុងវិថីការងារដែលពួកគេកំពុងបំពេញត្រូវបានដាក់ជំនួសអ្វីដែលធ្លាប់មាន។ នេះគឺជាការអភិវឌ្ឍថ្មី ដើម្បីរក្សាបាននូវគុណតម្លៃការងារ មុខតំណែងក្នុងស្ថាប័ន ដែលបុគ្គលធ្លាប់មាន (Gretchen M. Spreitzer, 2017)។ Fouad (2007) យល់ស្របនឹងទស្សនៈខាងលើដែរថា ការផ្លាស់ប្តូរទីផ្សារការងារក៏ប៉ះពាល់ដល់ការអភិវឌ្ឍវិជ្ជាជីវៈផងដែរ។ ទស្សនៈប្រពៃណីរបស់ការងារ និងអាជីពកំពុងផ្លាស់ប្តូរយ៉ាងខ្លាំង នៅពេលដែលទីផ្សារការងារផ្លាស់ប្តូរនៅក្នុងសហរដ្ឋអាមេរិក និងទីផ្សារពិភពលោកកំពុងផ្លាស់ប្តូរកម្លាំងពលកម្មតាមរបៀបសំខាន់ៗ។ អសន្តិសុខការងារគឺលទ្ធផលពីការផ្លាស់ប្តូរកញ្ចប់ចូលនិវត្តន៍ និងការបញ្ឈប់ការងារដោយសារការរួមបញ្ចូលគ្នា ការកែតម្រូវក្រុមហ៊ុន និងការផ្លាស់ប្តូរផែនការសោធននិវត្តន៍។ ការផ្លាស់ប្តូរទាំងនេះមានឥទ្ធិពលលើការរំពឹងទុកនៅក្នុងអនុវិទ្យាល័យ និងក្រោយការអប់រំមធ្យមសិក្សា ក៏ដូចជាតម្រូវការជំនាញសម្រាប់ការងារនាពេលអនាគត។ ការផ្លាស់ប្តូរបរិយាកាសការងារកំពុងបង្ខំបុគ្គលិកឱ្យសម្របខ្លួនទៅនឹងពិភពការងារថ្មី។ កម្លាំងពលកម្មនាពេលបច្ចុប្បន្ន ត្រូវបានស្នើឱ្យចូលរួមក្នុងការសិក្សាពេញមួយជីវិត ដើម្បីបន្តកែប្រែ កែតម្រូវ ក្នុងគោលដៅសម្របទៅនឹងការផ្លាស់ប្តូរបរិយាកាសការងារ។ ការផ្លាស់ប្តូរទាំងនេះមានឥទ្ធិពលការអភិវឌ្ឍវិជ្ជាជីវៈ (Fouad, 2007)។

សរុបសេចក្តីមក ព័ត៌មានទីផ្សារការងារ ជាចំណែកមួយដែលមានភាពជាប់ពាក់ព័ន្ធទៅនឹងការសម្រេចចិត្តជ្រើសរើសអាជីពរបស់បុគ្គលម្នាក់ៗ។ តាមរយៈខ្លឹមសារខាងលើ ជាតុផ្សំសំខាន់ៗដែលមាននៅក្នុងព័ត៌មានទីផ្សារការងារដូចជា លក្ខខណ្ឌនៃអាជីពការងារ ទីកន្លែងបំពេញការងារ ប្រាក់ចំណូលនិងអត្ថប្រយោជន៍ផ្សេងៗ តួនាទីការងារ ព្រមទាំងឱកាសការងារដែលផ្តល់ឱ្យ គឺជាកត្តារួមចំណែកផ្តល់ផលជះទៅលើជម្រើសអាជីពរបស់យុវជន។ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានធ្វើឡើងដើម្បីបញ្ជាក់បន្ថែមថា តើកត្តាព័ត៌មានទីផ្សារការងារ ពិតជាមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា មែនឬយ៉ាងណា?

### ២.២.១.៤. កត្តាសង្គមសេដ្ឋកិច្ច

ឋានៈសង្គម គឺជាអ្វីដែលមនុស្សទូទៅតែងមានការគិតគូរ។ យើងសង្កេតឃើញមានការយល់ឃើញជាច្រើនក្នុងចំណោមយុវជន ស្តីពីការផ្តល់ និងទទួលបានគុណតម្លៃសង្គមចេញពីអាជីពការងារនីមួយៗ។ ជាក្រឹត្យក្រម អាជីពការងារណាក៏មានគុណតម្លៃរបស់វាដែរ ប៉ុន្តែមនុស្សទេតើដែលកំណត់ថាអាជីពនេះល្អ អាជីពនោះមិនល្អ ការងារនេះគេកោតសរសើរច្រើន ការងារនោះមើលទៅមិនសូវមានតម្លៃជាដើម។

ប្រសិនជានិយាយក្នុងក្របខណ្ឌសង្គមសេដ្ឋកិច្ច ការធ្វើចំណាត់ថ្នាក់សង្គមគឺត្រូវបានផ្តោតការចាប់អារម្មណ៍លើជីវភាពមាន ក្រ មធ្យម គ្រប់គ្រាន់ ឬខ្វះខាត។ កន្លងមក ការសិក្សាស្រាវជ្រាវអំពីចំណាត់ថ្នាក់សង្គម មិនសូវបានយកចិត្តទុកដាក់ចំពោះកង្វល់របស់ជនក្រីក្រមានជីវភាពទន់ខ្សោយ ឬវណ្ណៈកម្មករ ដែលធៀបទៅនឹងវណ្ណៈកណ្តាល ឬវណ្ណៈអ្នកមាននៅឡើយទេ (David L. Blustein, 2002)។ ទោះជាយ៉ាងនេះក្តី ថ្នាក់សង្គម ត្រូវបានគេសន្មតថាបានដើរតួជាកត្តារចនាសម្ព័ន្ធដ៏មានឥទ្ធិពលក្នុងការអភិវឌ្ឍវិជ្ជាជីវៈ ការបង្កើតលទ្ធភាពទទួលបានធនធាន និងឥទ្ធិពលលើការសម្រេចបាននូវការងារ សេចក្តីប្រាថ្នា និងការអភិវឌ្ឍអាជីពរបស់មនុស្សក្នុងសង្គម (Anna P. Chaves, 2004)។ អ្នកស្រាវជ្រាវបានណែនាំថា វណ្ណៈសង្គមប៉ះពាល់ដល់លទ្ធភាពនៃការទទួលបានការងារ ការរក្សាស្ថិរភាពការងារ និងគុណតម្លៃការងារ (David L. Blustein, 2002)។ ជាឧទាហរណ៍ជាក់ស្តែងក្នុងបរិបទកម្ពុជា និយោជកមានបញ្ហាប្រឈមក្នុងការជ្រើសរើសកម្លាំងពលកម្មជំនាញកម្រិតមធ្យមចូលធ្វើការក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងដេរស្បែកជើង ដោយហេតុថាយុវជនយល់ថា តម្លៃថ្នាក់សង្គមសម្រាប់ការបម្រើការងារក្នុងសហគ្រាសគ្រឹះស្ថានរោងចក្រ មិនសូវមានគុណតម្លៃ ប៉ុន្តែបើគិតពីកម្រិតបៀវត្សសម្រាប់អ្នកជំនាញវិញ ឃើញថាកម្ពុជាចំណាយប្រាក់ខ្ពង់ពាន់ដុល្លារក្នុងមួយខែ ដើម្បីជួលអ្នកបច្ចេកទេសកម្រិតមធ្យមចូលធ្វើការក្នុងវិស័យនេះ (BRONH Sopheana, 2021; NEA, 2018a, 2018b)។ នេះគឺជាការខាតបង់មួយផ្នែកសេដ្ឋកិច្ច។ ស្របគ្នានេះដែរ មានការសិក្សាមួយចំនួនបានគូសបញ្ជាក់ ទំនាក់ទំនងរវាងឱកាស រចនាសម្ព័ន្ធគាំទ្រ ទំនាក់ទំនង និងការគិតគូរពីការងារសម្រាប់បុគ្គលដែលមានប្រាក់ចំណូលទាប ដោយបានគូសបញ្ជាក់ថា សិស្សដែលចេញពីស្ថានភាពជីវភាព

គ្រួសាររកចំណូលបានទាប មានការគិតគូរតែពីផលសម្រេចចុងក្រោយនៃបៀវត្សដែលគេទទួលបានប៉ុណ្ណោះ ដោយពួកគេមិនបានថ្លឹងថ្លែងអំពីគុណតម្លៃនៅកន្លែងធ្វើការ រង្វាន់លើកទឹកចិត្តលើផលិតភាពការងារ និង កត្តាអំណោយផលមួយចំនួនទៀតនៅកន្លែងការងារ (Anna P. Chaves, 2004; Maureen E. Kenny, 2003)។ Anna P. Chaves (2004) ក៏បានបង្ហាញពីសារៈសំខាន់នៃការយល់ឃើញលើឱកាសការងារ ក្នុងចំណោមយុវជនរស់នៅនៅទីក្រុងដែលមានចំណូលទាបដោយពួកគេយល់ថា ការងារគឺមានមុខងារ ចាំបាច់ដើម្បីរកប្រាក់ចំណូល។ ស្ថានភាពសេដ្ឋកិច្ចសង្គមគ្រួសារត្រូវបានផ្សារភ្ជាប់ទៅនឹងគន្លងអាជីពកុមារ ដោយប្រយោល តាមរយៈឥទ្ធិពលរបស់វាទៅលើប្រសិទ្ធភាពនៃការយល់ឃើញរបស់ឪពុកម្ដាយ (Albert Bandura, 2001)។ David L. Blustein (2002) បានបន្តលើកឡើងពីបញ្ហានេះថា យើងបានស្វែងរក ដើម្បីបង្កើតការសន្និដ្ឋានអំពីវិធីដែលថ្នាក់សង្គម ជះឥទ្ធិពលលើរបៀបដែលយុវជនចូលទៅជិត និងដោះ ស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍអាជីព នៅក្នុងការផ្លាស់ប្ដូររបស់ពួកគេទៅតួនាទីការងារ។ ឥទ្ធិពល សង្គម បង្កើតគោលនយោបាយស្ដីពីការសិក្សា ការអប់រំឧត្តមសិក្សា ការផ្លាស់ប្ដូរក្នុង និងក្រៅការងារ (ដូច ជាការឈប់សម្រាកពីគ្រួសារ និងគោលនយោបាយសម្រាប់អ្នកអត់ការងារធ្វើ) អាយុ និងដំណើរការចូល និវត្តន៍ (Fouad, 2007)។ ជាក់ស្ដែង ស្ត្រីម្នាក់ដែលធ្វើអន្តោប្រវេសន៍ពីអារ៉ាប៊ីសាអូឌីតទៅសហរដ្ឋអាមេរិក នឹងទទួលឥទ្ធិពលពីការរំពឹងទុករបស់សង្គម ដោយឱកាសអាចរកការងារបានធ្វើសម្រាប់នាងនៅក្នុងសហ រដ្ឋអាមេរិក ប្រសិននាងមានសមត្ថភាពខ្ពស់ នាងនឹងទទួលបានឱកាសការងារសមរម្យដូចគ្នាទៅនឹងស្ត្រី ដទៃទៀតដែរ (Fouad, 2007)។ គោលនយោបាយទាំងនេះ នឹងបង្ហាញពីការសម្រេចចិត្តរបស់សង្គម កើតចេញពីតម្លៃ និងអាកប្បកិរិយាដែលមាននៅក្នុងសង្គមនោះ។ ទោះបីជាមានភាពខុសប្លែកគ្នាក្នុងក្រុមក៏ ដោយ ប៉ុន្តែសហរដ្ឋអាមេរិកក្នុងនាមជាសង្គមមួយសង្កត់ធ្ងន់លើសមិទ្ធផល និងប្រាក់ចំណេញរបស់បុគ្គល ចំណែកប្រទេសអាស៊ី ដាក់តម្លៃខ្ពស់លើសមិទ្ធផលរួម។ ភាពខុសគ្នាទាំងនេះ ជាភស្តុតាងនៅក្នុងប្រាក់ខែ រចនាសម្ព័ន្ធក្នុងសង្គមនីមួយៗ ពាក់ព័ន្ធទៅនឹងគុណតម្លៃសង្គម និងភាពរីកចម្រើនផ្នែកសេដ្ឋកិច្ច (Michele J. Gelfand, 2007)។ ថ្នាក់សង្គម មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការចូលទៅកាន់រចនាសម្ព័ន្ធឱកាសការងារ

និងការអភិវឌ្ឍអាជីព (Michael T. Brown, 1996)។ David L. Blustein (2002) បញ្ជាក់ថា យើងបានស្វែងរកដើម្បីបង្កើតការសន្និដ្ឋានអំពីវិធីដែលថ្នាក់សង្គម ជះឥទ្ធិពលលើរបៀបដែលយុវជនចូលទៅជិត និងដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍអាជីព នៅក្នុងការផ្លាស់ប្តូររបស់ពួកគេទៅតួនាទីការងារ។

សរុបសេចក្តីមក កត្តាសេដ្ឋកិច្ចសង្គម ជាចំណែកមួយដែលមានភាពជាប់ពាក់ព័ន្ធទៅនឹងការសម្រេចចិត្តជ្រើសរើសអាជីពរបស់បុគ្គលម្នាក់ៗ។ តាមរយៈខ្លឹមសារខាងលើ ជាតុផ្សំសំខាន់ៗដែលមាននៅក្នុងសេដ្ឋកិច្ចសង្គមដូចជា ការផ្តល់និងទទួលស្គាល់គុណតម្លៃនៃអាជីព មានការកោតសរសើរ និងឆ្លើយតបទៅនឹងកំណើននៃតម្រូវការជាក់ស្តែងក្នុងសង្គម គឺជាកត្តារួមចំណែកផ្តល់ផលជះទៅលើជម្រើសអាជីពរបស់យុវជន។ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានធ្វើឡើងដើម្បីបញ្ជាក់បន្ថែមថា តើកត្តាសង្គមសេដ្ឋកិច្ចពិតជាមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជាមែន ឬយ៉ាងណា?

### ២.២.២. កត្តាខាងក្នុងខ្លួន

#### ២.២.២.១. កត្តាភាពជឿជាក់លើខ្លួនឯង

ភាពជឿជាក់ បានដើរតួនាទីដ៏សំខាន់ក្នុងដំណើរការសម្រេចចិត្តជ្រើសជំនាញសិក្សា និងអាជីពរបស់សិស្ស (Nancy E. Betz, 1986)។ Bandura (1977) យល់ឃើញថា មនុស្សម្នាក់ដែលមានជំនឿជាក់លើសមត្ថភាពផ្ទាល់ខ្លួន គឺជាកត្តានាំឱ្យបុគ្គលនោះទទួលបានភាពជោគជ័យក្នុងមុខនាទីភារកិច្ចដែលគេបានអនុវត្ត។ បើតាមលោក Hackett (1981) ភាពជឿជាក់របស់បុគ្គល បានជះឥទ្ធិពលទៅលើឥរិយាបថផ្ទាល់ខ្លួន និងកំណត់នូវជម្រើសសម្រេចចិត្តផ្សេងៗ។

ដោយសង្ខេប ដូចដែលបានស្នើឡើងដំបូងដោយ Bandura (1977) ការរំពឹងទុកអំពីប្រសិទ្ធភាពដោយខ្លួនឯង សំដៅទៅលើជំនឿរបស់បុគ្គលទាក់ទងនឹងសមត្ថភាពរបស់គាត់ក្នុងការអនុវត្តកិច្ចការទទួលបានជោគជ័យ ឬអាកប្បកិរិយាដែលបានសម្តែងចេញ។ ប្រសិទ្ធភាពខ្លួនឯងទាប ការរំពឹងទុកទាក់ទងនឹងអាកប្បកិរិយា ឬដែនឥរិយាបទនាំទៅរកការជៀសវាង នៃអាកប្បកិរិយាទាំងនោះ ខណៈពេលដែលការរំពឹងទុកអំពីប្រសិទ្ធភាពខ្លួនឯងខ្លាំងជាងគួរតែនាំមុខ ដើម្បីចូលទៅជិតឥរិយាបថ។ ដូច្នេះ ការរំពឹងទុកអំពីជំនឿ

ដាក់ខ្លួនឯងអាចមានប្រយោជន៍ក្នុងការយល់ដឹង និងការទស្សន៍ទាយអាកប្បកិរិយា (Luzzo, 1996)។ សិស្ស ដែលមិនសូវមានទំនុកចិត្តលើសមត្ថភាពរបស់ពួកគេក្នុងការបំពេញភារកិច្ច ទំនងជានឹងមានការលំបាកសម្រេចបាននូវភាពជោគជ័យក្នុងកិច្ចការនោះណាស់។ នៅពេលដែលពួកគេធ្វើកិច្ចការដោយមិនមានភាពជឿជាក់លើសមត្ថភាពរបស់ខ្លួនបានពេញលេញ នោះពួកគេអាចងាយនឹងប្រឈមការបរាជ័យ (Karen M. Taylor, 1983)។ ដោយឡែក សិស្សដែលមានការសម្រេចចិត្តច្បាស់លាស់ ពួកគេអាចមានលទ្ធភាពបញ្ចប់ភារកិច្ចមួយចំនួន ដោយទទួលបាននូវបទពិសោធជីវិតល្អចេញពីសមិទ្ធផលដែលពួកគេសម្រេចបានតាមការរំពឹងទុក (Bandura, 1977)។ ការសិក្សាមួយត្រូវបានផ្តោតលើសិស្សវិទ្យាល័យនៅសហរដ្ឋអាមេរិក ដោយផ្តោតលើក្រុមសិស្សមានដើមកំណើតអាហ្វ្រិក George V. Gushue (2006) បង្ហាញថា ក្រុមសិស្សស្បែកខ្មៅទាំងនោះជារឿយៗមានបញ្ហាប្រឈមច្រើននៅពេលដែលពួកគេត្រូវបានផ្តល់ឱកាសឱ្យធ្វើការសម្រេចចិត្តទៅលើការរៀបចំផែនការអ្វីមួយ។ អ្វីដែលចោទឡើងជាបញ្ហាប្រឈមធំ សម្រាប់ពួកគេនោះគឺ ការរៀបចំផែនការអាជីពផ្ទាល់ខ្លួននេះតែម្តង។ ក្នុងក្របខណ្ឌចិញ្ចឹមបីបាច់កូនវិញ ឥទ្ធិពលនៃប្រសិទ្ធភាពលើខ្លួនឯង និងសេចក្តីប្រាថ្នារបស់មាតាបិតាលើប្រសិទ្ធភាពការងារ និងជម្រើសដែលយល់ឃើញរបស់កូនពួកគេ ត្រូវបានសម្របសម្រួលតាមរយៈការយល់ឃើញ និងសេចក្តីប្រាថ្នាចង់បានរបស់កុមារផ្ទាល់ (Albert Bandura, 2001)។ ភាពជឿជាក់លើការសិក្សា ទំនាក់ទំនងសង្គម និងការគ្រប់គ្រងខ្លួនឯងមានឥទ្ធិពលលើប្រភេទនៃសកម្មភាពការងារ ពួកគេវិនិច្ឆ័យខ្លួនឯងថាមានប្រសិទ្ធភាពទាំងដោយផ្ទាល់ និងតាមរយៈឥទ្ធិពលរបស់ពួកគេទៅលើសេចក្តីប្រាថ្នាក្នុងការសិក្សា។ ការយល់ឃើញប្រសិទ្ធភាពការងារខ្លួនឯងបានផ្តល់មូលដ្ឋានក្នុងការណែនាំដល់កុមារឱ្យពិចារណាយ៉ាងហ្មត់ចត់ លើជីវិតការងាររបស់ពួកគេ និងថ្លឹងថ្លែងនូវការងារណាដែលពេញចិត្ត ឬមិនពេញចិត្ត (Albert Bandura, 2001)។ ភាពជឿជាក់លើសមត្ថភាពខ្លួនឯង ត្រូវបានគេរកឃើញថា ជាកម្លាំងចលករមួយដ៏មានសក្តានុពលជំរុញប្រសិទ្ធភាពនៃការសម្រេចចិត្តរបស់បុគ្គលបានច្បាស់លាស់ ព្រមទាំងកំណត់នូវការប្តេជ្ញាចិត្តមុតមាំក្នុងការអនុវត្តការងារអ្វីមួយបានពេញលេញ និងទទួលបានជោគជ័យ (Lia D. Falco, 2019)។ ជំនឿជាក់លើខ្លួនឯងនេះ មានឥទ្ធិពលលើសេច

ក្តីប្រាថ្នា និងភាពខ្លាំងនៃការប្តេជ្ញាចិត្តរបស់បុគ្គលម្នាក់ ទៅលើគុណភាពនៃការវិភាគ និងការគិតជាយុទ្ធសាស្រ្ត កម្រិតនៃការលើកទឹកចិត្ត និងការតស៊ូក្នុងការប្រឈមមុខនឹងការលំបាក និងបញ្ហាប្រឈមក្នុងជីវិត (Betz, 2000; Nancy E. Betz, 1997b)។ តាមរយៈជំនឿជាក់លើខ្លួនឯងនេះ បានផ្តល់នូវប្រសិទ្ធភាពនៃការយល់ឃើញរបស់មនុស្សកាន់តែខ្ពស់ ដើម្បីបំពេញតម្រូវការអប់រំ ការងារ និងជម្រើសអាជីពដែលពួកគេបានផ្តោតការពិចារណាយ៉ាងយកចិត្តទុកដាក់ ធ្វើការសិក្សាតាមដាន និងផ្តោតការចាប់អារម្មណ៍កាន់តែខ្លាំង។ ការណ៍នេះ ជាបច្ច័យនាំឱ្យពួកគេមានលទ្ធភាពរៀបចំខ្លួនសម្រាប់ទទួលយកការអប់រំប្រកបដោយគុណភាព និងតម្រង់ទិសខ្លួនឯងទៅកាន់វិថីអាជីពការងារបានល្អប្រសើរ (Albert Bandura, 2001)។ ការសិក្សាស្រាវជ្រាវមួយដោយ Kao Sovansophal (2019) ទៅលើនិស្សិតឧត្តមសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានក្នុងប្រទេសកម្ពុជាចំនួន ១ ២៨១ នាក់ បានបង្ហាញថា នៅពេលសិស្សមានភាពជឿជាក់លើសមត្ថភាពខ្លួនឯងក្នុងមុខវិជ្ជាវិទ្យាសាស្រ្ត នោះពួកគេនឹងមាននិន្នាការទោរទន់ទៅរកការជ្រើសរើសមុខជំនាញសិក្សាកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងផ្នែកវិទ្យាសាស្រ្ត ឬស្ទែមផងដែរ។

សរុបមក កត្តាជឿជាក់លើសមត្ថភាពខ្លួនឯង បានផ្តល់មកនូវប្រសិទ្ធភាពខ្ពស់លើគ្រប់ទិដ្ឋភាពនៃការសម្រេចចិត្តរបស់បុគ្គលម្នាក់ មិនថាតែលើការអនុវត្តការងារ និងការសម្រេចចិត្តនោះទេ។ ក្នុងន័យនេះដូចបានលើកយកមកពិភាក្សាខាងលើ កត្តាជំនឿជាក់នេះ បានផ្តល់នូវឥទ្ធិពលជាវិជ្ជមានដល់ការសម្រេចចិត្តរបស់សិស្សក្នុងការជ្រើសរើសមុខជំនាញសិក្សា និងអាជីពការងាររបស់ពួកគេនាពេលអនាគតប្រាកដមែន។ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានធ្វើឡើងដើម្បីបញ្ជាក់បន្ថែមថា តើកត្តាជំនឿជាក់លើខ្លួនឯង គឺពិតជាមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា មែន ឬយ៉ាងណា?

#### ២.២.២.២.កត្តាលទ្ធផលរំពឹងទុក

ការរំពឹងទុកពីជោគជ័យ គឺជាជំនឿរបស់មនុស្សអំពីរបៀបដែលពួកគេនឹងធ្វើបានល្អលើកិច្ចការណាមួយនាពេលខាងមុខ ចំណែកឯតម្លៃនៃកិច្ចការនោះគឺសំដៅលើការលើកទឹកចិត្ត ឬហេតុផលសម្រាប់ការបំពេញកិច្ចការចំពោះមុខ (AllanWigfield, 2002)។ ការលើកឡើងពីទ្រឹស្តីជំនឿជាក់លើសមត្ថភាព

ខ្លួនឯងរបស់ Bandura (1977) បានបង្ហាញនូវធាតុផ្សំសំខាន់ៗចំនួន ២ គឺៈ ការជឿជាក់លើសមត្ថភាព និងការរំពឹងទុកលើលទ្ធផល។ ផ្អែកទ្រឹស្តីខាងលើនេះ Hackett (1981) បានផ្តល់នូវទស្សនាទានបន្ថែមក្នុងផ្នែកទី២ ការរំពឹងទុកលើលទ្ធផលថា ជាទូទៅមុននឹងបុគ្គលម្នាក់ធ្វើការសម្រេចចិត្តលើកិច្ចការអ្វីមួយ គេតែងរំពឹងគិតជាមុននូវលទ្ធផលចុងក្រោយដែលទទួលបានចេញពីការអនុវត្តកិច្ចការនោះ។

ការរំពឹងទុកលើលទ្ធផល ជាការរួមផ្សំនូវជំនឿជាក់ និងអាកប្បកិរិយាបុគ្គល ដែលត្រូវបានលេចចេញជាសកម្មភាពជាក់លាក់ផ្អែកលើការយល់ឃើញ ហើយវានឹងនាំទៅរកលទ្ធផលចុងក្រោយ (Nancy E. Betz, 1997b)។ ក្នុងអំឡុងពេលនៃដំណើរការអភិវឌ្ឍអាជីព បុគ្គលភាគច្រើនតែងបង្កើតជម្រើសការងារផ្សេងៗក្នុងក្តីស្រមៃរបស់ពួកគេ។ មនុស្សវ័យជំទង់ ចាប់ផ្តើមមានការយល់ដឹងអំពីអាជីព និងប្រភេទមុខរបរផ្សេងៗគ្នាកាន់តែមានភាពប្រាកដនិយម ប៉ុន្តែស្ថិតក្នុងស្ថានភាពស្មុគស្មាញច្រើន។ ពួកគេ បានដាក់ចេញនូវសេចក្តីប៉ងប្រាថ្នាផ្សេងៗដោយចង់ឱ្យអាជីពនេះបានផលយ៉ាងនេះ ឬយ៉ាងនោះសម្រាប់បំពេញតម្រូវការខ្លួន។ ជាមួយគ្នានេះ ការរំពឹងទុកពីលទ្ធផលទទួលបានចេញពីជម្រើសអាជីពណាមួយ ត្រូវបានសន្មតថាជាការចាប់ផ្តើមមួយមានភាពប្រាកដប្រជា (Patrick Ian Armstrong, 2000)។ ការរំពឹងទុកនូវលទ្ធផលដែលនឹងអាចកើតឡើង ត្រូវបានកំណត់ថាជាជំនឿរបស់បុគ្គលម្នាក់ នឹងត្រូវបានផ្សារភ្ជាប់ទៅនឹងលទ្ធផលដែលអាចកើតមានក្រោយការសម្រេចចិត្តក្នុងការជ្រើសរើសអាជីព (Bandura, 1989)។ Robert W. Lent (1994) យល់ថា ការរំពឹងទុកលទ្ធផល បានដើរតួនាទីដ៏សំខាន់ និងមានឥទ្ធិពលលើការអភិវឌ្ឍគោលដៅអនាគត។ គោលដៅនោះ ជាទូទៅមានធាតុផ្សំនៃជម្រើសអាជីព និងដំណើរការសម្រេចចិត្តដែលមានរួមបញ្ចូលនូវយន្តការពាក់ព័ន្ធមួយចំនួនដូចជា ការរៀបចំផែនការ ការសម្រេចចិត្ត សេចក្តីប៉ងប្រាថ្នា និងអាកប្បកិរិយា។ ជាមួយគ្នានេះ ការរំពឹងទុកលើលទ្ធផល នឹងត្រូវបានកំណត់ច្បាស់លាស់ ដើម្បីនាំទៅរកគោលដៅកាន់តែជាក់លាក់ ជាមួយនឹងការតម្រង់អាកប្បកិរិយាបុគ្គល (Nancy E. Betz, 1997b)។ ទ្រឹស្តីនៃការរំពឹងទុកលើ លទ្ធផលនេះ ត្រូវបានលើកយកមកសិក្សាក្នុងដំណាក់កាលជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅតាមតំបន់ ឬប្រទេសនានា ដើម្បីពិនិត្យមើលនូវភាពជាប់ពាក់ព័ន្ធ និងកម្រិតឥទ្ធិពលរបស់វាទៅលើការសម្រេច

ចិត្តរបស់សិស្ស (Saba Rasheed Ali, 2005)។ ប៉ុន្តែភាពជាក់ស្តែងនៃការអនុវត្តវិជ្ជាជីវៈក្នុងអាជីពណាមួយ នឹងត្រូវបានបង្ហាញនៅពេលសិស្សណាម្នាក់មានបទពិសោធផ្ទាល់ក្នុងបរិបទការងារ បន្ទាប់ពីគេផ្លាស់ប្តូរពីសាលារៀនទៅកាន់កន្លែងធ្វើការងារដ៏ពិតប្រាកដណាមួយ (David L. Blustein, 2002)។ ទោះជាយ៉ាងនេះក្តី ការរំពឹងទុកលើលទ្ធផលនេះ គឺគ្រាន់តែជាការបង្ហាញពីចំណាប់អារម្មណ៍ដែលព្យាករទុកមុនអំពីជំហានសកម្មភាព និងអ្វីដែលនឹងអាចកើតមានឡើងប៉ុណ្ណោះ (Fouad, 2007)។ មនុស្សវ័យជំទង់ មានសេចក្តីប្រាថ្នា និងផែនការទាក់ទងនឹងការអប់រំនាពេលអនាគត និងការសម្រេចបាននូវការងាររបស់ពួកគេដោយផ្អែកលើការសន្មតនូវអ្វីដែលនឹងអាចកើតមានឡើងនេះជារឿងសំខាន់។ (Monica Kirkpatrick Johnson, 2002)។ សង្គមវិទូបានទទួលស្គាល់ថា វិសាលភាពផ្លូវចិត្តរបស់មនុស្សវ័យជំទង់កាន់តែទូលំទូលាយ ប្រសិនពួកគេទទួលបានការតម្រង់ទិសបន្ថែមលើការអប់រំ ការងារ និងការរៀបចំផែនការអនាគត ដែលវាមានឥទ្ធិពលលើទិសដៅវិជ្ជាជីវៈ និងសមត្ថភាពដើម្បីទទួលបានជោគជ័យនៅក្នុងពិភពការងា (Monica Kirkpatrick Johnson, 2002)។ សកម្មភាពប្រចាំរបស់មនុស្សវ័យជំទង់ មានសក្តានុពលមានឥទ្ធិពលលើជម្រើសអាជីព និងការអភិវឌ្ឍតាមវិធីផ្សេងៗគ្នា។ តាមរយៈសកម្មភាពនៅសាលារៀន នៅផ្ទះ ឬការកម្សាន្តផ្សេងៗ វានឹងបង្កើតបានជាទម្លាប់ ផ្សារភ្ជាប់ទៅនឹងចំណាប់អារម្មណ៍ និងក្តីរំពឹងចង់បាន ដែលវារួមចំណែកក្នុងការផ្តល់គុណតម្លៃ លើកទឹកចិត្តមនុស្សវ័យជំទង់ឱ្យពិចារណាកាន់តែល្អិតល្អន់នូវអ្វីដែលគេគួរសម្រេចបាន។ (Monica Kirkpatrick Johnson, 2002)។ លើសពីនេះ ការសិក្សាស្រាវជ្រាវ ប្រើប្រាស់ការយល់ដឹងពីសង្គមនូវគំរូជម្រើសអាជីពបង្ហាញថា ការអនុវត្ត (ជាញឹកញាប់ក្នុងទម្រង់នៃចំណាត់ថ្នាក់ដែលទទួលបាន) មានឥទ្ធិពលប្រសិទ្ធភាពខ្លួនឯង (ការវិនិច្ឆ័យរបស់បុគ្គលអំពីសមត្ថភាពរបស់ពួកគេក្នុងការបំពេញភារកិច្ចដោយជោគជ័យ (Bandura, 1989) ដែលមានឥទ្ធិពលលើគោលដៅ និងជម្រើសអាជីព។

សរុបមក កត្តាលទ្ធផលរំពឹងទុក បានរួមចំណែកជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗតាមរយៈការដាក់ចេញនូវអាកប្បកិរិយា និងសកម្មភាពនៃការប្រព្រឹត្តជាប្រចាំផ្សារភ្ជាប់ទៅនឹងគោលដៅជាក់លាក់ដែលនឹងទទួលបានក្រោយពេលអនុវត្តសកម្មភាពនោះ។ ដូចបានពិភាក្សាខាងលើ កត្តាលទ្ធផល

រំពឹងទុកនេះ បានផ្តល់នូវឥទ្ធិពលជាវិជ្ជមានដល់ការសម្រេចចិត្តរបស់សិស្សក្នុងការជ្រើសរើសមុខជំនាញសិក្សា និងអាជីពការងាររបស់ពួកគេនាពេលអនាគតប្រាកដមែន។ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់បន្ថែមថា តើកត្តាលទ្ធផលរំពឹងទុក គឺពិតជាមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជាមែន ឬយ៉ាងណា?

### ២.២.២.៣. កត្តាទេពកោសល្យផ្ទាល់ខ្លួន

អាជីពនីមួយៗ មានទំនាក់ទំនងរវាងតម្រូវការរបស់អង្គភាព និងតម្រូវការរបស់បុគ្គលិក។ ទោះបីជាតម្រូវការរបស់អង្គភាពមានភាពស៊ីសង្វាក់គ្នាទៅនឹងតម្រូវការបុគ្គលិកក៏ដោយ ក៏បុគ្គលិកម្នាក់ៗមានគោលដៅជាក់លាក់ផ្ទាល់ខ្លួនមួយឆ្ពោះទៅរកអាទិភាព និងគុណតម្លៃច្បាស់លាស់ ដែលមានភាពពាក់ព័ន្ធខ្លាំងទៅនឹងទេពកោសល្យរបស់បុគ្គលម្នាក់ៗ (W. Brent Barclay, 2013)។ ទ្រឹស្តីអភិវឌ្ឍអាជីព ត្រូវបានផ្តោតជាសំខាន់លើកត្តាពីរគឺ គោលដៅការងារខាងក្រៅ និងខាងក្នុង (W. Brent Barclay, 2013)។ តម្លៃខាងក្នុងគឺជាការរីករាយដែលបុគ្គលទទួលបានពីការសម្តែងសកម្មភាព ឬចំណាប់អារម្មណ៍ដែលបុគ្គលមាននៅក្នុងជម្រើសអ្វីមួយ (Janis E. Jacobs, 2000)។ ការតម្រង់ទិសខាងក្រៅ ជាការសម្លឹងមើលអាជីពដោយការផ្តោតយកចិត្តទុកដាក់ (Bailyn, 1989)។

តាមទស្សនៈខាងលើនេះ អាជីពត្រូវបានសិក្សាក្នុងទម្រង់ជាប្រវត្តិការងារ ឬឱកាស និងឧបសគ្គដែលបុគ្គលបានឆ្លងកាត់តាមរយៈការបំពេញវិជ្ជាជីវៈណាមួយជាក់លាក់ (Hwee-Hoon Tan, 2001)។ អន្តរកម្មសង្គមរបស់និយោជិតជាមួយបុគ្គលផ្សេងទៀត នឹងក្លាយជាចំណុចសំខាន់នៃរឿងនេះ ជួយដល់ការសិក្សាស្រាវជ្រាវ។ ប្រធានបទស្រាវជ្រាវ មួយចំនួនដែលទាក់ទងនឹងការមើលឃើញខាងក្រៅ គឺជាដំណាក់កាលស្វែងយល់ពីស្ថានភាពទូទៅនៃអាជីព អ្វីដែលបុគ្គលម្នាក់ៗកំពុងអនុវត្ត និងធម្មជាតិនៃមុខរបរផ្សេងៗនៅក្នុងសង្គម (C. Brooklyn Derr, 1989)។ ទស្សនៈផ្សេងទៀត វិធីសាស្ត្រនៃការពិនិត្យមើលកត្តាខាងក្នុងរបស់បុគ្គលម្នាក់ៗមុនពេលចាប់យកអាជីព គឺជាការពិនិត្យមើលពីរបៀបដែលមនុស្សយល់ឃើញចំពោះអាជីពណាមួយនោះ ថាតើអ្វីដែលពួកគេជួបប្រទះ។ C. Brooklyn Derr (1989) បន្តលើកឡើងថា កាលណា

និយាយពីកត្តាខាងក្នុងនៃជម្រើសអាជីព គេនឹងចាប់ផ្តើមគិតដល់បញ្ហាការលើកទឹកចិត្ត សុវត្ថិភាព ការពេញចិត្ត ទិសដៅការងារឈានឆ្ពោះទៅអាជីពមួយ ដែលវាគឺជាចរិតលក្ខណៈពីធម្មជាតិនៃអាជីពនោះ។ ការពិនិត្យពីទេពកោសល្យផ្ទាល់ខ្លួនមុននឹងសម្រេចចិត្តជ្រើសរើសអាជីព គឺជាការរួមបញ្ចូលគ្នានូវផ្នែកដែលមើលឃើញពីសមត្ថភាព ការលើកទឹកចិត្ត ការជំរុញចិត្ត អាកប្បកិរិយា និងតម្លៃទាក់ទងនឹងជម្រើសការងារដែលមានជំនាញវិជ្ជាជីវៈ ប្រកបដោយស្ថិរភាពពេញលេញ (W. Brent Barclay, 2013)។ បញ្ហានេះ Schein (1980) ស្នើឱ្យមានពេលវេលាសមរម្យក្នុងការឆ្លុះបញ្ចាំងពីដំណើរអភិវឌ្ឍអាជីពរបស់បុគ្គលណាម្នាក់ តាមរយៈការដែលបុគ្គលនោះអាចពិនិត្យមើលបទពិសោធផ្ទាល់ខ្លួន ដើម្បីកំណត់ថាតើមានប្រភេទការងារ ឬអាជីពអ្វីខ្លះ ដែលពួកគេចង់ធ្វើ និងកន្លែងការងារបែបណាល្អសមរម្យបំផុតសម្រាប់ពួកគេផងដែរ។ ក្នុងវិធីនេះ បុគ្គលម្នាក់អាចនឹងមានលទ្ធភាពឈានឆ្ពោះទៅកំណត់ជម្រើសដ៏ល្អប្រកបដោយស្ថិតភាព។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំដំបូងនៃបទពិសោធការងារ បុគ្គលម្នាក់ចាប់ផ្តើមអភិវឌ្ឍគំនិតខ្លួនឯងក្នុងអាជីពដែលមានស្ថិរភាពជាងមុន អភិវឌ្ឍបន្តិចម្តងៗនូវទេពកោសល្យក្នុងអាជីពរបស់គាត់ (Schein, 1980)។ ជាផ្នែកមួយនៃទ្រឹស្តីយុថ្កាអាជីពរបស់គាត់ Schein កំណត់ទេពកោសល្យក្នុងអាជីពចំនួនប្រាំបី៖ បច្ចេកទេស/ មុខងារសមត្ថភាព, សមត្ថភាពគ្រប់គ្រងទូទៅ, ស្វ័យភាព/ឯករាជ្យ, សន្តិសុខ/ស្ថិរភាព, សហគ្រិនភាព/ភាពច្នៃប្រតិដ្ឋ សេវាកម្ម/ការលះបង់ចំពោះបុព្វហេតុ ការប្រកួតប្រជែងសុទ្ធសាធនិងរបៀបរស់នៅ (W. Brent Barclay, 2013)។ ក្នុងការសិក្សាស្រាវជ្រាវមួយរបស់ Hwee-Hoon Tan (2001) នៅប្រទេសសិង្ហបុរីបានបង្ហាញថា ដើម្បីរក្សាមនុស្សដែលមានទេពកោសល្យក្នុងវិជ្ជាជីវៈគ្រូបង្រៀន គឺទាមទារឱ្យបុគ្គលទាំងនោះមើលឃើញពីគុណសម្បត្តិខាងក្នុងនៃវិជ្ជាជីវៈនេះដោយខ្លួនគេផ្ទាល់ជាកត្តាអាទិភាព។ ការធ្វើឱ្យប្រសើរឡើងនូវគុណសម្បត្តិខាងក្រៅតាមរយៈការផ្តល់រង្វាន់បន្ថែមជាដើម គឺអាចជួយបានត្រឹមតែការបង្រៀនមួយខណៈប៉ុណ្ណោះ ប៉ុន្តែវាមិនមានស្ថិរភាពក្នុងវិជ្ជាជីវៈឡើយ ល្គឹកណាបុគ្គលខ្លួនឯងមិនមានការលើកទឹកចិត្ត អារម្មណ៍ទទួលបាននូវការគោរព គុណតម្លៃ និងកត្តាជំរុញពីខាងក្នុងខ្លួន (Lambert, 1991)។ ខាងក្នុង ការលើកទឹកចិត្តមានសារៈសំខាន់ព្រោះវាដើរតួនាទីធំជាងការលើកទឹកចិត្តពីខាងក្រៅ ក្នុងការកំណត់ការពេញចិត្ត

ការងារ (Schein, 1990)។ ការយល់ឃើញនូវគុណលក្ខណៈ ឬទេពកោសល្យសមត្ថភាពផ្ទាល់ខ្លួន វាមានភាពទាក់ទងនឹងបញ្ហាចិត្តសាស្ត្របុគ្គល ដែលបង្កើតជាគំនិតអំពីគុណភាព លក្ខណៈ តម្លៃ និងសមត្ថភាពដែលបុគ្គលសន្មតចំពោះខ្លួនគេ (Coetzee, 2016)។

សរុបមក កត្តាទេពកោសល្យផ្ទាល់ខ្លួន បានរួមចំណែកជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ តាមរយៈការពិនិត្យឆ្លុះបញ្ចាំងលើសមត្ថភាព តម្រូវការបុគ្គល និងគុណតម្លៃខាងក្នុងនិងខាងក្រៅផ្សារភ្ជាប់ទៅនឹងគោលដៅជាក់លាក់។ ដូចបានពិភាក្សាខាងលើ កត្តាទេពកោសល្យផ្ទាល់ខ្លួននេះ បានផ្តល់នូវឥទ្ធិពលជាវិជ្ជមានដល់ការសម្រេចចិត្តរបស់សិស្សក្នុងការជ្រើសរើសមុខជំនាញសិក្សា និងអាជីពការងាររបស់ពួកគេនាពេលអនាគតប្រាកដមែន។ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់បន្ថែមថា តើកត្តាទេពកោសល្យផ្ទាល់ខ្លួន គឺពិតជាមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជាមែន ឬយ៉ាងណា?

### ២.២.២.៤. កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន

អត្តសញ្ញាណបុគ្គល ជាផ្នែកមួយនៃការចង្អុលបង្ហាញឱ្យឃើញនូវស្ថិរភាព និងការអភិវឌ្ឍនៅក្នុងស្ថាប័នការងារមួយ (Dalton, 1989)។ អត្តសញ្ញាផ្ទាល់ខ្លួន ត្រូវបានផ្សារភ្ជាប់ទៅនឹងជម្រើសអាជីព ចាប់ពីអំឡុងពេលដែលបុគ្គលម្នាក់មានការគិតពិចារណាច្បាស់លាស់។ អត្តសញ្ញាណវិជ្ជាជីវៈ ត្រូវបានគេកំណត់ថាជាការប្រាកដឡើងនូវរូបភាពការងារច្បាស់លាស់ ស្ថិរភាព ផ្លូវអារម្មណ៍ និងទេពកោសល្យរបស់បុគ្គលម្នាក់ៗដែលជាមូលដ្ឋានរឹងមាំក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅលើការជ្រើសរើសអាជីព ឬមុខរបរណាមួយ (Spencer G. Niles, 2013)។

ប្រសិននិយាយក្នុងក្របខណ្ឌនៃការសិក្សាវិញ ការរកឃើញនូវអត្តសញ្ញាណ បុគ្គលផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ នឹងអាចជួយខ្លួនពួកគេឱ្យទទួលបានលទ្ធផលនៃការសិក្សាគាប់ប្រសើរ តាមរយៈស្មារតីតស៊ូពុះពារក្រេបជញ្ជក់យកចំណេះដឹងលើមុខវិជ្ជាបានច្បាស់លាស់ (Zahra Hazari, 2010)។ វាបានផ្តល់ឱ្យសិស្សនូវការយល់ដឹងពីរបៀបដែលសិស្សមើលឃើញខ្លួនឯង ទាក់ទងទៅនឹងការសិក្សាលើមុខវិជ្ជានានា

ផ្សារភ្ជាប់ទៅនឹងការដាក់ចេញនូវវិធីសាស្ត្រគាំទ្រចាំបាច់ក្នុងការរៀនមុខវិជ្ជាទាំងនោះ។ Zahra Hazari (2010) បានលើកឡើងពីភស្តុតាងដែលភ្ជាប់វិធានការទាក់ទងនឹងអត្តសញ្ញាណ ថាបានផ្តល់នូវភាពច្បាស់លាស់ដល់សិស្សក្នុងការសិក្សារៀនសូត្រ និងអនុវត្តកិច្ចផ្សេងៗដែលគ្រូបានដាក់ឱ្យ។ ការអភិវឌ្ឍចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស នៅអំឡុងពេលពួកគេត្រូវជ្រើសរើសមុខវិជ្ជាសិក្សា គឺពិតជាមានសារៈសំខាន់ណាស់។ វាទំនងជា ទំនាក់ទំនងរវាងការអភិវឌ្ឍចំណាប់អារម្មណ៍ និងជម្រើសអាជីពរបស់សិស្សត្រូវពឹងអាស្រ័យទៅលើការយល់ឃើញដោយខ្លួនឯងធៀបទៅនឹងអត្តសញ្ញាណផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ (Zahra Hazari, 2010)។ ការយល់ឃើញ និងការរំពឹងទុកដោយខ្លួនឯងអាចត្រូវបានផ្សារភ្ជាប់ទៅនឹងជម្រើសអាជីពនៅពេលក្រោយ។ ការវិភាគរបស់ Janis E. Jacobs (2000) បានបង្ហាញថា សារមាតាបិតាត្រូវបានរួមបញ្ចូលនៅក្នុងការយល់ឃើញដោយខ្លួនឯងរបស់សិស្ស និងប្រព័ន្ធខ្លួនឯង ហើយនៅទីបំផុត សារទាំងនោះមានឥទ្ធិពលលើជម្រើសនាពេលអនាគត ក៏ដូចជាថ្នាក់មហាវិទ្យាល័យជាដើម។ ការបង្កើតទំនាក់ទំនងរវាងការសម្តែង និងការយល់ឃើញដោយខ្លួនឯង Herbert W. Marsh (2002) បានរកឃើញឥទ្ធិពលទៅវិញទៅមករវាងការអនុវត្ត និងគំនិតខ្លួនឯង ដែលនោះគឺការអនុវត្តមុននេះប៉ះពាល់ដល់គំនិតខ្លួនឯងរបស់អ្នកសិក្សាហើយគំនិតខ្លួនឯងពីមុនប៉ះពាល់ដល់ការអនុវត្តនាពេលអនាគត។ ដទៃពីនេះ បញ្ហាភេទដែលកំណត់ឡើងដោយធម្មជាតិជាប់ទៅនឹងបុគ្គលម្នាក់ៗ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងជម្រើសអាជីពរបស់បុគ្គល ហើយតាមរយៈការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា អត្តសញ្ញាណនៃភេទនេះ បានដើរតួជាជម្រើសដំបូងគេ ដែលបុគ្គលត្រូវគិតពិចារណាមុននឹងសម្រេចចិត្តជ្រើសរើសអាជីពមួយ (Linda Miller, 1999; Nadya A. Fouad, 2008; Patrick Ian Armstrong, 2000)។ Linda Miller (1999) បានធ្វើការសិក្សាអំពីការប្រាថ្នាចង់បានការងាររបស់សិស្សកម្រិតមធ្យមសិក្សាបានរកឃើញថា ទាំងសិស្សប្រុស ទាំងសិស្សស្រី ប្រាថ្នាចង់បានអាជីពដែលមានលក្ខណៈឆ្លើយតបនឹងភេទ។ ការណ៍នេះបង្ហាញថាបញ្ហាយេនឌ័រក៏មានឥទ្ធិពលការយល់ឃើញរបស់បុគ្គលម្នាក់ៗ សម្រាប់ការសម្រេចចិត្តលើអាជីពការងារដែរ។ ការសិក្សារបស់ Helen S. Farmer (1995) បានបង្ហាញពី សិស្សស្រីរៀននៅកម្រិតវិទ្យាល័យមានការ

តាំងចិត្តឈោងចាប់យកអាជីពការងារកាន់តែខ្ពស់ ខណៈដែល Davey (2001) បង្ហាញលទ្ធផលស្រាវជ្រាវរបស់ខ្លួនដែរថាសិស្សប្រុសដែលរៀននៅកម្រិតវិទ្យាល័យដូចគ្នា បានផ្តោតភាពសំខាន់ក្នុងការជ្រើសរើសអាជីពទៅលើបញ្ហាផលប្រយោជន៍ទទួលបាន(Swaney, 1985)។ ចំណែក F. Heather Davey (1993) បានរាយការណ៍ថា ប្រហែលមួយភាគបីនៃសិស្សស្រីដែលកំពុងរៀនថ្នាក់ទី ១២ រំពឹងថានឹងមានមុខរបរជាលក្ខណៈប្រពៃណីដែលស្ត្រីភាគច្រើនធ្វើជាប្រចាំ ដើម្បីទទួលបានការគាំទ្រពីអ្នកដទៃ។ ក្រៅពីបញ្ហាភេទ តួនាទី និងលក្ខណៈនៃការងារក្នុងជីវិតរបស់បុគ្គលម្នាក់ៗ ត្រូវបានទទួលឥទ្ធិពលជំនឿ និងគុណតម្លៃសង្គម។ វប្បធម៌ដើមកំណើតរបស់បុគ្គល បង្ហាញពីរបៀបដែលបុគ្គលនោះបង្កើតអត្ថន័យនៅក្នុងការងាររបស់គាត់ (Fouad, 2007)។ ការជ្រើសរើសការងារ ឬមុខរបរគឺជាជម្រើសនៃរបៀបរស់នៅដែលបុគ្គលគ្រប់រូបត្រូវតែស្វែងរកក្នុងកម្រិតដ៏អស្ចារ្យតាមដែលអាចធ្វើទៅបាន (Spencer G. Niles, 2013)។ បុគ្គលិកលក្ខណៈ, ដែលរួមបញ្ចូលនូវសមត្ថភាព គុណតម្លៃ កត្តាជំរុញ ចំណូលចិត្ត និងតម្រូវការរបស់បុគ្គលម្នាក់ ត្រូវបានគេយល់ថាជាកត្តាកំណត់ដ៏សំខាន់នៃជម្រើសអាជីព (Brown, 2002; Coetzee, 2016)។ បុគ្គលម្នាក់ៗ តែងប្រើប្រាស់សមត្ថភាពយល់ដឹងរបស់ពួកគេដើម្បីពិចារណា លើជំនឿស្នូលរបស់ពួកគេអំពីសាសនា ទំនាក់ទំនង និងសារៈសំខាន់នៃការងារ (Brown, 2002)។ ជាមួយគ្នានេះគោលគំនិតនៃអាជីព គឺជាការយល់ឃើញផ្ទាល់ខ្លួន ឬគំនិតរបស់បុគ្គលណាម្នាក់ដែលកើតចេញពីបទពិសោធ ជីវិត និងអន្តរកម្មសង្គមជាក់លាក់មួយ (សង្គម-វប្បធម៌)។ ភាពចម្រុះ ជាអ្វីដែលគួរឱ្យកត់សម្គាល់នៅក្នុងវប្បធម៌នៃការរស់នៅ ជាចំណែកមួយមានឥទ្ធិពលលើជម្រើសអាជីពរបស់បុគ្គលម្នាក់ៗ (Carter, 1991; Michele J. Gelfand, 2007)។

សរុបមក កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន បានរួមចំណែកជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ តាមរយៈការពិនិត្យលើសមត្ថភាពផ្ទាល់ខ្លួន ភេទ ចំណាប់អារម្មណ៍ ការយល់ឃើញពីវប្បធម៌ជាដើម។ ដូចបានពិភាក្សាខាងលើ កត្តាអត្តសញ្ញាណផ្ទាល់ខ្លួននេះ បានផ្តល់នូវឥទ្ធិពលជាវិជ្ជមានដល់ការសម្រេចចិត្តរបស់សិស្សក្នុងការជ្រើសរើសមុខជំនាញសិក្សា និងអាជីពការងាររបស់ពួកគេនាពេលអនាគតប្រាកដមែន។ ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់បន្ថែមថាតើ កត្តាអត្តសញ្ញាណផ្ទាល់ខ្លួនគឺពិតជាមានឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជាមែន ឬយ៉ាងណា។

## ២.៣. លទ្ធផលនៃការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ

លោក David L. Blustein (2002) និង លោក Anna P. Chaves (2004) បានលើកឡើងពីលទ្ធផលស្រាវជ្រាវរបស់ខ្លួនថា យុវជនជាច្រើនបាននិងកំពុងផ្តោតការចាប់អារម្មណ៍ខ្ពស់លើគុណតម្លៃសង្គម និងកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ជាមូលដ្ឋានរួមចំណែកមួយដ៏សំខាន់ក្នុងការជ្រើសអាជីព និងការអភិវឌ្ឍអាជីព។ ដទៃពីនេះ មានការសិក្សាមួយចំពោះសិស្សវិទ្យាល័យម៉ិកស៊ិក-អាមេរិក បានបង្ហាញថា គ្រូបង្រៀន និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងសាលារៀន គឺជាចំណែកមួយមានឥទ្ធិពលជាវិជ្ជមានដល់ការកំណត់គោលដៅអាជីពរបស់ពួកគេនាថ្ងៃអនាគត (Julius Koech, 2016)។

ដោយឡែក ប្រសិនក្រឡេកទៅមើលលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់លោក Kao Sovansophal (2019) បង្ហាញថា លទ្ធភាពនៃការកំណត់គោលដៅអាជីព ឬការជ្រើសរើសមុខជំនាញសិក្សារបស់សិស្សវិទ្យាល័យនៅកម្ពុជា (ជំនាញស្ទែម) គឺមានជាប់ពាក់ព័ន្ធទៅនឹងឥទ្ធិពលនៃភាពជឿជាក់លើសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ដទៃពីនេះ ការសិក្សារបស់ Lindsay Noble Calkins (2006) និង Akpan (1986) បានរកឃើញថា ការជ្រើសរើសមុខវិជ្ជា ឬមុខជំនាញសិក្សា សម្រាប់ថ្ងៃអនាគតរបស់សិស្សកម្រិតវិទ្យាល័យ គឺទទួលរងឥទ្ធិពលពីបញ្ហាភេទ ចំណាប់អារម្មណ៍ គុណតម្លៃ សមត្ថភាព និងលទ្ធផលសិក្សា ខណៈការរកឃើញរបស់ក្រុមការងារលោក ពៅ សុគុណរិទ្ធ (២០២១) បង្ហាញពីការជះឥទ្ធិពល លើការសម្រេចចិត្តជ្រើសរើសផ្លូវសិក្សារបស់សិស្សវិទ្យាល័យនៅកម្ពុជា អាស្រ័យមួយផ្នែកលើស្ថានភាពជីវភាព គ្រួសាររបស់ពួកគេផ្ទាល់។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងពណ៌នាពីការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើរបស់ខ្លួនដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណ ដែលភ្ជាប់មកជាមួយនូវការបរិយាយពីការឌីហ្សាញការសិក្សាស្រាវជ្រាវចំនួនបីចំណុចសំខាន់រួមមាន៖ ការឌីហ្សាញភាគសំណាក ការឌីហ្សាញឧបករណ៍ស្រាវជ្រាវនិងការប្រមូលទិន្នន័យ និងការឌីហ្សាញការវិភាគទិន្នន័យ។

## ៣.១. ការឌីហ្សាញការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណ ក្នុងទម្រង់នៃការសិក្សាពីទំនាក់ទំនងអថេរ។ ជាទូទៅ ការស្រាវជ្រាវក្នុងទម្រង់សិក្សាពីទំនាក់ទំនងអថេរ ត្រូវបានធ្វើឡើងដើម្បីស្វែងរកពីទំនាក់ទំនងគ្នាក្នុងចំណោមអថេរដែលនឹងត្រូវលើកយកមកសិក្សា និងពិនិត្យមើលអំពីកម្រិតឥទ្ធិពលរបស់អថេរមួយទៅលើអថេរមួយទៀត (Creswell, 2014; Creswell, 2018)។ ដើម្បីឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវ និងសំណួរស្រាវជ្រាវដូចបានបង្ហាញជូនក្នុងជំពូកទី១ ខាងលើ អ្នកសិក្សាស្រាវបានឌីហ្សាញការសិក្សាស្រាវជ្រាវដូចខាងក្រោម៖

### ៣.១.១. លំហសំណាក និងភាគសំណាក

#### ៣.១.១.១. លំហសំណាក

លំហសំណាកដែលប្រើក្នុងការសិក្សាស្រាវជ្រាវនេះ គឺជាសិស្សដែលកំពុងសិក្សាថ្នាក់ទី១២ នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ទូទាំងប្រទេសកម្ពុជា ក្នុងឆ្នាំសិក្សា២០២១-២០២២ ចំនួន ១០៦ ៦០៨ នាក់ ស្រី ៥៨ ៤៩១ នាក់ (ក្រសួងអប់រំយុវជននិងកីឡា, ២០២២ខ)។

#### ៣.១.១.២. ភាគសំណាក

ការជ្រើសរើសសំណាកដើម្បីប្រមូលទិន្នន័យ គឺមានសារៈសំខាន់ណាស់ក្នុងការសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យ។ ជាទូទៅ ការឌីហ្សាញភាគសំណាកក្នុងការសិក្សាស្រាវជ្រាវតាមបែបបរិមាណ គឺត្រូវ

ភ្ជាប់មកជាមួយនូវគុណលក្ខណៈរបស់ភាគសំណាក ចំនួនសំណាក និងវិធីសាស្ត្រជ្រើសរើសសំណាកឱ្យបាន ច្បាស់លាស់ ដើម្បីទទួលបានភាពជាតំណាងតាមលក្ខណៈវិទ្យាសាស្ត្រ (Antonius, 2003)។

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាបានជ្រើសរើសសំណាកដើម្បីប្រមូលទិន្នន័យដោយប្រើ៖

វិធីសាស្ត្របែបពហុជំហាន (Multistage Cluster Sampling) ដើម្បីជ្រើសរើសរាជធានី ខេត្ត និងវិទ្យាល័យគោលដៅប្រមូលទិន្នន័យ និងប្រើប្រាស់វិធីសាស្ត្រ៖ អ្នកស្រាវជ្រាវបានបំបែករាជធានី ខេត្តទាំង ២៥ ក្នុងប្រទេសកម្ពុជាជា ៣ ប្រភេទរួមមាន៖ ខេត្តធំ ខេត្តមធ្យម និងខេត្តតូច ព្រមទាំងបំបែកគ្រឹះស្ថាន មធ្យមសិក្សាសាធារណៈជា ២ ប្រភេទរួមមាន៖ សាលារៀន ក្នុងទីប្រជុំជន និងសាលារៀនក្នុងជនបទ (វិទ្យាស្ថានជាតិស្ថិតិ, ២០២០)។

វិធីសាស្ត្រតាមលក្ខណៈវិនិច្ឆ័យរបស់អ្នកស្រាវជ្រាវ (Purposive Sampling) ក្នុងការជ្រើសរើស យករាជធានី ខេត្តចំនួន ៣ ចេញពីក្រុមដែលត្រូវបានបែងចែកខាងលើ តំណាងឱ្យតំបន់ ឬភូមិភាគនានា និងជ្រើសរើសយកគ្រឹះស្ថានមធ្យមសិក្សាសាធារណៈកម្រិតវិទ្យាល័យ ចំនួន ២ ចេញពីរាជធានី ខេត្ត នីមួយៗខាងលើ ដោយវិទ្យាល័យ ១ ត្រូវស្ថិតក្នុងតំបន់ប្រជុំជន និងវិទ្យាល័យ ១ ទៀតត្រូវស្ថិតក្នុងតំបន់ ជនបទ ដើម្បីឱ្យរបាយទិន្នន័យស្រាវជ្រាវទទួលបាន មានលក្ខណៈវិទ្យាសាស្ត្រ អាចគ្របដណ្តប់ និងតំណាង ឱ្យគ្របខណ្ឌទូទាំងប្រទេសកម្ពុជា។ ឈ្មោះរាជធានី ខេត្ត និងឈ្មោះវិទ្យាល័យដែលបានជ្រើសរើសជាគោលដៅ ប្រមូលទិន្នន័យ មានបង្ហាញជូនក្នុងតារាងទី១។

វិធីសាស្ត្រតាមបែបងាយស្រួល (Convenience Sampling) ដើម្បីជ្រើសរើសសិស្សចូលរួមឆ្លើយ កម្រងសំណួរប្រមូលទិន្នន័យ ដែលត្រូវបានរៀបចំទុកជាមុន។ ចំនួនភាគសំណាកដែលត្រូវបានជ្រើសរើស តាមវិទ្យាល័យនីមួយៗ មានបង្ហាញជូនក្នុងតារាងទី២។

ចំនួនសំណាកដែលនឹងត្រូវជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវនេះ ត្រូវបានកំណត់ដោយផ្អែកលើ អនុសាសន៍របស់ Joseph F. Hair (2019)។ Joseph F. Hair (2019) ពន្យល់ពីការកំណត់ ចំនួនសំណាកថា ជាធម្មតាសំណាកដែលត្រូវជ្រើសរើសដើម្បីប្រមូលទិន្នន័យ យ៉ាងហោចណាស់គួរតែមាន

ចំនួនប្រាំដងច្រើនជាងចំនួនល្បះសំណួរប្រមូលទិន្នន័យ ឬគួរតែមានយ៉ាងហោចណាស់ចំនួនដប់ដងច្រើនជាងល្បះសំណួរប្រមូលទិន្នន័យ ដើម្បីឱ្យលទ្ធផលទទួលបានកាន់តែមានភាពជាក់លាក់។

*តារាង 1 គោលដៅប្រមូលទិន្នន័យស្រាវជ្រាវ*

| ល.រ | ស្ថានភាព ប្រជាសាស្ត្រ | រាជធានី ខេត្តជ្រើសរើស | ភាពជាតំណាង តាមតំបន់ | វិទ្យាល័យ សរុប | វិទ្យាល័យត្រូវបានជ្រើសរើស | |
|---|---|---|---|---|---|---|
| | | | | | ប្រជុំជន | ជនបទ |
| ១ | ខេត្តធំ | រាជធានីភ្នំពេញ | សក្តានុពលសេដ្ឋកិច្ច | ៣៥ | វិ.ជស.បឹងកេងកង | វិ.ទួលអំពិល |
| ២ | ខេត្តធំ | កំពង់ធំ | ភូមិភាគកណ្តាល | ២៥ | វិ.កំពង់ធំ | វិ.ជស.កំពង់ថ្ម |
| ៣ | ខេត្តធំ | បាត់ដំបង | ភូមិភាគពាយ័ព្យ | ២៩ | វិ.នេតយ៉ង់ | វិ.ពេជ្រចិន្តា |
| ៤ | ខេត្តមធ្យម | ស្វាយរៀង | ភូមិភាគអាគ្នេយ៍ | ២០ | វិ.ស្វាយរៀង | វិ.បរហេស.ចន្ទ្រា |
| ៥ | ខេត្តមធ្យម | កំពង់ស្ពឺ | ភូមិភាគនិរតី | ២៤ | វិ.កំពង់ស្ពឺ | វិ.ព្រះបិតាឯកពជ្យ |
| ៦ | ខេត្តមធ្យម | កំពត | ភូមិភាគទក្សិណ | ២៣ | វិ.ចប.ព្រះរាជសម្ភារ | វិ.ហស.ឈូក |
| ៧ | ខេត្តតូច | ព្រះវិហារ | ភូមិភាគឧត្តរ | ១៨ | វិ.ជស.ត្បែងមានជ័យ | វិ.ស្រអែម |
| ៨ | ខេត្តតូច | រតនគិរី | ភូមិភាគឦសាន | ១១ | វិ.សម្តេចឪសម្តេចម៉ែ | វិ.សោមធំ |
| ៩ | ខេត្តតូច | ព្រះសីហនុ | មាត់សមុទ្ទ | ៩ | វិ.ក្រុងព្រះសីហនុ | វិ.ហស.វាលរេញ |
| | | | | សរុប | ៩ | ៩ |

ភាគសំណាកដែលបានជ្រើសរើសចេញពីវិទ្យាល័យ នៃរាជធានី ខេត្តខាងលើ ដើម្បីចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ មានចំនួនសរុប ១ ៥២០ នាក់ ស្រី ៨៨១ នាក់។ អាយុជាមធ្យមគឺ ១៧.៩៦ ឆ្នាំ (SD = ១.០១)។ ក្នុងចំណោមនោះ សិស្សដែលរៀននៅបណ្តុំថ្នាក់វិទ្យាសាស្ត្រសង្គម មានចំនួន ៦៣.១%។

### ៣.១.២. ការសាងឧបករណ៍ស្រាវជ្រាវ

ការរំលឹកទ្រឹស្តី និងបង្កើតនូវក្របខណ្ឌទស្សនាទានខាងលើ ជាមូលដ្ឋានដ៏សំខាន់សម្រាប់អ្នកស្រាវជ្រាវ មានលទ្ធភាពឈានឆ្ពោះទៅរកការសាងឧបករណ៍ប្រមូលទិន្នន័យ ឆ្លើយតបទៅនឹងគោលបំណង និង

សំណួរស្រាវជ្រាវនៃប្រធានបទនេះ។ កម្រងសំណួរប្រមូលទិន្នន័យ ដែលបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ ត្រូវបានបង្កើតឡើងដោយចែកចេញជា បីផ្នែកធំៗ៖ ផ្នែកទី១ ព័ត៌មានប្រជាសាស្ត្រ ផ្នែកទី២ កត្តាជះឥទ្ធិពលលើជម្រើសអាជីព និងផ្នែកទី៣ ជម្រើសមុខជំនាញសិក្សានៅកម្រិតឧត្តមសិក្សា។

### ៣.១.២.១. កម្រងសំណួរផ្នែកទី១

កម្រងសំណួរពាក់ព័ន្ធព័ត៌មានប្រជាសាស្ត្ររបស់សំណាក ត្រូវបានបង្កើតឡើងក្នុងទម្រង់ជាសំណួរបិទពហុជ្រើសរើសចំនួន ៦ ល្បះសំណួរ ដើម្បីកំណត់អំពី៖ ភេទ អាយុ អាគតដ្ឋានវិទ្យាល័យ ប្រភេទថ្នាក់រៀន (ថ្នាក់វិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម) ទីលំនៅបច្ចុប្បន្ន (រាជធានី ខេត្ត) មុខរបរឪពុកម្តាយ ឬអ្នកអាណាព្យាបាល។

### ៣.១.២.២. កម្រងសំណួរផ្នែកទី២

កម្រងសំណួរពាក់ព័ន្ធកត្តាជះឥទ្ធិពលលើជម្រើសអាជីព ត្រូវបានសាងឡើងក្នុងទម្រង់សំណួរបិទពហុជ្រើសរើសចំនួន ៨០ ល្បះសំណួរ (Items) ដែលរំលេចចេញពីក្របខណ្ឌទស្សនាទាន និងការរំលឹកទ្រឹស្តីក្នុងជំពូកទី២ ខាងលើ។ សិស្សដែលត្រូវចូលរួមបំពេញកម្រងសំណួរក្នុងការសិក្សាស្រាវជ្រាវនេះ ត្រូវអានល្បះ នីមួយៗរួចពិចារណាជ្រើសរើសយកកម្រិតចង្អុលបង្ហាញ (Likert Scale) ណាមួយក្នុងចំណោមកម្រិតចង្អុលបង្ហាញចំនួន ៥ កម្រិត ដែលសមស្របទៅនឹងការគិតរបស់ពួកគេ។ កម្រិតចង្អុលបង្ហាញទាំង ៥ កម្រិត មានដូចជា៖ ១.មិនយល់ស្របសោះ ២.មិនយល់ស្រប ៣.មិនប្រាកដ ៤.យល់ស្រប ៥.យល់ស្របទាំងស្រុង។

**ចរិតលក្ខណៈនៃកម្រងសំណួរប្រមូលទិន្នន័យ៖** កត្តាខាងក្រៅ ចំនួន ៣៨ ល្បះសំណួរ

**កត្តាគ្រួសារ** ត្រូវបានសាងឡើងចំនួន ១០ ល្បះសំណួរ ផ្តោតលើ៖ ការគាំទ្រផ្លូវអារម្មណ៍ ការរំពឹងទុករបស់គ្រួសារ ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការគាំទ្រផ្នែកព័ត៌មាន និងការផ្តល់ភាពជាគំរូ។ ឧទាហរណ៍៖ *ក្រុមគ្រួសារ តែងលើកទឹកចិត្តខ្ញុំឱ្យខិតខំសិក្សារៀនសូត្រ ដើម្បីទទួលបានការងារល្អ, ក្រុមគ្រួសារខ្ញុំ រំពឹងថាអាជីពដែលខ្ញុំជ្រើសរើសនាពេលអនាគត នឹងឆ្លើយតបនឹងបំណងប្រាថ្នារបស់ពួកគាត់,...។*

**កត្តាសាលារៀន** ត្រូវបានសាងឡើងចំនួន ១២ ឈ្មោះសំណួរ ផ្តោតលើ៖ ការគាំទ្ររបស់គ្រូបង្រៀន ការគាំទ្ររបស់មិត្តភក្តិ លទ្ធផលសិក្សា ការទទួលសេវាប្រឹក្សាអាជីព ការគាំទ្រផ្នែកសម្ភារៈរៀននិងបង្រៀន និងការផ្តល់ភាពជាគំរូ។ ឧទាហរណ៍៖ *មុននឹងសម្រេចចិត្តជ្រើសរើសអាជីព ខ្ញុំតែងពិភាក្សាគ្នា និងទទួលយកយោបល់ពី លោកគ្រូអ្នកគ្រូដែលជិតស្និទ្ធ, លោកគ្រូអ្នកគ្រូខ្ញុំ បានផ្តល់នូវភាពជាគំរូដ៏ល្អសម្រាប់ការជ្រើសរើសអាជីពរបស់ខ្ញុំ,...*។

**កត្តាព័ត៌មានទីផ្សារការងារ** ត្រូវបានសាងឡើងចំនួន ១០ ឈ្មោះសំណួរ ផ្តោតលើ៖ ទីកន្លែងបំពេញការងារ តំណែងតួនាទី ប្រាក់កម្រៃនិងអត្ថប្រយោជន៍ លក្ខខណ្ឌការងារ និងលទ្ធភាពទទួលបានការងារ។ ឧទាហរណ៍៖ *ខ្ញុំចង់បានការងារធ្វើនៅទីប្រជុំជន រាជធានី ឬតំបន់សេដ្ឋកិច្ចពិសេស, ខ្ញុំនឹងជ្រើសរើសអាជីពណាដែលផ្តល់ប្រាក់ខែ និងមានអត្ថប្រយោជន៍ខ្ពស់,...*។

**កត្តាសង្គម-សេដ្ឋកិច្ច** ត្រូវបានសាងឡើងចំនួន ៦ ឈ្មោះសំណួរ ផ្តោតលើ៖ ឋានៈសង្គម ស្ថានភាពវិវត្តផ្នែកសេដ្ឋកិច្ច និងការទទួលស្គាល់របស់សង្គម។ ឧទាហរណ៍៖ *អាជីពដែលខ្ញុំជ្រើសរើសនាពេលអនាគតនឹងផ្តល់ឱ្យខ្ញុំនូវកិត្តិយសថ្លៃថ្នូក្នុងសង្គម, ការជ្រើសរើសអាជីពរបស់ខ្ញុំ គឺអាស្រ័យលើស្ថានភាពរីកដុះដាលផ្នែកសេដ្ឋកិច្ច និងតម្រូវការជាក់ស្តែងរបស់សង្គម,...*។

**ចរិតលក្ខណៈនៃកម្រងសំណួរប្រមូលទិន្នន័យ៖** កត្តាខាងក្នុង ចំនួន ៤២ ឈ្មោះសំណួរ

**ភាពជឿជាក់លើខ្លួនឯង** ត្រូវបានសាងឡើងចំនួន ១០ ឈ្មោះសំណួរ ផ្តោតលើ៖ ការជ្រើសរើសគោលដៅ ព័ត៌មានអំពីមុខរបរ ការរៀបចំផែនការ ការស្វ័យវាយតម្លៃផ្ទាល់ខ្លួន និងការដោះស្រាយបញ្ហា។ ឧទាហរណ៍៖ *ខ្ញុំនឹងស្វែងរកព័ត៌មានបន្ថែមដើម្បីកំណត់ថា តើមុខជំនាញដែលខ្ញុំនឹងរៀន ឆ្លើយតបទៅនឹងគោលដៅអាជីពដែលខ្ញុំនឹងជ្រើសរើសឬយ៉ាងណា, ខ្ញុំរៀបចំផែនការផ្ទាល់ខ្លួនសម្រាប់ការជ្រើសរើសអាជីពរបស់ខ្ញុំ,...*។

**លទ្ធផលរំពឹងទុក** ត្រូវបានសាងឡើងចំនួន ១០ ឈ្មោះសំណួរ ផ្តោតលើ៖ ឥរិយាបថនៃការទទួលបានការអប់រំ និងឥរិយាបថនៃការជ្រើសរើសអាជីព។ ឧទាហរណ៍៖ *ប្រសិនខ្ញុំទទួលបានចំណាត់ថ្នាក់ល្អ*

*ខ្ញុំនឹងមានលទ្ធភាពជ្រើសរើសអាជីពសមរម្យ, ប្រសិនខ្ញុំសិក្សាស្រាវជ្រាវឱ្យបានច្រើនពីអាជីពការងារផ្សេងៗ ខ្ញុំនឹងមានលទ្ធភាពសម្រេចចិត្តជ្រើសរើសអាជីពការងារ ផ្ទាល់ខ្លួនបានកាន់តែល្អប្រសើរ,...។*

**ទេពកោសល្យផ្ទាល់ខ្លួន** ត្រូវបានសាងឡើងចំនួន ១០ ល្បះសំណួរ ផ្តោតលើ៖ ផ្អែកលើទេពកោសល្យ ផ្អែកលើតម្រូវការផ្ទាល់ខ្លួន និងផ្អែកលើគុណតម្លៃ។ ឧទាហរណ៍៖ *ខ្ញុំជាមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ ការកែតម្រូវកំហុសឆ្គង និងការធ្វើការប្រកបដោយផលិតភាព, ខ្ញុំមានតម្រូវការផ្អែកសេរីភាពផ្ទាល់ខ្លួនក្នុងការបំពេញការងារ,...។*

**អត្តសញ្ញាណផ្ទាល់ខ្លួន** ត្រូវបានសាងឡើងចំនួន ១២ ល្បះសំណួរ ផ្តោតលើ៖ ចំណាប់អារម្មណ៍ ការទទួលស្គាល់ ការអនុវត្ត សមត្ថភាព ភេទ និងការយល់ឃើញ។ ឧទាហរណ៍៖ *ខ្ញុំបានធ្វើបញ្ជីរាយមុខជំនាញ និងអាជីពទាំងឡាយដែលខ្ញុំចាប់អារម្មណ៍, ខ្ញុំអាចទទួលយក និងធ្វើការងារជាមួយអ្នកដែលមានការអប់រំខុសគ្នា វប្បធម៌នៃការរស់នៅខុសគ្នា,...។*

### ៣.១.២.៣. កម្រងសំណួរផ្នែកទី៣

កម្រងសំណួរពាក់ព័ន្ធព័ត៌មាននឹងមុខជំនាញសិក្សា ដែលសិស្សគ្រោងនឹងជ្រើសរើសសិក្សានៅកម្រិតឧត្តមសិក្សា បន្ទាប់ពីពួកគេបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិភូមិ។ ខ្លឹមសារនៃកម្រងសំណួរនេះត្រូវបានរៀបចំឡើងក្នុងលក្ខណៈជាបណ្តុំមុខជំនាញ តាមគំរូដែលមានស្រាប់របស់ ក្រសួងអប់រំយុវជននិងកីឡា (២០២២a) ចំនួន ១ ល្បះសំណួរ ដើម្បីឱ្យសិស្សគូសជីកជ្រើសរើសយកបណ្តុំមុខជំនាញណាមួយដែលគេគ្រោងនឹងបន្តការសិក្សានាពេលអនាគត ជាអាទិ៍៖ ធុរកិច្ច សុខាភិបាល កសិកម្ម វិស្វកម្ម វិទ្យាសាស្ត្រមូលដ្ឋាន វិទ្យាសាស្ត្រ សង្គមនិងសិល្បៈ បច្ចេកវិទ្យាព័ត៌មានវិទ្យា ភាសាបរទេស ច្បាប់និងកិច្ចការយុត្តិធម៌ និងទេសចរណ៍និងបដិសណ្ឋារកិច្ច។

ឧបករណ៍ប្រមូលទិន្នន័យនេះ ត្រូវបានរៀបចំឡើង និងបញ្ចូលក្នុងប្រព័ន្ធ Google Form ដើម្បីប្រើប្រាស់ក្នុងការប្រមូលទិន្នន័យស្រាវជ្រាវ។ តំណលីងចូលទៅកាន់កម្រងសំណួរប្រមូលទិន្នន័យ មានភ្ជាប់ជូន https://forms.gle/KSjgh8HzKgVi5NUK9 ។

### ៣.១.២.៤. ការត្រួតពិនិត្យគុណភាពឧបករណ៍ស្រាវជ្រាវ

### ក.ការពិនិត្យលើសុពលភាពខ្លឹមសារឧបករណ៍

បន្ទាប់ពីរៀបចំសាងឧបករណ៍ប្រមូលទិន្នន័យរួចរាល់ អ្នកសិក្សាស្រាវជ្រាវបានដាក់ឧបករណ៍នោះជូនគ្រូដឹកនាំបង្គោល និងដឹកនាំរង ពិនិត្យផ្តល់យោបល់លើខ្លឹមសារ ពាក្យពេចន៍ ល្បះសំណួរទាំងអស់។ លោកបណ្ឌិតទាំងពីរ បានផ្តល់យោបល់កែសម្រួលខ្លឹមសារឧបករណ៍ស្រាវជ្រាវដោយអន្លើ និងបានឯកភាពជារួមអនុញ្ញាតឱ្យអ្នកស្រាវជ្រាវយកទៅប្រើប្រាស់ប្រមូលទិន្នន័យ។

### ខ.ការពិនិត្យលើកម្រិតភាពជឿជាក់របស់ឧបករណ៍

Antonius (2003) និង Creswell (2014) បានផ្តល់អនុសាសន៍ថា ជាធម្មតាក្នុងការប្រមូលទិន្នន័យសាកល្បង ត្រូវធ្វើឡើងលើក្រុមសំណាកស្ថិតក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងសំណាកផ្លូវការ ដែលមានចំនួនយ៉ាងតិចចាប់ពី ៣០ នាក់ឡើង ដើម្បីពិនិត្យកម្រិតភាពជឿជាក់របស់ឧបករណ៍ប្រមូលទិន្នន័យ (Cronbach's alpha)។ យោងអនុសាសន៍នេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរប្រមូលទិន្នន័យដែលបានសាងឡើង ក្រោមការឆ្លងយោបល់ពិភាក្សាល្អិតល្អន់ជាមួយគ្រូដឹកនាំ គ្រូដឹកនាំរង ធ្វើការប្រមូលទិន្នន័យសាកល្បងជំហានដំបូងដោយប្រើប្រាស់ប្រព័ន្ធ Google Form ទៅលើក្រុមសំណាកជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យហ៊ុនសែនស្គន់ ខេត្តកំពង់ចាម ចំនួន ៤០ នាក់ ស្រី ២៨ នាក់។ លទ្ធផលនៃការវិភាគកម្រិតភាពជឿជាក់របស់ឧបករណ៍ប្រមូលទិន្នន័យបង្ហាញថា Cronbach's alpha ស្មើនឹង ០.៩៧ ខណៈដែល Cronbach's alpha based on standardized items ស្មើនឹង ០.៩៨។ តាមរយៈលទ្ធផលនេះ បង្ហាញពីកម្រិតភាពជឿជាក់របស់ឧបករណ៍ស្រាវជ្រាវនេះ អាចយកទៅប្រើប្រាស់ ប្រមូលទិន្នន័យផ្លូវការបាន។ បណ្តុំអថេរទាំងអស់ ដែលមានក្នុងការសិក្សាស្រាវជ្រាវនេះមានចំនួន ៨ ដូចជា *(១)* កត្តាគ្រួសារ *(២)* កត្តាសាលារៀន *(៣)* កត្តាព័ត៌មានទីផ្សារការងារ *(៤)* កត្តាសង្គម-សេដ្ឋកិច្ច *(៥)* កត្តាភាពជឿជាក់លើខ្លួនឯង *(៦)* កត្តាលទ្ធផលរំពឹងទុក *(៧)* កត្តាទេពកោសល្យផ្ទាល់ខ្លួន និង *(៨)* កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន។ លទ្ធផល Cronbach's alpha ទទួលបានលើបណ្តុំអថេរទាំង ៨ ខាងលើ ក្រោយពេលប្រមូលទិន្នន័យផ្លូវការ មានបង្ហាញក្នុងតារាងខាងក្រោម៖

*តារាង 2 កម្រិតនៃភាពជឿជាក់របស់ឧបករណ៍ប្រមូលទិន្នន័យ*

| **បណ្ដុំនៃអថេរ** | Cronbach's alpha |
|---|---|
| ១. កត្តាគ្រួសារ | ០.៨៣ |
| ២. កត្តាសាលារៀន | ០.៩០ |
| ៣. កត្តាព័ត៌មានទីផ្សារការងារ | ០.៨៤ |
| ៤. កត្តាសង្គម-សេដ្ឋកិច្ច | ០.៨៥ |
| ៥. កត្តាភាពជឿជាក់លើខ្លួនឯង | ០.៨៨ |
| ៦. កត្តាលទ្ធផលរំពឹងទុក | ០.៩០ |
| ៧. កត្តាទេពកោសល្យផ្ទាល់ខ្លួន | ០.៩០ |
| ៨. កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន | ០.៨៨ |
| **សរុបរួម** | **០.៩៧** |

### ៣.១.៣. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺជាសមាសធាតុសំខាន់មិនអាចខ្វះបាន នៅក្នុងការសិក្សាស្រាវជ្រាវតាមបែបបរិមាណ។ លោក Antonius (2003) លើកឡើងថា ក្នុងការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ ប្រសិនទិន្នន័យយកមកប្រើ មិនត្រូវបានប្រមូលឱ្យបានហ្មត់ចត់ច្បាស់លាស់ទេនោះ វាក៏មិនអាចផ្ដល់មូលដ្ឋានវិភាគបានត្រឹមត្រូវឆ្លើយតបទៅនឹងវិធីវិទ្យាសាស្ត្របានដែរ។ លោកបន្តថា វិធីជាក់លាក់នៃការប្រមូលទិន្នន័យ នឹងទទួលទិន្នន័យល្អដើម្បីប្រើប្រាស់ (Antonius, 2003)។

ក្រសួងអប់រំ យុវជន និងកីឡា បានចេញលិខិតលេខ ២៣៤១ អយក.វជអ ចុះថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ និងលិខិតឧទ្ទេសនាម លេខ ២៤៦៦ អយក.ឧទន ចុះថ្ងៃ សុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ជាការជូនព័ត៌មានដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ផ្ដល់កិច្ច

សហការដល់ក្រុមនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៃវិទ្យាស្ថានជាតិអប់រំ មានលទ្ធភាពចុះប្រមូលទិន្នន័យតាមគោលដៅរបស់ខ្លួន។ ក្នុងន័យនេះ ក្រោយពីបានជ្រើសរើសគោលដៅ និងក្រុមភាគសំណាកបម្រើឱ្យការប្រមូលទិន្នន័យរួចមក អ្នកសិក្សាស្រាវជ្រាវបានទាក់ទងជូនព័ត៌មានដល់មន្ទីរអប់រំ យុវជន និងកីឡា ដើម្បីគោរពស្នើសុំកិច្ចសហការប្រមូលទិន្នន័យនៅតាមគោលដៅដែលបានកំណត់ទុក។

យន្តការដាក់ស្តែងនៃការប្រមូលទិន្នន័យនេះ ត្រូវបានធ្វើឡើងក្នុងរូបភាព ២ យ៉ាង៖ ការចុះប្រមូលដោយអ្នកស្រាវជ្រាវផ្ទាល់ (នៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ ខេត្តព្រះសីហនុ និងខេត្តកំពត) និងការប្រមូលទិន្នន័យតាមរយៈអន្តរការី (នៅខេត្តបាត់ដំបង ខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង ខេត្តព្រះវិហារ និងខេត្តរតនគិរី)។ ចំពោះការប្រមូលទិន្នន័យតាមរយៈអន្តរការី អ្នកសិក្សាស្រាវជ្រាវបានទាក់ទងទៅកាន់គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ នៃវិទ្យាល័យគោលដៅ ដោយការខលទូរសព្ទ និងប្រព័ន្ធទាក់ទងតេលេក្រាម ដើម្បីស្នើគាត់ឱ្យជួយសម្របសម្រួលប្រមូលទិន្នន័យជំនួស។ មុននឹងផ្តល់តំណលីងឱ្យគាត់ជួយប្រមូលទិន្នន័យពីសិស្ស អ្នកសិក្សាស្រាវជ្រាវ បានផ្ញើតំណលីងកម្រងសំណួរប្រមូលទិន្នន័យជូនគាត់ពិនិត្យ។ បន្ទាប់មក អ្នកសិក្សាស្រាវជ្រាវបានជួបលោកគ្រូអ្នកគ្រូជាអន្តរការី តាមខ្សែទូរសព្ទដើម្បីពន្យល់បំភ្លឺចំណុចទាំងឡាយដែលគាត់នៅមានមន្ទិល មុននឹងគាត់ចាត់ចែងផ្តល់តំណលីងកម្រងសំណួរប្រមូលទិន្នន័យដល់សិស្សថ្នាក់ទី១២។

ការប្រមូលទិន្នន័យផ្លូវការសម្រាប់ការសិក្សាស្រាវជ្រាវនេះ ត្រូវបានចាប់ផ្តើមនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។

### ៣.១.៤. ការវិភាគទិន្នន័យ

មុននឹងឈានដល់ការវិភាគលទ្ធផលស្រាវជ្រាវ ទិន្នន័យដែលប្រមូលបានតាមរយៈទម្រង់ Google Form ត្រូវបានទាញបញ្ចូលក្នុងកម្មវិធី Microsoft Excel 2013 ដើម្បីសម្អាតទិន្នន័យជំហានដំបូង និងកែក្បាលតារាងឱ្យត្រូវគ្នាទៅនឹងទម្រង់កម្មវិធីវិភាគដែលត្រូវបានរៀបចំទុកជាមុន។ បន្ទាប់មក អ្នកសិក្សាស្រាវជ្រាវ បានទាញទិន្នន័យទាំងអស់ដែលប្រមូលបានពីក្នុងទម្រង់ Ms.Excel ទៅក្នុងកម្មវិធីវិភាគស្ថិតិ និងធ្វើការវិភាគរកលទ្ធផលផ្អែកលើសំណួរស្រាវជ្រាវ និងតម្រូវការដាក់ស្តែង។

ទិន្នន័យដែលទទួលបាន នឹងត្រូវប្រើប្រាស់ការវិភាគតាមវិធីស្ថិតិច្បាស់លាស់ ដើម្បីទាញបានតម្លៃសន្និដ្ឋានមួយជាក់លាក់ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ។ ក្នុងការឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី១ ស្នេរនិក្ខេបបទ បានប្រើប្រាស់កម្មវិធីវិភាគស្ថិតិ៖ ស្ថិតិពណ៌នា (Descriptive Statistics) ដើម្បីរកតម្លៃមធ្យមភាគរយ និងគម្លាតស្តង់ដា។ បន្ថែមលើនេះ ក្នុងការឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី២ ស្នេរនិក្ខេបបទ បានប្រើប្រាស់ស្ថិតិសន្និដ្ឋាន (Inferential Statistics)៖ T-Test និង One-Way-Anova មកវិភាគសិក្សាប្រៀបធៀបពីភាពប្រែប្រួលផ្នែកស្ថិតិរវាងក្រុមអថេរ។

## ៣.២. ដំណើរការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងតាមជំហាននីមួយៗជាក់លាក់ ដើម្បីឆ្លើយតបទៅគោលបំណងស្រាវជ្រាវ និងសំណួរស្រាវជ្រាវដូចបានកំណត់ក្នុងជំពូកទី១។ ខាងក្រោមនេះ ជាតារាងបង្ហាញពីយន្តការនៃការសិក្សាស្រាវជ្រាវតាមជំហានច្បាស់លាស់។

*តារាង 3 ដំណើរការសិក្សាស្រាវជ្រាវ*

| គោលបំណង | ដំណើរការស្រាវជ្រាវ | ការឌីហ្សាញការស្រាវជ្រាវ | | | លទ្ធផល |
|---|---|---|---|---|---|
| | | សំណាក/ ប្រភពព័ត៌មាន | ឧបករណ៍ ប្រមូលទិន្នន័យ | ការវិភាគ ទិន្នន័យ | |
| ១. ស្វែងរកកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ | ១.ជំហានទី១៖ សិក្សាពីទ្រឹស្តី ទស្សនាទានសំខាន់ៗ ក្របខណ្ឌគំនិត បញ្ញត្តិផ្សេងៗ និងលទ្ធផលដែលអ្នកស្រាវជ្រាវមុនៗបានរកឃើញ ដែលមានភាពពាក់ព័ន្ធទៅនឹងខ្លឹមសារប្រធានបទស្រាវជ្រាវ។ | | | | |
| | ១.១ សិក្សាពីគោលគំនិតទ្រឹស្តីនិងការសិក្សាមុនៗដែលពាក់ព័ន្ធទៅនឹងកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ | គោលគំនិត ទ្រឹស្តី និងការសិក្សាមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទ | រៀបចំតារាងសំយោគគំនិត | ការវិភាគលើសមាសភាគពាក់ព័ន្ធ | ១.១ សេចក្តីព្រាងក្របខណ្ឌទស្សនាទានដែលនឹងត្រូវសិក្សា ជុំវិញកត្តាជះឥទ្ធិពលលើជម្រើស |

| | | | | | |
|---|---|---|---|---|---|
| | ១.២ សំយោគក្របខណ្ឌទស្សនាទានដែលមាន | - | តារាងវិភាគខាងលើ | វិភាគ និងសំយោគខ្លឹមសារ | អាជីពរបស់សិស្សវិទ្យាល័យ |
| | ១.៣ វាយតម្លៃ និងពិនិត្យស៊ីជម្រៅលើក្របខណ្ឌទស្សនាទានដែលនឹងត្រូវលើមកធ្វើការសិក្សា | វិភាគពីជាតុផ្សំនៃកត្តាជះឥទ្ធិពលនីមួយៗ | រៀបចំតារាងសំយោគគំនិតឡើងវិញ | ការវិភាគលើសមាសភាគសំខាន់ៗ | ១.២ ទទួលបានក្របខណ្ឌទស្សនាទាន ដែលនឹងត្រូវសិក្សាអំពីកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ |
| | ១.៤ ការសាងឧបករណ៍ប្រមូលទិន្នន័យ | ប្រមូលទិន្នន័យសាកល្បងពីសិស្សចំនួន ៤០ នាក់ | កម្រងសំណួរដែលត្រូវបានរៀបចំរួច | វិភាគមើលគុណភាពឧបករណ៍ | ១.៤ ទទួលបានឧបករណ៍ប្រមូលទិន្នន័យ |
| | ១.៥ សិក្សាពីកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ | វិទ្យាល័យ ១៨ នៃ ៩ រាជធានីខេត្ត សិស្សថ្នាក់ទី១២ ចំនួន ១ ៥២០ នាក់ | កម្រងសំណួរប្រមូលទិន្នន័យដែលត្រូវបានរៀបចំឡើងជាបីផ្នែកធំៗ | -សិក្សាពីតម្លៃមធ្យម គម្លាតស្តង់ដា និងភាគរយ របស់កត្តានីមួយៗ<br>-វិភាគពីកត្តាជះឥទ្ធិពលទៅលើជម្រើសអាជីពសិស្ស | ១.៥ ទទួលបានលទ្ធផលនៃកត្តាជះឥទ្ធិពលនីមួយៗលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ |

| | | | | | |
|---|---|---|---|---|---|
| ២. សិក្សាពីកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជាធៀបទៅនឹងភេទ និងប្រភេទមុខរបររបស់ឪពុកម្តាយសិស្ស? | ២.ជំហានទី២៖ សិក្សាប្រៀបធៀបរវាងកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ទៅនឹងភេទ និងប្រភេទមុខរបរឪពុកម្តាយសិស្ស | | | | |
| | ២.១ សិក្សាកត្តាជះឥទ្ធិពលលើជម្រើសអាជីពធៀបទៅនឹងភេទ និងប្រភេទមុខរបរឪពុកម្តាយ | សិស្សថ្នាក់ទី១២ ចំនួន ១ ៥២០ នាក់ | កម្រងសំណួរប្រមូលទិន្នន័យ | សិក្សាពីភាពខុសគ្នាដោយប្រើ Inferential Statistics | ២.១ ទទួលបានលទ្ធផលនៃភាពខុសគ្នា ឬមិនខុសគ្នានៃកត្តាជះឥទ្ធិពលនីមួយៗ ទៅនឹងភេទ និងប្រភេទមុខរបរឪពុកម្តាយ |

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

ក្នុងជំពូកនេះ អ្នកសិក្សានឹងធ្វើការបកស្រាយបង្ហាញនូវលទ្ធផលស្រាវជ្រាវរបស់ខ្លួន ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់ក្នុងជំពូកទី១ខាងលើ។ បន្ថែមលើនេះ អ្នកស្រាវជ្រាវក៏ត្រូវធ្វើការពិភាក្សាអំពីស្ថានភាពពាក់ព័ន្ធជុំវិញលទ្ធផលដែលបានរកឃើញ ធៀបទៅនឹង ទ្រឹស្តីដែលបានរៀបរាប់ក្នុងជំពូកទី២។

## ៤.១. ការវិភាគទិន្នន័យប្រជាសាស្ត្រ

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានកំណត់យកវិទ្យាល័យចំនួន ១៨ ចេញពីរាជធានី ខេត្តចំនួន ៩ ចំណោមរាជធានី ខេត្តទាំង២៥ ក្នុងប្រទេសកម្ពុជា ដើម្បីធ្វើជាតំណាងឱ្យលទ្ធផលស្រាវជ្រាវក្នុងក្របខណ្ឌទូទាំងប្រទេស។ អ្នកសិក្សាស្រាវជ្រាវ បានប្រមូលទិន្នន័យពីក្រុមភាគសំណាកជាសិស្សកំពុងសិក្សាថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា២០២១-២០២២ នៃវិទ្យាល័យទាំងអស់ខាងលើនេះ សរុបចំនួន ១ ៥២០ នាក់ ស្រី ៨៨១ នាក់។ ក្នុងចំណោមនេះ សិស្សដែលចូលរួមឆ្លើយកម្រងសំណួរប្រមូលទិន្នន័យទាំងអស់ស្ថិតក្នុងក្រុមអាយុ ១៦ ឆ្នាំ មានចំនួន ៦៦ នាក់ ស្មើនឹង ៤.៣% ក្រុមអាយុ ១៧ ឆ្នាំ មានចំនួន ៤៥៤ នាក់ ស្មើនឹង ២៩.៩% ក្រុមអាយុ ១៨ ឆ្នាំ មានចំនួន ៦២៣ នាក់ ស្មើនឹង ៤១% ក្រុមអាយុ ១៩ ឆ្នាំ មានចំនួន ២១៨ នាក់ ស្មើនឹង ១៤.៣% និងក្រុមអាយុ ២០ ឆ្នាំ មានចំនួន ១៥៩ នាក់ ស្មើនឹង ១០.៥%។

របាយទិន្នន័យប្រជាសាស្ត្រដដែលនេះ ក៏បានបង្ហាញសិស្សថ្នាក់ទី១២ ដែលកំពុងរៀននៅក្នុងបណ្តុំថ្នាក់វិទ្យាសាស្ត្រមានចំនួន ៥៦១ នាក់ ស្មើនឹង ៣៦.៩% និងសិស្សនៅបណ្តុំថ្នាក់វិទ្យាសាស្ត្រសង្គមមានចំនួន ៩៥៩ នាក់ ស្មើនឹង ៦៣.១%។ ជាមួយគ្នានេះ ទិន្នន័យដែលប្រមូលក្នុងកម្រងសំណួរផ្នែកទី៣ បង្ហាញថាក្នុងចំណោមសិស្សសរុប ១ ៥២០ នាក់ ពួកគេបានដាក់គោលដៅជ្រើសរើសមុខជំនាញបន្តការសិក្សានៅកម្រិតឧត្តមសិក្សា លើបណ្តុំមុខជំនាញវិទ្យាសាស្ត្រ សរុបមានចំនួន ៤០.៣% (សុខាភិបាល ១១.៤% កសិកម្ម ៦.២% វិស្វកម្ម ១០% វិទ្យាសាស្ត្រមូលដ្ឋាន ៥.៩% និងបច្ចេកវិទ្យាព័ត៌មានវិទ្យា ៦.៨%) ខណៈ

សិស្សចង់បន្តការសិក្សាលើបណ្តុំមុខជំនាញវិទ្យាសាស្ត្រសង្គម សរុបមានចំនួន ៥៩.៧% (ធុរកិច្ច ២១% វិទ្យាសាស្ត្រសង្គមនិងសិល្បៈ ១២.៤% ភាសាបរទេស ៤.១% ច្បាប់និងកិច្ចការយុត្តិធម៌ ១៨.៨% និង ទេសចរណ៍និងបដិសណ្ឋារកិច្ច ៣.៤%)។

## ៤.២. ការវិភាគលើសំណួរស្រាវជ្រាវ

### ៤.២.១. សំណួរស្រាវជ្រាវទី១៖ កត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា

ការរំលឹកទ្រឹស្តីក្នុងជំពូកទី២ បានបង្ហាញពីកត្តាធំៗចំនួន២ ដែលជះឥទ្ធិពលទៅលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យកម្ពុជារួមមាន៖ កត្តាខាងក្រៅ និងកត្តាខាងក្នុង។ កត្តាខាងក្រៅ ត្រូវបានផ្សំឡើងដោយកត្តាតូចៗចំនួន ៤ ទៀត មានជាអាទិ៍៖ កត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច។ កត្តាខាងក្នុង ក៏ត្រូវបានផ្សំឡើងដោយកត្តាតូចៗចំនួន ៤ ទៀតដែរ មានជាអាទិ៍៖ កត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន។

#### ៤.២.១.១. កត្តាខាងក្រៅ

*តារាង 4 ចរិតលក្ខណៈកត្តាខាងក្រៅ ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | កត្តាគ្រួសារ | ៣.៧១ | ០.៥៨ | ៣ |
| ២ | កត្តាសាលារៀន | ៣.៧៨ | ០.៦០ | ២ |
| ៣ | កត្តាព័ត៌មានទីផ្សារការងារ | ៣.៦៧ | ០.៥៦ | ៤ |
| ៤ | កត្តាសង្គម-សេដ្ឋកិច្ច | ៣.៨៩ | ០.៦០ | ១ |
| | **សរុប** | **៣.៧៦** | **០.៤៧** | |

តាម *តារាង ៤* បង្ហាញថា កត្តាខាងក្រៅ (រួមបញ្ចូលគ្នានូវកត្តាគ្រួសារ ១០ ឈ្មោះសំណួរ, កត្តាសាលារៀន ១២ ឈ្មោះសំណួរ, កត្តាព័ត៌មានទីផ្សារការងារ ១០ ឈ្មោះសំណួរ, និងកត្តាសង្គម-សេដ្ឋកិច្ច ៦ ឈ្មោះសំណួរ) បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៧៦ និងគម្លាតស្តង់ដា ០.៤៧។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមកត្តារងទាំង ៤ នៃខាងក្រៅក្នុងតារាងខាងលើនេះ ខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេគឺកត្តារងទី៤ (កត្តាសង្គម-សេដ្ឋកិច្ច) មានតម្លៃមធ្យម ៣.៨៩ និងគម្លាតស្តង់ដា ០.៦០។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ គឺកត្តារងទី២ (កត្តាសាលារៀន) មានតម្លៃមធ្យម ៣.៧៨ និងគម្លាតស្តង់ដា ០.៦០។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺកត្តារងទី១ (កត្តាគ្រួសារ) មានតម្លៃមធ្យម ៣.៧១ និងគម្លាតស្តង់ដា ០.៥៨។ ខ្លឹមសារដែលមានតម្លៃទាបជាងគេស្ថិតក្នុងលំដាប់ទី៤ គឺកត្តារងទី៤ (កត្តាព័ត៌មានទីផ្សារការងារ) មានតម្លៃមធ្យម ៣.៦៧ និងគម្លាតស្តង់ដា ០.៥៦។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា សិស្សវិទ្យាល័យនៅកម្ពុជាមាននិន្នាការគិតពិចារណាខ្លាំងទៅលើបញ្ហាសង្គម-សេដ្ឋកិច្ច មុននឹងគេសម្រេចចិត្តជ្រើសរើសអាជីព។

**ក.កត្តាគ្រួសារ**

ក្រុមគ្រួសារ ត្រូវបានចាត់ថាជាកត្តាមានឥទ្ធិពលដល់ការជ្រើសរើសអាជីពរបស់សិស្ស។ ក្នុងបរិបទកម្ពុជា ជាធម្មតាកុមារ និងយុវជន ត្រូវស្ថិតក្រោមការចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតចម្រើនវ័យដល់អាយុត្រូវចូលរៀន និងបន្តរហូតដល់ពួកគេមានលទ្ធភាពអាចដោះស្រាយបញ្ហាជីវភាពខ្លួនឯងបាន។ ក្នុងជីវភាពប្រចាំថ្ងៃនៃការរស់នៅក្នុងក្រុមគ្រួសារនីមួយៗ អន្តរទំនាក់ទំនងរវាងសមាជិកម្នាក់ទៅម្នាក់ អាចបង្កើតបានជាកត្តាលីករបង្កឱ្យមាននិន្នាការទំនោរ ឬទម្លាប់គ្រួសារកើតឡើង ដែលវាមានឥទ្ធិពលដល់ការរីកលូតលាស់ធំធាត់របស់កុមារ និងយុវជនក្រោមដំបូលតែមួយ។ តាមការសិក្សាស្រាវជ្រាវបង្ហាញថា កត្តាគ្រួសារ បានផ្តល់ការរួមចំណែកដែលមានឥទ្ធិពលដល់កុមារ និងយុវជនតាមរយៈការគាំទ្រផ្លូវអារម្មណ៍ ការរំពឹងទុករបស់គ្រួសារ ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការគាំទ្រផ្នែកព័ត៌មាន និងការផ្តល់ភាពជាគំរូ។

*តារាង 5 ចរិតលក្ខណៈកត្តាគ្រួសារ (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ក្រុមគ្រួសារ តែងលើកទឹកចិត្តខ្ញុំឱ្យខិតខំសិក្សារៀនសូត្រ ដើម្បីទទួលបានការងារល្អ | ៤.៣៤ | ០.៧៥ | ១ |
| ២ | ក្រុមគ្រួសារខ្ញុំ តែងអនុញ្ញាតនិងគាំទ្រខ្ញុំឱ្យធ្វើអ្វីដែលទាក់ទង នឹងចំណាប់អារម្មណ៍ ផ្ទាល់ខ្លួនរបស់ខ្ញុំ | ៣.៩០ | ០.៨៧ | ៣ |
| ៣ | ក្រុមគ្រួសារខ្ញុំ រំពឹងថាអាជីពដែលខ្ញុំជ្រើសរើសនាពេល អនាគត នឹងឆ្លើយតបនឹងបំណងប្រាថ្នារបស់ពួកគាត់ | ៣.៥៦ | ០.៩៤ | ៨ |
| ៤ | ក្រុមគ្រួសារខ្ញុំ រំពឹងថាខ្ញុំនឹងបន្តការសិក្សានៅឧត្តមសិក្សា បន្ទាប់ពីបញ្ចប់វិទ្យាល័យ និងទទួលបានការងារធ្វើជាក់លាក់ | ៣.៨៩ | ០.៨៦ | ៤ |
| ៥ | ក្រុមគ្រួសារខ្ញុំ ផ្គត់ផ្គង់ការចាយវាយដល់ខ្ញុំគ្រប់គ្រាន់ក្នុងការ សិក្សារៀនសូត្រទាំងនៅវិទ្យាល័យ ក៏ដូចជាឧត្តមសិក្សា | ៣.៧៣ | ០.៩០ | ៥ |
| ៦ | ខ្ញុំមិនមានក្តីបារម្ភផ្នែកហិរញ្ញវត្ថុក្នុងការសិក្សារៀនសូត្រ ដើម្បី ទទួលបានឱកាសការងារល្អប្រសើរនោះទេ | ៣.១៣ | ១.០១ | ១០ |
| ៧ | ក្រុមគ្រួសារខ្ញុំ តែងពិភាក្សាផ្តល់ព័ត៌មានផ្សេងៗពាក់ព័ន្ធ ជម្រើសអាជីពរបស់ខ្ញុំ | ៣.៧១ | ០.៩១ | ៦ |
| ៨ | រាល់ព័ត៌មានដែលទទួលបានពីក្រុមគ្រួសារខ្ញុំ វាពិតជាមាន សារៈសំខាន់ណាស់ សម្រាប់ខ្ញុំក្នុងការកំណត់គោលដៅអាជីព | ៣.៩១ | ០.៨៣ | ២ |
| ៩ | ការបំពេញការងាររបស់សមាជិកក្រុមគ្រួសារខ្ញុំ បានជះឥទ្ធិ ពលជាវិជ្ជមានដល់ ជម្រើសអាជីពរបស់ខ្ញុំ | ៣.៣០ | ១.០៣ | ៩ |
| ១០ | ខ្ញុំចង់បានការងារល្អ ដូចសមាជិកក្រុមគ្រួសារខ្ញុំដែរ | ៣.៦៥ | ១.០៦ | ៧ |
| | **សរុប** | **៣.៧១** | **០.៥៨** | |

តាម *តារាង ៥* បង្ហាញថា កត្តាគ្រួសារ បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៧១ និងគម្លាតស្តង់ដា ០.៥៨។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមឈ្មោះសំណួរទាំង ១០ នៃកត្តាគ្រួសារខាងលើ ខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេលំដាប់ពី ១ ដល់ ៣ គឺ ឈ្មោះសំណួរទី១ ស្ថិតក្នុងកម្រិតខ្ពស់ជាងគេ *«ក្រុមគ្រួសារ តែងលើកទឹកចិត្តខ្ញុំឱ្យខិតខំសិក្សារៀនសូត្រ ដើម្បីទទួលបានការងារល្អ»* មានតម្លៃមធ្យម ៤.៣៤ និងគម្លាតស្តង់ដា ០.៧៥ (ស្ថិតក្នុងកត្តារង៖ ការគាំទ្រផ្លូវអារម្មណ៍)។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ គឺឈ្មោះសំណួរទី៨ *«រាល់ព័ត៌មានដែលទទួលបានពីក្រុមគ្រួសារខ្ញុំ វាពិតជាមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំក្នុងការកំណត់គោលដៅអាជីព»* មានតម្លៃមធ្យម ៣.៩១ និងគម្លាតស្តង់ដា ០.៨៣ (ស្ថិតក្នុងកត្តារង៖ ការគាំទ្រផ្នែកព័ត៌មាន)។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺឈ្មោះសំណួរទី២ *«ក្រុមគ្រួសារខ្ញុំ តែងអនុញ្ញាតនិងគាំទ្រខ្ញុំឱ្យធ្វើអ្វីដែលទាក់ទងនឹងចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ខ្ញុំ»* មានតម្លៃមធ្យម ៣.៩០ និងគម្លាតស្តង់ដា ០.៨៧ (ស្ថិតក្នុងកត្តារង៖ ការគាំទ្រ ផ្លូវអារម្មណ៍)។ ដោយឡែក ខ្លឹមសារដែលមានតម្លៃទាបជាងគេបំផុត គឺឈ្មោះសំណួរទី៦ *«ខ្ញុំមិនមានក្ដីបារម្ភផ្នែកហិរញ្ញវត្ថុក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានឱកាសការងារល្អប្រសើរនោះទេ»* មានតម្លៃមធ្យម ៣.១៣ និងគម្លាតស្តង់ដា ១.០១ (ស្ថិតក្នុងកត្តារង៖ ការគាំទ្រផ្នែកហិរញ្ញវត្ថុ)។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា ក្នុងចំណោមកត្តារងទាំង ៥ ក្នុងកត្តាគ្រួសារ គឺកត្តារង *«ការគាំទ្រផ្លូវអារម្មណ៍»* និង *«ការគាំទ្រផ្នែកព័ត៌មាន»* បានដើរតួនាទីដ៏សំខាន់ក្នុងជម្រើសអាជីពរបស់សិស្ស វិទ្យាល័យនៅកម្ពុជា ខណៈកត្តារង *«ការគាំទ្រផ្នែកហិរញ្ញវត្ថុ»* ហាក់ដូចជាបានចូលរួមចំណែកតិចតួចដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា។

### ខ.កត្តាសាលារៀន

សាលារៀន ត្រូវបានចាត់ទុកថាជាទីស្ថានប្រមូលផ្ដុំដ៏សំខាន់មួយដែលកុមារ និងយុវជនចំណាយពេលវេលាប្រចាំថ្ងៃរបស់គេយូរជាងកន្លែងផ្សេងទៀត បន្ទាប់ពីផ្ទះសម្បែង។ ក្នុងប្រព័ន្ធអប់រំចំណេះទូទៅផ្លូវការរបស់កម្ពុជា កុមារ និងយុវជន ត្រូវស្ថិតក្រោមដំបូលសាលារៀនរយៈពេល ១២ ឆ្នាំ ដើម្បីបញ្ចប់ការសិក្សា

ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។ ក្នុងចិរវេលាដ៏យូរនេះ កុមារ និងយុវជន បានចម្រើនលូតលាស់ដំណាលគ្នានូវសរីរាង្គកាយ សតិបញ្ញាស្មារតី និងចំណេះដឹង ដើម្បីអាចប្រែក្លាយខ្លួនជាពលរដ្ឋពេញលេញក្នុងសង្គម។ អន្តរកម្មនានាក្នុងសាលារៀនជាអាទិ៍៖ ការគាំទ្ររបស់គ្រូបង្រៀន ការគាំទ្ររបស់មិត្តភក្តិ ការទទួលបានសេវាប្រឹក្សាអាជីព ការគាំទ្រផ្នែកសម្ភារៈរៀននិងបង្រៀន និងការផ្តល់ភាពជាគំរូ បានផ្តល់នូវឥទ្ធិពលមួយចំណែកដល់ការសម្រេចចិត្តជ្រើសរើសផ្លូវសិក្សា និងអាជីពការងាររបស់សិស្ស។

*តារាង 6 ចរិតលក្ខណៈកត្តាសាលារៀន (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ខ្ញុំពេញចិត្តនឹងការពិភាក្សាចែករំលែកពីគោលដៅអាជីពរបស់ខ្ញុំជាមួយលោកគ្រូអ្នកគ្រូនៅសាលារៀន | ៣.៥៤ | ០.៩៤ | ១២ |
| ២ | មុននឹងសម្រេចចិត្តជ្រើសរើសអាជីព ខ្ញុំតែងពិភាក្សាគ្នា និងទទួលយកយោបល់ពី លោកគ្រូអ្នកគ្រូដែលជិតស្និទ្ធ | ៣.៦៦ | ០.៩០ | ១០ |
| ៣ | ខ្ញុំមានអារម្មណ៍រីករាយក្នុងការចែករំលែកគោលដៅអាជីពរបស់ខ្ញុំជាមួយមិត្តភក្តិ | ៣.៨៧ | ០.៨៤ | ៣ |
| ៤ | មុននឹងសម្រេចចិត្តជ្រើសរើសអាជីព ខ្ញុំតែងពិភាក្សាគ្នា និងទទួលយកយោបល់ពី មិត្តភក្តិជិតស្និទ្ធ | ៣.៥៩ | ០.៩៦ | ១១ |
| ៥ | មុខវិជ្ជាដែលខ្ញុំចូលចិត្តនិងរៀនពូកែ គឺមានភាពទាក់ទងគ្នាទៅនឹងអាជីពដែលខ្ញុំចង់ ធ្វើនាពេលអនាគត | ៣.៧៤ | ០.៩០ | ៩ |
| ៦ | លទ្ធផលនៃការសិក្សារបស់ខ្ញុំ ជាផ្នែកមួយដ៏សំខាន់ក្នុងការរួមចំណែកសម្រេចក្តី សុបិនអាជីពនាពេលអនាគត | ៣.៩៣ | ០.៨៥ | ១ |
| ៧ | តាមរយៈកម្មវិធីតម្រង់ទិសអាជីពដែលសាលាបានរៀបចំ ពិតជាជួយខ្ញុំបានច្រើន ក្នុងការសម្រេចចិត្តជ្រើសរើសជំនាញសិក្សា និងអាជីព | ៣.៨៤ | ០.៨២ | ៥ |

| | | | | |
|---|---|---|---|---|
| ៨ | គ្រូប្រឹក្សាអាជីព បានផ្តល់យោបល់ និងលើកទឹកចិត្តខ្ញុំ ឱ្យជ្រើសរើសអាជីពផ្អែកលើចំណាប់អារម្មណ៍ និងបុគ្គលិក លក្ខណៈផ្ទាល់ខ្លួន | ៣.៧៩ | ០.៨៤ | ៧ |
| ៩ | សាលារៀនខ្ញុំមានបន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ សួនកសិកម្ម ពេងដាងបំណិនជីវិត បណ្ណាល័យ សម្រាប់សិស្សប្រើប្រាស់ ពង្រឹងសមត្ថភាពចំណេះដឹង | ៣.៧៩ | ០.៩៧ | ៧ |
| ១០ | ខ្ញុំពេញចិត្តនឹងការចូលរួមពិសោធន៍ ប្រើប្រាស់បន្ទប់កុំព្យូទ័រ ចូលរួមការងារបំណិន ជីវិត និងស្រាវជ្រាវឯកសារនៅបណ្ណាល័យ ដើម្បីពង្រឹងសមត្ថភាពផ្ទាល់ខ្លួនផ្សារ ភ្ជាប់នឹងជម្រើស អាជីពពេលអនាគត | ៣.៨៧ | ០.៨៦ | ៣ |
| ១១ | លោកគ្រូអ្នកគ្រូខ្ញុំ បានផ្តល់នូវភាពជាគំរូដ៏ល្អសម្រាប់ការ ជ្រើសរើសអាជីពរបស់ខ្ញុំ | ៣.៩៣ | ០.៧៩ | ១ |
| ១២ | លោកគ្រូអ្នកគ្រូក្នុងថ្នាក់ខ្ញុំ និងគណៈគ្រប់គ្រងសាលារៀន មានឥទ្ធិពលជាវិជ្ជមាន ទៅលើអាជីពដែលខ្ញុំចង់ធ្វើ | ៣.៨១ | ០.៨៤ | ៦ |
| | **សរុប** | **៣.៧៨** | **០.៦០** | |

តាម *តារាង ៦* បង្ហាញថា កត្តាសាលារៀន បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៧៨ និងគម្លាតស្តង់ដា ០.៦០។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមល្បះសំណួរទាំង ១២ នៃកត្តាសាលារៀនខាងលើ ខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេលំដាប់ពី ១ ដល់ ៣ គឺ ល្បះសំណួរទី៦ និងល្បះសំណួរទី១១ ស្ថិតក្នុងកម្រិតខ្ពស់ជាងគេស្មើនគ្នា *«លទ្ធផលនៃការសិក្សារបស់ខ្ញុំ ជាផ្នែកមួយដ៏សំខាន់ក្នុងការរួមចំណែកសម្រេចក្តី សុបិនអាជីពនាពេលអនាគត»* និង *«លោកគ្រូអ្នកគ្រូខ្ញុំ បានផ្តល់នូវភាពជាគំរូដ៏ល្អសម្រាប់ការជ្រើសរើសអាជីពរបស់ខ្ញុំ»* មានតម្លៃមធ្យម ៣.៩៣ និងគម្លាតស្តង់ដា ០.៨៥ (ស្ថិតក្នុងកត្តារង៖ លទ្ធផលសិក្សា) និងតម្លៃមធ្យម ៣.៩៣ និងគម្លាតស្តង់ដា ០.៧៩ (ស្ថិតក្នុងកត្តារង៖ ផ្តល់ភាពជាគំរូ)។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺល្បះសំណួរទី១០ *«ខ្ញុំពេញចិត្តនឹងការចូលរួមពិសោធន៍ ប្រើប្រាស់បន្ទប់កុំព្យូទ័រ ចូលរួមការងារបំណិនជីវិត និងស្រាវជ្រាវឯក*

*សារនៅបណ្ណាល័យ ដើម្បីពង្រឹងសមត្ថភាពផ្ទាល់ខ្លួនផ្សារភ្ជាប់នឹងជម្រើសអាជីពពេលអនាគត»* មានតម្លៃមធ្យម ៣.៨៧ និងគម្លាតស្តង់ដា ០.៨៦ (ស្ថិតក្នុងកត្តារង៖ ការគាំទ្រសម្ភារៈរៀននិងបង្រៀន)។ ដោយឡែក ខ្លឹមសារដែលមានតម្លៃទាបជាងគេបំផុតគឺល្បះសំណួរទី១ *«ខ្ញុំពេញចិត្តនឹងការពិភាក្សាចែករំលែកពីគោលដៅអាជីពរបស់ខ្ញុំជាមួយលោកគ្រូអ្នកគ្រូនៅសាលារៀន»* មានតម្លៃមធ្យម ៣.៥៤ និងគម្លាតស្តង់ដា ០.៩៤ (ស្ថិតក្នុងកត្តារង៖ ការគាំទ្ររបស់គ្រូបង្រៀន)។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា ក្នុងចំណោមកត្តារងទាំង ៦ ក្នុងកត្តាសាលារៀន គឺកត្តារង *«លទ្ធផលសិក្សា»* និង *«ការផ្តល់ភាពជាគំរូ»* បានដើរតួនាទីដ៏សំខាន់ក្នុងជម្រើសអាជីពរបស់សិស្ស វិទ្យាល័យនៅកម្ពុជា ខណៈកត្តារង *«ការគាំទ្ររបស់គ្រូបង្រៀន»* ហាក់ដូចជាបានចូលរួមចំណែកតិចតួចដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា។

### គ.កត្តាព័ត៌មានទីផ្សារការងារ

ព័ត៌មាន ជាចំណែកមួយដ៏សំខាន់ក្នុងការផ្តល់មូលដ្ឋានសម្រេចចិត្តមួយប្រកបដោយភាពច្បាស់លាស់។ ក្នុងជីវភាពជាសិស្សកម្រិតមធ្យមសិក្សា ជាដំណាក់ចុងបញ្ចប់នៃប្រព័ន្ធអប់រំចំណេះទូទៅផ្លូវការរយៈពេល ១២ ឆ្នាំ។ ក្រៅពីការសិក្សារៀនសូត្រក្រេបយកចំណេះដឹងលើមុខវិជ្ជានៅសាលារៀន ការសិក្សាស្វែងយល់ និងទទួលបានព័ត៌មានសំខាន់ៗពីសង្គម ជាពិសេសព័ត៌មានទីផ្សារការងារ គឺជាការណ៍មួយដែលមិនអាចខ្វះបាន។ ការទទួលបានព័ត៌មានទីផ្សារការងារគ្រប់គ្រាន់ និងសម្បូរបែប ជាចំណែកមួយជះឥទ្ធិពលដល់ការរៀបចំផែនការអាជីពរបស់សិស្ស ដោយហេតុថានៅក្នុងព័ត៌មានទីផ្សារការងារ មានប្រមូលផ្តុំទៅដោយធាតុផ្សំសំខាន់ៗដូចជា៖ ទីកន្លែងបំពេញការងារ តំណែងតួនាទី ប្រាក់កម្រៃនិងអត្ថប្រយោជន៍ លក្ខខណ្ឌការងារ និងលទ្ធភាពទទួលបានការងារ ក្នុងប្រភេទអាជីពមុខរបរនីមួយៗ។

*តារាង 7 ចរិតលក្ខណៈកត្តាព័ត៌មានទីផ្សារការងារ (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ខ្ញុំចង់បានការងារធ្វើនៅទីប្រជុំជន រាជធានី ឬតំបន់សេដ្ឋកិច្ចពិសេស | ៣.៨៤ | ០.៨៩ | ២ |
| ២ | ខ្ញុំចង់បានកន្លែងធ្វើការដែលនៅជិតៗផ្ទះ ឬមិនឆ្លងខេត្តទៅឆ្ងាយ | ៣.៧៦ | ០.៩៦ | ៥ |
| ៣ | ខ្ញុំចង់ធ្វើការងារណាដែលឆាប់ឡើងតំណែងតួនាទី | ៣.៣១ | ១.០១ | ១០ |
| ៤ | ខ្ញុំនឹងផ្លាស់ប្តូរកន្លែងធ្វើការ ទៅកន្លែងផ្សេងណាដែលផ្តល់តួនាទីសមរម្យដល់ខ្ញុំ | ៣.៥៦ | ០.៩២ | ៧ |
| ៥ | ខ្ញុំនឹងជ្រើសរើសអាជីពការងារណាដែលផ្តល់ប្រាក់ខែ និងមានអត្ថប្រយោជន៍ច្រើន | ៣.៨៣ | ០.៨៤ | ៣ |
| ៦ | ខ្ញុំអាចនឹងផ្លាស់ប្តូរកន្លែងធ្វើការ ឬអាជីព ដើម្បីទទួលបានប្រាក់ខែកាន់តែច្រើន | ៣.៣៥ | ០.៩៥ | ៩ |
| ៧ | មុននឹងសម្រេចចិត្តជ្រើសរើសអាជីពណាមួយ ខ្ញុំត្រូវគិតដល់លក្ខខណ្ឌបំពេញ ការងារ តួនាទីនិងការទទួលខុសត្រូវ ឱ្យបានច្បាស់លាស់ជាមុនសិន | ៤.០៩ | ០.៦៨ | ១ |
| ៨ | ខ្ញុំអាចពិពណ៌នាអំពីលក្ខខណ្ឌការងារ តួនាទីការទទួលខុសត្រូវក្នុងអាជីពមុខរបរ ដែលខ្ញុំជ្រើសរើស | ៣.៨១ | ០.៧៣ | ៤ |
| ៩ | អាជីពការងារដែលខ្ញុំជ្រើសរើស គឺមានភាពងាយស្រួលក្នុងការឆាប់បានការងារធ្វើ | ៣.៤៦ | ០.៨៩ | ៨ |
| ១០ | ឱកាសការងារនាពេលអនាគត ពិតជាជះឥទ្ធិពលដល់ការជ្រើសរើសអាជីពរបស់ខ្ញុំ | ៣.៧ | ០.៨៤ | ៦ |
| | **សរុប** | **៣.៦៧** | **០.៥៦** | |

តាម *តារាង ៧* បង្ហាញថា កត្តាព័ត៌មានទីផ្សារការងារ បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៦៧ និងគម្លាតស្តង់ដា ០.៥៦។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមល្បះសំណួរទាំង ១០ នៃកត្តាព័ត៌មានទីផ្សារការងារខាងលើខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេលំដាប់ពី ១ ដល់ ៣ គឺ ល្បះសំណួរទី៧ ស្ថិតក្នុងកម្រិតខ្ពស់ជាងគេ *«មុននឹងសម្រេចចិត្តជ្រើសរើសអាជីពណាមួយ ខ្ញុំត្រូវគិតដល់លក្ខខណ្ឌបំពេញការងារ តួនាទីនិងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ជាមុនសិន»* មានតម្លៃមធ្យម ៤.០៩ និងគម្លាតស្តង់ដា ០.៦៨ (ស្ថិតក្នុងកត្តារង៖ លក្ខខណ្ឌការងារ)។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ គឺល្បះសំណួរទី១ *«ខ្ញុំចង់បានការងារធ្វើនៅទីប្រជុំជន រាជធានី ឬតំបន់សេដ្ឋកិច្ចពិសេស»* មានតម្លៃមធ្យម ៣.៨៤ និងគម្លាតស្តង់ដា ០.៨៩ (ស្ថិតក្នុងកត្តារង៖ ទីកន្លែងបំពេញការងារ)។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺល្បះសំណួរទី៥ *«ខ្ញុំនឹងជ្រើសរើសអាជីពការងារណាដែលផ្តល់ប្រាក់ខែ និងមានអត្ថប្រយោជន៍ច្រើន»* មានតម្លៃមធ្យម ៣.៨៣ និងគម្លាតស្តង់ដា ០.៨៤ (ស្ថិតក្នុងកត្តារង៖ ប្រាក់កម្រៃនិងអត្ថប្រយោជន៍)។ ដោយឡែក ខ្លឹមសារដែលមានតម្លៃទាបជាងគេបំផុតគឺល្បះសំណួរទី៣ *«ខ្ញុំចង់ធ្វើការងារណាដែលឆាប់ឡើងតំណែងតួនាទី»* មានតម្លៃមធ្យម ៣.៣១ និង គម្លាតស្តង់ដា ១.០១ (ស្ថិតក្នុងកត្តារង៖ តំណែងតួនាទី)។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា ក្នុងចំណោមកត្តារងទាំង ៥ ក្នុងកត្តាព័ត៌មានទីផ្សារការងារ គឺកត្តារង *«លក្ខខណ្ឌការងារ»*, *«ទីកន្លែងបំពេញការងារ»* និង *«ប្រាក់កម្រៃនិងអត្ថប្រយោជន៍»* បានដើរតួនាទីដ៏សំខាន់ក្នុងជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា ខណៈកត្តារង *«មុខតំណែងតួនាទី»* ហាក់ដូចជាបានចូលរួមចំណែកតិចតួចដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា។

### ឃ.កត្តាសង្គម-សេដ្ឋកិច្ច

សង្គម-សេដ្ឋកិច្ច ក៏ត្រូវបានកត់សម្គាល់ថាមានជាប់ពាក់ព័ន្ធទៅនឹងការសម្រេចចិត្តជ្រើសរើសអាជីពការងាររបស់យុវជន។ ជាទូទៅក្នុងដំណើរការសង្គមនីមួយៗ គេតែងសង្កេតឃើញតម្រូវការជាមូលដ្ឋាន និង

តម្រូវការបន្ទាប់បន្សំផ្សេងៗទៀត ត្រូវបានបំពេញដល់មនុស្សម្នាក់ៗមិនដូចគ្នាទេ ដោយវាត្រូវអាស្រ័យខ្លាំងទៅលើតថភាពសង្គម-សេដ្ឋកិច្ចជាក់ស្តែងរបស់សង្គមតែម្តង។ នៅសង្គម-សេដ្ឋកិច្ច អភិវឌ្ឍចម្រើនលូតលាស់លឿនរហ័ស ការគិតរបស់មនុស្សនៅក្នុងសង្គមនោះក៏កាន់តែស៊ីវិល័យ ភ្ជាប់ទៅនឹងតម្រូវការកាន់តែខ្ពស់។ ក្នុងស្ថានភាពនៃការគិតគូរពីអនាគតអាជីពការងាររបស់ខ្លួន យុវជនជាសិស្សវិទ្យាល័យនៅកម្ពុជាមួយចំនួនបានដាក់ក្តីស្រមៃប្រាថ្នាចង់បានអាជីពការងារដែលអាចនាំរូបគេឱ្យមានឋានៈល្អ មានគុណតម្លៃសង្គម និងឆ្លើយតបទៅនឹងដំណើរវិវត្តជឿនលឿនផ្នែកសេដ្ឋកិច្ច ដើម្បីជាផ្នែកមួយនៃនិរន្តរភាពការងារ។

*តារាង 8 ចរិតលក្ខណៈកត្តាសង្គម-សេដ្ឋកិច្ច (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | អាជីពដែលខ្ញុំជ្រើសរើសនាពេលអនាគត នឹងផ្តល់ឱ្យខ្ញុំនូវកិត្តិយសថ្លៃថ្នូរក្នុងសង្គម | ៤.០៤ | ០.៧៥ | ១ |
| ២ | ខ្ញុំនឹងប្រកបតែអាជីពណាដែលសង្គមផ្តល់តម្លៃប៉ុណ្ណោះ | ៤.០៣ | ០.៨៦ | ២ |
| ៣ | ការជ្រើសរើសអាជីពរបស់ខ្ញុំ គឺអាស្រ័យលើស្ថានភាពរីកដុះដាលផ្នែកសេដ្ឋកិច្ច និងតម្រូវការជាក់ស្តែងរបស់សង្គម | ៣.៧៦ | ០.៨៣ | ៥ |
| ៤ | ខ្ញុំនឹងតាមដានការវិវត្តនៃតម្រូវការ-ការផ្គត់ផ្គង់កម្លាំងពលកម្ម និងស្ថានភាព សេដ្ឋកិច្ចជាប្រចាំ ព្រោះថាវាជះឥទ្ធិពលដល់ការជ្រើសរើសអាជីពរបស់ខ្ញុំ | ៣.៦៨ | ០.៧៩ | ៦ |
| ៥ | អាជីពដែលខ្ញុំជ្រើសរើស ត្រូវបានសង្គមផ្តល់គុណតម្លៃ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង | ៣.៩៧ | ០.៧៥ | ៣ |
| ៦ | អាជីពដែលខ្ញុំជ្រើសរើស ត្រូវបានការកោតសរសើរពីមនុស្សទូទៅ ដែលវាជាផ្នែក មួយនៃការជំរុញឱ្យមានវឌ្ឍនភាពសង្គម | ៣.៨៧ | ០.៧៩ | ៤ |
| | **សរុប** | **៣.៨៩** | **០.៦០** | |

តាម *តារាង ៨* បង្ហាញថា កត្តាសង្គម-សេដ្ឋកិច្ច បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៨៩ និងគម្លាតស្តង់ដា ០.៦០។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមល្បះសំណួរទាំង ៦ នៃកត្តាសង្គម-សេដ្ឋកិច្ចខាងលើខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេលំដាប់ពី ១ ដល់ ៣ គឺ ល្បះសំណួរទី១ ស្ថិតក្នុងកម្រិតខ្ពស់ជាងគេ *«អាជីពដែលខ្ញុំជ្រើសរើសនាពេលអនាគត នឹងផ្តល់ឱ្យខ្ញុំនូវកិត្តិយសថ្លៃថ្នូរក្នុងសង្គម»* មានតម្លៃមធ្យម ៤.០៤ និងគម្លាតស្តង់ដា ០.៧៥ (ស្ថិតក្នុងកត្តារង៖ ឋានៈសង្គម)។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ គឺល្បះសំណួរទី២ *«ខ្ញុំនឹងប្រកបតែអាជីពណាដែលសង្គមផ្តល់តម្លៃប៉ុណ្ណោះ»* មានតម្លៃមធ្យម ៤.០៣ និងគម្លាតស្តង់ដា ០.៨៦ (ស្ថិតក្នុងកត្តារង៖ ឋានៈសង្គម)។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺល្បះសំណួរទី៥ *«អាជីពដែលខ្ញុំជ្រើសរើស ត្រូវបានសង្គមផ្តល់គុណតម្លៃ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង»* មានតម្លៃមធ្យម ៣.៩៧ និងគម្លាតស្តង់ដា ០.៧៥ (ស្ថិតក្នុងកត្តារង៖ គុណតម្លៃសង្គម)។ ដោយឡែក ខ្លឹមសារដែលមានតម្លៃទាបជាងគេបំផុតគឺល្បះសំណួរទី៤ *«ខ្ញុំនឹងតាមដានការវិវត្តនៃតម្រូវការ-ការផ្គត់ផ្គង់កម្លាំងពលកម្ម និងស្ថានភាពសេដ្ឋកិច្ចជាប្រចាំ ព្រោះថាវាជះឥទ្ធិពលដល់ការជ្រើសរើសអាជីពរបស់ខ្ញុំ»* មានតម្លៃមធ្យម ៣.៦៩ និង គម្លាតស្តង់ដា ០.៧៩ (ស្ថិតក្នុងកត្តារង៖ ការវិវត្តផ្នែកសេដ្ឋកិច្ច)។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា ក្នុងចំណោមកត្តារងទាំង ៣ ក្នុងកត្តាព័ត៌មានទីផ្សារការងារ គឺកត្តារង *«ឋានៈសង្គម»* និង *«គុណតម្លៃសង្គម»* បានដើរតួនាទីដ៏សំខាន់ក្នុងជម្រើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា ខណៈកត្តារង *«ការវិវត្តផ្នែកសេដ្ឋកិច្ច»* ហាក់ដូចជាបានចូលរួមចំណែកតិចតួចដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា។

### ៤.២.១.២. កត្តាខាងក្នុង

*តារាង ១ ចរិតលក្ខណៈកត្តាខាងក្នុង ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | កត្តាភាពជឿជាក់លើខ្លួនឯង | ៣.៨១ | ០.៥៣ | ២ |
| ២ | កត្តាលទ្ធផលរំពឹងទុក | ៣.៨៤ | ០.៥៧ | ១ |
| ៣ | កត្តាទេពកោសល្យផ្ទាល់ខ្លួន | ៣.៦៦ | ០.៦១ | ៣ |
| ៤ | កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន | ៣.៥៨ | ០.៥៧ | ៤ |
| | **សរុប** | **៣.៧២** | **០.៤៩** | |

តាម *តារាង ៩* បង្ហាញថា កត្តាខាងក្នុង (រួមបញ្ចូលគ្នានូវកត្តាភាពជឿជាក់លើខ្លួនឯង ១០ ល្បះសំណួរ, កត្តាលទ្ធផលរំពឹងទុក ១០ ល្បះសំណួរ, កត្តាទេពកោសល្យផ្ទាល់ខ្លួន ១០ ល្បះសំណួរ, និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ១២ ល្បះសំណួរ) បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ដែលមានតម្លៃមធ្យម ៣.៧២ និងគម្លាតស្តង់ដា ០.៤៩។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមកត្តារងទាំង ៤ នៃកត្តាខាងក្នុង តាមរយៈតារាងខាងលើនេះ ខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេគឺកត្តារងទី២ (កត្តាលទ្ធផលរំពឹងទុក) មានតម្លៃមធ្យម ៣.៨៤ និងគម្លាតស្តង់ដា ០.៥៧។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ គឺកត្តារងទី១ (កត្តាភាពជឿជាក់លើខ្លួនឯង) មានតម្លៃមធ្យម ៣.៨១ និងគម្លាតស្តង់ដា ០.៥៣។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺកត្តារងទី៣ (កត្តាទេពកោសល្យផ្ទាល់ខ្លួន) មានតម្លៃមធ្យម ៣.៦៦ និងគម្លាតស្តង់ដា ០.៦១។ ខ្លឹមសារដែលមានតម្លៃទាបជាងគេ ស្ថិតក្នុងលំដាប់ទី៤ គឺកត្តារងទី៤ (កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន) មានតម្លៃមធ្យម ៣.៥៨ និងគម្លាតស្តង់ដា ០.៥៧។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា សិស្សវិទ្យាល័យនៅកម្ពុជាមាននិន្នាការគិតពិចារណាខ្លាំងទៅលើលទ្ធផលរំពឹងទុក មុននឹងគេសម្រេចចិត្តជ្រើសរើសអាជីព។

### ក.កត្តាភាពជឿជាក់លើខ្លួនឯង

ភាពជឿជាក់ បានដើរតួនាទីដ៏សំខាន់ក្នុងដំណើរការសម្រេចចិត្តជ្រើសរើសជំនាញសិក្សា និងអាជីពការងាររបស់សិស្ស។ នៅពេលដែលបុគ្គលម្នាក់មានភាពច្បាស់លាស់ក្នុងចិត្ត គេនឹងអាចពុះពារជំនះរាល់ឧបសគ្គធំតូច ដើម្បីបន្តដំណើរទៅមុខសម្រេចបានជោគជ័យដ៏ត្រចះត្រចង់។ យ៉ាងណាមិញ ក្នុងតួនាទីជាសិស្ស អ្វីដែលអាចជួយពួកគេឱ្យសម្រេចក្ដីស្រមៃថ្ងៃអនាគតក្នុងរូបភាពបែបណានោះ គឺទាមទារឱ្យបុគ្គលជាសិស្សនោះ មានភាពប្រាកដប្រជាជឿជាក់ច្បាស់លាស់លើខ្លួនឯង ជាពិសេសពាក់ព័ន្ធទៅនឹងការសម្រេចចិត្តដាក់ចេញនូវគោលដៅអាជីពការងារ។ ដើម្បីជាមូលដ្ឋានជួយដល់បុគ្គលម្នាក់អាចសម្រេចជ្រើសរើសអាជីពដោយជំហរនៃភាពជឿជាក់លើខ្លួនឯង ពួកគេត្រូវពិចារណាលើជាតុផ្សំសំខាន់ៗដូចជា៖ ការជ្រើសរើសគោលដៅ ព័ត៌មានអំពីមុខរបរ ការរៀបចំផែនការ ការស្វ័យវាយតម្លៃផ្ទាល់ខ្លួន និងការដោះស្រាយបញ្ហា។

*តារាង 10 ចរិតលក្ខណៈកត្តាភាពជឿជាក់លើខ្លួនឯង (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ខ្ញុំជ្រើសរើសជំនាញសិក្សា ឬអាជីពការងារ ចេញពីបញ្ជីដែលបានព្រាងទុកពីមុន | ៣.៤៩ | ០.៨៧ | ៩ |
| ២ | ខ្ញុំសម្រេចចិត្តជ្រើសរើសអាជីព ដោយមិនមានអារម្មណ៍ស្ដាយក្រោយថាការជ្រើសរើសនោះខុស ឬត្រូវឡើយ | ៣.៨៣ | ០.៨២ | ៧ |
| ៣ | ខ្ញុំនឹងស្វែងរកព័ត៌មានបន្ថែមដើម្បីកំណត់ថា តើមុខជំនាញដែលខ្ញុំនឹងរៀន ឆ្លើយ តបទៅនឹងគោលដៅអាជីពដែលខ្ញុំនឹងជ្រើសរើសឬយ៉ាងណា | ៣.៩១ | ០.៧២ | ៥ |
| ៤ | ខ្ញុំនឹងស្វែងរកព័ត៌មានបន្ថែមអំពីឱកាសការងារក្នុងអាជីពដែលខ្ញុំជ្រើសរើស តាមរយៈប្រភពព័ត៌មានផ្សេងៗ និងអ្នកដែលកំពុងធ្វើការក្នុងអាជីពនេះ | ៣.៩៤ | ០.៦៩ | ៣ |

| | | | | |
|---|---|---|---|---|
| ៥ | ខ្ញុំបានកំណត់ជំហានសំខាន់ៗ ដើម្បីសម្រេចជោគជ័យក្នុងការជ្រើសរើសអាជីព | ៣.៩១ | ០.៧៤ | ៦ |
| ៦ | ខ្ញុំរៀបចំផែនការផ្ទាល់ខ្លួន សម្រាប់ការជ្រើសរើសអាជីពរបស់ខ្ញុំ | ៣.៩៨ | ០.៧១ | ១ |
| ៧ | ជាធម្មតា ខ្ញុំតែងធ្លុះបញ្ជាំងសមត្ថភាពផ្ទាល់ខ្លួន ទៅនឹងអាជីពដែលខ្ញុំជ្រើសរើស | ៣.៨ | ០.៧៦ | ៨ |
| ៨ | ខ្ញុំកំណត់ជ្រើសរើសអាជីពដែលសក្តិសមបំផុតសម្រាប់ខ្លួនខ្ញុំ | ៣.៩៥ | ០.៧៣ | ២ |
| ៩ | ខ្ញុំនឹងផ្លាស់ប្តូរអាជីពការងារ ប្រសិនបើខ្ញុំមានភាពមិនពេញចិត្តនៅពេលក្រោយ | ៣.៤១ | ០.៩៣ | ១០ |
| ១០ | ប្រសិនមានបញ្ហាក្នុងការសិក្សា ខ្ញុំនឹងកំណត់ជំហានដែលត្រូវដោះស្រាយភ្លាមៗ | ៣.៩៣ | ០.៧១ | ៤ |
| | **សរុប** | **៣.៨១** | **០.៥៣** | |

តាម *តារាង ១០* បង្ហាញថា កត្តាភាពជឿជាក់លើខ្លួនឯង បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៨១ និងគម្លាតស្តង់ដា ០.៥៣។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមល្បះសំណួរទាំង ១០ នៃកត្តាភាពជឿជាក់លើខ្លួនឯងខាងលើ ខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេលំដាប់ពី ១ ដល់ ៣ គឺ ល្បះសំណួរទី៦ ស្ថិតក្នុងកម្រិតខ្ពស់ជាងគេ *«ខ្ញុំរៀបចំផែនការផ្ទាល់ខ្លួន សម្រាប់ការជ្រើសរើសអាជីពរបស់ខ្ញុំ»* មានតម្លៃមធ្យម ៣.៩៨ និងគម្លាតស្តង់ដា ០.៧១ (ស្ថិតក្នុងកត្តារង៖ ការរៀបចំផែនការ)។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ គឺល្បះសំណួរទី៨ *«ខ្ញុំកំណត់ជ្រើសរើសអាជីពដែលសក្តិសមបំផុតសម្រាប់ខ្លួនខ្ញុំ»* មានតម្លៃមធ្យម ៣.៩៥ និងគម្លាតស្តង់ដា ០.៧៣ (ស្ថិតក្នុងកត្តារង៖ ការស្វ័យវាយតម្លៃផ្ទាល់ខ្លួន)។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺល្បះសំណួរទី៤ *«ខ្ញុំនឹងស្វែងរកព័ត៌មានបន្ថែមអំពីឱកាសការងារក្នុងអាជីពដែលខ្ញុំជ្រើសរើស តាមរយៈប្រភពព័ត៌មានផ្សេងៗ និងអ្នកដែលកំពុងធ្វើការក្នុងអាជីពនេះ»* មានតម្លៃមធ្យម ៣.៩៥ និងគម្លាតស្តង់ដា ០.៧៣ (ស្ថិតក្នុងកត្តារង៖ ព័ត៌មានអំពីមុខរបរ)។ ដោយឡែក ខ្លឹមសារដែលមានតម្លៃទាបជាងគេបំផុត

គឺឈ្មោះសំណួរទី៩ *«ខ្ញុំនឹងផ្លាស់ប្តូរអាជីពការងារ ប្រសិនបើខ្ញុំមានភាពមិនពេញចិត្តនៅពេលក្រោយ»* មានតម្លៃមធ្យម ៣.៤១ និង គម្លាតស្តង់ដា ០.៩៣ (ស្ថិតក្នុងកត្តារង៖ ការដោះស្រាយបញ្ហា)។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា ក្នុងចំណោមកត្តារងទាំង ៥ ក្នុងកត្តាភាពជឿជាក់លើខ្លួនឯង គឺកត្តារង *«ការរៀបចំផែនការ»*, *«ការស្វ័យវាយតម្លៃផ្ទាល់ខ្លួន»* និង *«ព័ត៌មានអំពីមុខរបរ»* បានដើរតួនាទីដ៏សំខាន់ក្នុងជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ខណៈកត្តារង *«ការដោះស្រាយបញ្ហា»* ហាក់ដូចជាបានចូលរួមចំណែកតិចតួចដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា។

**ខ.កត្តាលទ្ធផលរំពឹងទុក**

ការរំពឹងទុកពីជោគជ័យ គឺជាជំនឿរបស់មនុស្សអំពីរបៀបដែលពួកគេនឹងធ្វើបានល្អលើកិច្ចការណាមួយនាពេលខាងមុខ ចំណែកឯតម្លៃនៃកិច្ចការនោះគឺសំដៅលើការលើកទឹកចិត្ត ឬហេតុផលសម្រាប់ការបំពេញកិច្ចការចំពោះមុខ។ ក្នុងការធ្វើកិច្ចការអ្វីមួយ បុគ្គលគ្រប់រូបតែងភ្ជាប់សកម្មភាពទៅនឹងការរំពឹងទុកលើលទ្ធផលទទួលបាន។ ការរំពឹងទុកលើលទ្ធផលក្នុងតួនាទីជាសិស្សវិញ ជាចំណែកមួយបំផុសឱ្យពួកគេពង្រឹងខ្លួនឯង ខិតខំបង្កើនសមត្ថភាពចំណេះដឹង ដើម្បីសម្រេចបាននូវអ្វីមួយដែលគេប៉ងប្រាថ្នា។ ក្របខណ្ឌនៃការធ្វើសេចក្តីសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្ស ការរំពឹងទុកពីលទ្ធផលទទួលបាន បានរួមវិភាគទានជំធេងដល់ពួកគេឱ្យផ្តោតការយកចិត្តទុកដាក់ខ្ពស់លើ ឥរិយាបថនៃការទទួលបានការអប់រំ និងឥរិយាបថនៃការជ្រើសរើសអាជីព ប្រកបដោយការទទួលខុសត្រូវខ្ពស់លើវាសនាអនាគតខ្លួនឯង។

*តារាង 11 ចរិតលក្ខណៈកត្តាលទ្ធផលរំពឹងទុក (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ប្រសិនខ្ញុំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ខ្ញុំនឹងទទួលបានលទ្ធផលល្អប្រសើរ | ៤.០៨ | ០.៧៤ | ១ |

| | | | | |
|---|---|---|---|---|
| ២ | ប្រសិនខ្ញុំធ្វើកិច្ចការនៅសាលាបានល្អ ខ្ញុំនឹងមានលទ្ធភាពកាន់តែល្អក្នុងការសម្រេច គោលដៅអនាគត | ៣.៨៥ | ០.៨២ | ៦ |
| ៣ | ប្រសិនខ្ញុំទទួលបានចំណាត់ថ្នាក់ល្អ ខ្ញុំនឹងមានលទ្ធភាពជ្រើសរើសអាជីពសមរម្យ | ៣.៦១ | ០.៨៧ | ១០ |
| ៤ | ប្រសិនខ្ញុំទទួលបានមធ្យមភាគប្រចាំឆ្នាំល្អ ខ្ញុំនឹងមានលទ្ធភាពជ្រើសរើសអាជីពក្នុង វិស័យផ្សេងៗបានច្រើន | ៣.៦២ | ០.៨៩ | ៩ |
| ៥ | ការបំពេញការងារនៅសាលារៀនបានល្អ មានន័យថាខ្ញុំនឹងអាចដឹកនាំជីវិតរបស់ខ្ញុំ បានប្រសើរដូចគ្នា | ៣.៦៥ | ០.៨៦ | ៨ |
| ៦ | ប្រសិនខ្ញុំសិក្សាស្រាវជ្រាវឱ្យបានច្រើនពីអាជីពការងារផ្សេងៗ ខ្ញុំនឹងមានលទ្ធភាពសម្រេចចិត្តជ្រើសរើសអាជីពការងារផ្ទាល់ខ្លួនបានកាន់តែល្អប្រសើរ | ៣.៩២ | ០.៧១ | ៤ |
| ៧ | ប្រសិនខ្ញុំសិក្សាស្វែងយល់ពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និងសមត្ថភាពខ្លួនឯងបានច្បាស់ ខ្ញុំនឹងអាចមានលទ្ធភាពជ្រើសរើសអាជីពការងារបានកាន់តែល្អប្រសើរ | ៣.៩៨ | ០.៦៩ | ២ |
| ៨ | ប្រសិនខ្ញុំយល់ដឹងពីតម្រូវការការអប់រំសម្រាប់អាជីពការងារនីមួយៗបានច្បាស់ ខ្ញុំ នឹងមានលទ្ធភាពជ្រើសរើសអាជីពការងារបានកាន់តែល្អប្រសើរ | ៣.៩ | ០.៧១ | ៥ |
| ៩ | ប្រសិនខ្ញុំចំណាយពេលក្នុងការសិក្សាស្វែងយល់អំពីអាជីពការងារផ្សេងៗ បានគ្រប់គ្រាន់ ខ្ញុំអាចរៀនសូត្រពីអ្វីដែលខ្ញុំគួរធ្វើដើម្បីសម្រេចចិត្តជ្រើសរើសអាជីពមួយបានត្រឹមត្រូវល្អ | ៣.៩៣ | ០.៧០ | ៣ |
| ១០ | ប្រសិនខ្ញុំបានជួបប្រាស្រ័យជាមួយអ្នកដែលប្រកបអាជីពការងារផ្សេងៗបានច្រើនគ្នា ខ្ញុំនឹងអាចធ្វើការសម្រេចចិត្តជ្រើសរើសអាជីពដ៏ល្អមួយ | ៣.៨៣ | ០.៧៧ | ៧ |
| | **សរុប** | **៣.៨៤** | **០.៥៧** | |

តាម *តារាង ១១* បង្ហាញថា កត្តាលទ្ធផលរំពឹងទុក បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៨៤ និងគម្លាតស្តង់ដា ០.៥៧។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមល្បះសំណួរទាំង ១០ នៃកត្តាលទ្ធផលរំពឹងទុកខាងលើ ខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេលំដាប់ពី ១ ដល់ ៣ គឺ ល្បះសំណួរទី១ ស្ថិតក្នុងកម្រិតខ្ពស់ជាងគេ *«ប្រសិនខ្ញុំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ខ្ញុំនឹងទទួលបានលទ្ធផលល្អប្រសើរ»* មានតម្លៃមធ្យម ៤.០៨ និងគម្លាតស្តង់ដា ០.៧៤ (ស្ថិតក្នុងកត្តារង៖ ឥរិយាបថនៃការទទួលបានការអប់រំ)។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ និងទី៣ គឺល្បះសំណួរទី៧ *«ប្រសិនខ្ញុំសិក្សាស្វែងយល់ពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និងសមត្ថភាពខ្លួនឯងបានច្បាស់ ខ្ញុំនឹងអាចមានលទ្ធភាពជ្រើសរើសអាជីពការងារបានកាន់តែល្អប្រសើរ»* មានតម្លៃមធ្យម ៣.៩៨ និងគម្លាតស្តង់ដា ០.៦៩ និងល្បះសំណួរទី៩ *«ប្រសិនខ្ញុំចំណាយពេលក្នុងការសិក្សាស្វែងយល់អំពីអាជីពការងារផ្សេងៗបានគ្រប់គ្រាន់ ខ្ញុំអាចរៀនសូត្រពីអ្វីដែលខ្ញុំគួរធ្វើដើម្បីសម្រេចចិត្តជ្រើសរើសអាជីពមួយបានត្រឹមត្រូវល្អ»* មានតម្លៃមធ្យម ៣.៩៣ និងគម្លាតស្តង់ដា ០.៧០ (ស្ថិតក្នុងកត្តារង៖ ឥរិយាបថនៃការជ្រើសរើសអាជីព ដូចគ្នា)។ ដោយឡែក ខ្លឹមសារដែលមានតម្លៃទាបជាងគេបំផុត គឺល្បះសំណួរទី៣ *«ប្រសិនខ្ញុំទទួលបានចំណាត់ថ្នាក់ល្អ ខ្ញុំនឹងមានលទ្ធភាពជ្រើសរើសអាជីពសមរម្យ»* មានតម្លៃមធ្យម ៣.៦១ និងគម្លាតស្តង់ដា ០.៨៧ (ស្ថិតក្នុងកត្តារង៖ ឥរិយាបថនៃការទទួលបានការអប់រំ)។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា ក្នុងចំណោមកត្តារងទាំង ២ ក្នុងកត្តាលទ្ធផលរំពឹងទុក គឺកត្តារង *«ឥរិយាបថនៃការជ្រើសរើសអាជីព»*, បានដើរតួនាទីដ៏សំខាន់ក្នុងជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ខណៈកត្តារង *«ឥរិយាថនៃការទទួលបានការអប់រំ»* ហាក់ដូចជាបានចូលរួមចំណែកតិចតួចដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា។

### គ.កត្តាទេពកោសល្យផ្ទាល់ខ្លួន

ទេពកោសល្យផ្ទាល់ខ្លួន គឺជាសមត្ថភាពពិសេសដែលធម្មជាតិបានប្រគល់ជូនបុគ្គលម្នាក់ៗ។ ទេពកោសល្យផ្ទាល់ខ្លួននេះ បានផ្តល់ឱ្យបុគ្គលម្នាក់ៗអាចស្តែងចេញនូវសក្តានុពលមិនចេះរីងស្ងួត ជាពិសេស

ក្នុងវិថីនៃការបំពេញមុខនាទីការងារក្នុងវិជ្ជាជីវៈឬអាជីពការងារ។ ជាមួយគ្នានេះ វាបានរួមចំណែកជះឥទ្ធិពលដល់ការសម្រេចចិត្តជ្រើសរើសអាជីពការងាររបស់បុគ្គលម្នាក់ៗ តាមរយៈការពិនិត្យឆ្លុះបញ្ចាំងលើសមត្ថភាពតម្រូវការបុគ្គល គុណតម្លៃខាងក្នុងនិងខាងក្រៅ ផ្សារភ្ជាប់ទៅនឹងគោលដៅនិងចរិតលក្ខណៈនៃអាជីព។ ដំណាក់កាលជ្រើសរើសអាជីពដំបូងរបស់យុវជនកម្រិតវិទ្យាល័យ គឺពិតជាមានភាពពាក់ព័ន្ធទៅនឹងការគិតគូរអំពីបញ្ហាទេពកោសល្យផ្ទាល់ខ្លួនជាមូលដ្ឋាន ដែលវាត្រូវបានផ្សំឡើងពី ការពិនិត្យលើសមត្ថភាពតម្រូវការផ្ទាល់ខ្លួន និងគុណតម្លៃ ដើម្បីបន្ស៊ីស្ថានភាពបុគ្គលទៅនឹងពិភពអាជីពការងារដែលគេប្រាថ្នា។

*តារាង 12 ចរិតលក្ខណៈកត្តាទេពកោសល្យផ្ទាល់ខ្លួន (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ខ្ញុំជាមនុស្សមានឆន្ទៈក្នុងការដោះស្រាយបញ្ហាស្មុគស្មាញ និងបង្កើតជម្រើសនៃការសម្រេចចិត្តជាបន្តបន្ទាប់ | ៣.៥៥ | ០.៨៣ | ៨ |
| ២ | ខ្ញុំជាមនុស្សដែលចង់បានឋានៈជាអ្នកជំនាញការច្បាស់លាស់លើកិច្ចការដែលខ្ញុំធ្វើ ក្នុងក្រសែភ្នែកមិត្តរួមការងារ | ៣.៤២ | ០.៩៥ | ១០ |
| ៣ | ខ្ញុំជាមនុស្សដែលមើលឃើញពីឱកាសក្នុងការច្នៃប្រតិដ្ឋ និងកំណត់អំពីតម្រូវការនៃការចាប់ផ្តើមអាជីវកម្មថ្មី ឬសេវាកម្មថ្មីៗ | ៣.៥ | ០.៨៧ | ៩ |
| ៤ | ខ្ញុំជាមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារការកែតម្រូវកំហុសឆ្គង និងធ្វើការប្រកបដោយផលិតភាព | ៣.៥៩ | ០.៨៣ | ៧ |
| ៥ | ខ្ញុំមានតម្រូវការក្នុងការទទួលបានការងារធ្វើរយៈពេលវែង មានប្រព័ន្ធគាំពារច្បាស់ លាស់ និងមានជម្រើសសមរម្យក្នុងការចូលនិវត្តន៍ | ៣.៦២ | ០.៨២ | ៦ |
| ៦ | ខ្ញុំមានតម្រូវការផ្នែកសេរីភាពផ្ទាល់ខ្លួន ក្នុងការបំពេញការងារ | ៣.៨០ | ០.៧៧ | ៣ |
| ៧ | ខ្ញុំមានតម្រូវការផ្នែកតុល្យភាពរវាងសុខុមាលភាពផ្ទាល់ខ្លួន គ្រួសារ និងការប្តេជ្ញាចិត្តលើអាជីពការងារ | ៣.៧៦ | ០.៧៨ | ៤ |

| | | | | |
|---|---|---|---|---|
| ៨ | ខ្ញុំតែងសាកល្បងទទួលយកនូវការតស៊ូឆ្ពោះទៅមុន តាមរយៈគម្រោងប្រជុំប្រជុំប្រថានផ្សេងៗ ឬការងារដែលត្រូវប្រឈមមុខនឹងការលំបាកច្រើន | ៣.៦៥ | ០.៨៥ | ៥ |
| ៩ | ខ្ញុំពេញចិត្តនឹងការធ្វើការងារដើម្បីភាពលូតលាស់រីកចម្រើនរបស់ស្ថាប័ន និង សហគមន៍ | ៣.៩០ | ០.៧៦ | ១ |
| ១០ | ខ្ញុំពេញចិត្តក្នុងការស្វែងរកអត្ថន័យស៊ីជម្រៅ និងការបង្ហាញពីភាពច្នៃប្រតិដ្ឋ ផ្ទាល់ខ្លួនតាមរយៈការបំពេញការងារ | ៣.៨១ | ០.៧៨ | ២ |
| | **សរុប** | **៣.៦៦** | **០.៦១** | |

តាម *តារាង ១២* បង្ហាញថា កត្តាទេពកោសល្យផ្ទាល់ខ្លួន បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៦៦ និងគម្លាតស្តង់ដា ០.៦១។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមល្បះសំណួរទាំង ១០ នៃកត្តាទេពកោសល្យផ្ទាល់ខ្លួនខាងលើ ខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេលំដាប់ពី ១ ដល់ ៣ គឺ ល្បះសំណួរទី៩ ស្ថិតក្នុងកម្រិតខ្ពស់ជាងគេ *«ខ្ញុំពេញចិត្តនឹងការធ្វើការងារដើម្បីភាពលូតលាស់រីកចម្រើនរបស់ស្ថាប័ន និងសហគមន៍»* មានតម្លៃមធ្យម ៣.៩០ និងគម្លាតស្តង់ដា ០.៧៦ (ស្ថិតក្នុងកត្តារងៈ ផ្អែកលើគុណតម្លៃ)។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ គឺល្បះសំណួរទី១០ *«ខ្ញុំពេញចិត្តក្នុងការស្វែងរកអត្ថន័យស៊ីជម្រៅ និងការបង្ហាញពីភាពច្នៃប្រតិដ្ឋផ្ទាល់ខ្លួនតាមរយៈការបំពេញការងារ»* មានតម្លៃមធ្យម ៣.៨១ និងគម្លាតស្តង់ដា ០.៧៨ (ស្ថិតក្នុងកត្តារងៈ ផ្អែកលើគុណតម្លៃ)។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺល្បះសំណួរទី៦ *«ខ្ញុំមានតម្រូវការផ្អែកសេរីភាពផ្ទាល់ខ្លួន ក្នុងការបំពេញការងារ»* មានតម្លៃមធ្យម ៣.៨០ និងគម្លាតស្តង់ដា ០.៧៧ (ស្ថិតក្នុងកត្តារងៈ ផ្អែកលើតម្រូវការផ្ទាល់ខ្លួន)។ ដោយឡែក ខ្លឹមសារដែលមានតម្លៃទាបជាងគេបំផុត គឺល្បះសំណួរទី២ *«ខ្ញុំជាមនុស្សដែលចង់បានឋានៈជាអ្នកជំនាញការច្បាស់លាស់លើកិច្ចការដែលខ្ញុំធ្វើ ក្នុងក្រសែភ្នែកមិត្តរួមការងារ»* មានតម្លៃមធ្យម ៣.៤២ និង គម្លាតស្តង់ដា ០.៩៥ (ស្ថិតក្នុងកត្តារងៈ ផ្អែកលើទេពកោសល្យ)។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា ក្នុងចំណោមកត្តារងទាំង ៣ ក្នុងកត្តាទេពកោសល្យផ្ទាល់ខ្លួន គឺកត្តារង *«ផ្អែកលើគុណតម្លៃ»* និង *«ផ្អែកលើតម្រូវផ្ទាល់ខ្លួន»* បានដើរតួនាទីដ៏សំខាន់ក្នុងជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ខណៈកត្តារង *«ផ្អែកលើទេពកោសល្យ»* ហាក់ដូចជាបានចូលរួមចំណែកតិចតួចដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា។

### ឃ.កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន

អត្តសញ្ញាណបុគ្គល ជាផ្នែកមួយនៃការចង្អុលបង្ហាញឱ្យឃើញពីស្ថិរភាព និងការអភិវឌ្ឍនៅក្នុងស្ថាប័នការងារមួយ។ វាត្រូវបានផ្សារភ្ជាប់ទៅនឹងជម្រើសអាជីពចាប់តាំងពីពេលដែលបុគ្គលម្នាក់មានការគិតគូរពិចារណាច្បាស់លាស់។ អត្តសញ្ញាណបុគ្គល ក៏ត្រូវបានផ្សារភ្ជាប់ទៅនឹងអត្តសញ្ញាណវិជ្ជាជីវៈ ដែលវាបានប្រាកដឡើងកាន់តែច្បាស់នូវរូបភាពការងារ ស្ថិរភាព អារម្មណ៍វិជ្ជមាន និងវប្បធម៌នៃការបំពេញការងាររបស់បុគ្គល។ ការណ៍នេះ បានផ្ដល់នូវវិភាគទានដ៏សំខាន់សម្រាប់បុគ្គលម្នាក់ៗធ្វើការសម្រេចចិត្តជ្រើសរើសអាជីពការងារនាពេលអនាគត ដើម្បីឱ្យឆ្លើយតបទៅនឹងអ្វីដែលជាអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេ។ ក្នុងន័យនេះ នៅពេលដែលបុគ្គលម្នាក់ជ្រើសរើសអាជីពការងារ គេតែងផ្សារភ្ជាប់ទិដ្ឋភាពបរិយាកាសការងារនោះទៅនឹងចំណាប់អារម្មណ៍ ការទទួលស្គាល់ ការអនុវត្ត សមត្ថភាព ភេទ និងការយល់ឃើញផ្ទាល់ខ្លួន។

*តារាង 13 ចរិតលក្ខណៈកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន (n=១ ៥២០)*

| ល.រ | បរិយាយកត្តាជះឥទ្ធិពលលើជម្រើសអាជីព | តម្លៃមធ្យម | គម្លាតស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ខ្ញុំបានធ្វើបញ្ជីរាយមុខជំនាញ និងអាជីពការងារទាំងឡាយដែលខ្ញុំចាប់អារម្មណ៍ | ៣.៥៩ | ០.៨៤ | ៨ |
| ២ | អាជីពដែលខ្ញុំជ្រើសរើស នឹងសក្តិសមទៅនឹងចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ហើយខ្ញុំនឹងធ្វើដោយក្តីរីករាយពេញចិត្ត | ៤.០០ | ០.៧៣ | ១ |
| ៣ | មនុស្សជាច្រើនយល់ថា ខ្ញុំសក្តិសមនឹងធ្វើការក្នុងអាជីពការងារដែលខ្ញុំជ្រើសរើស | ៣.៦២ | ០.៨១ | ៥ |

| | | | | |
|---|---|---|---|---|
| ៤ | មនុស្សជាច្រើនយល់ថា ខ្ញុំជាមនុស្សពោរពេញដោយការសហការក្រុម មានការទទួលខុសត្រូវខ្ពស់ និងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីសម្រេចជោគជ័យ | ៣.៦៨ | ០.៧៨ | ៣ |
| ៥ | ខ្ញុំអាចធ្វើការជាមួយមនុស្សដែលមានចរឹតលក្ខណៈ និងការយល់ឃើញខុសៗគ្នា | ៣.៦២ | ០.៨៤ | ៥ |
| ៦ | ខ្ញុំអាចសម្របខ្លួនទៅនឹងការប្រឈមថ្មីៗ អាស្រ័យលើតួនាទីការទទួលខុសត្រូវ បរិបទ ស្ថានភាព និងបរិយាកាសនៅកន្លែងការងារបានល្អ | ៣.៨៤ | ០.៧២ | ២ |
| ៧ | ខ្ញុំមានការយល់ដឹងពីច្បាប់ទម្លាប់ អន្តរកម្មរបស់មិត្តរួមការងារ ស្ថានភាពសេដ្ឋកិច្ច ផ្ទៃក្នុង និងបរិស្ថាននៅកន្លែងធ្វើការ | ៣.៦៤ | ០.៧៦ | ៤ |
| ៨ | ខ្ញុំមានលទ្ធភាពអាចប្រើប្រាស់ឧបករណ៍ សម្ភារៈបច្ចេកវិទ្យាដែលពាក់ព័ន្ធទៅនឹងការបំពេញការងារមានប្រសិទ្ធភាព | ៣.៥៨ | ០.៨៣ | ៩ |
| ៩ | ខ្ញុំយល់ថា សិស្សប្រុសមានមហិច្ឆតាអាជីព ខ្ពស់ជាងសិស្សស្រី | ២.៩៥ | ១.១៥ | ១២ |
| ១០ | ខ្ញុំយល់ថា អាជីពការងារខ្លះមានភាពសក្តិសមទៅនឹងមនុស្សប្រុសជាង ខណៈអាជីពខ្លះ សក្តិសមទៅនឹងមនុស្សស្រីជាង | ៣.២២ | ១.០៥ | ១១ |
| ១១ | ខ្ញុំអាចទទួលយក និងធ្វើការងារជាមួយអ្នកដែលមានការអប់រំខុសគ្នា វប្បធម៌នៃការ រស់នៅខុសគ្នា | ៣.៦២ | ០.៨២ | ៥ |
| ១២ | ខ្ញុំអាចយល់ដឹងពីអារម្មណ៍ តម្រូវការ ការគិត ចំណាប់អារម្មណ៍ និងចំណូលចិត្ត របស់អ្នកដទៃ | ៣.៥៨ | ០.៨២ | ៩ |
| | **សរុប** | **៣.៥៨** | **០.៥៧** | |

តាម *តារាង ១៣* បង្ហាញថា កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន បានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យជារួមក្នុងកម្រិតខ្ពស់ ដែលមានតម្លៃមធ្យម ៣.៥៨ និងគម្លាតស្តង់ដា ០.៥៧។ បើរៀងតាមលំដាប់តម្លៃមធ្យមក្នុងចំណោមល្បះសំណួរទាំង ១០ នៃកត្តាអត្តសញ្ញាណផ្ទាល់ខ្លួនខាងលើ ខ្លឹមសារដែលមានតម្លៃខ្ពស់ជាងគេលំដាប់ពី ១ ដល់ ៣ គឺ ល្បះសំណួរទី២ ស្ថិតក្នុងកម្រិតខ្ពស់ជាងគេ *«អាជីពដែលខ្ញុំ*

*ជ្រើសរើសនឹងសក្តិសមទៅនឹងចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ហើយខ្ញុំនឹងធ្វើដោយក្តីរីករាយពេញចិត្ត»* មានតម្លៃមធ្យម ៤.០០ និងគម្លាតស្តង់ដា ០.៧៣ (ស្ថិតក្នុងកត្តារង៖ ចំណាប់អារម្មណ៍)។ ខ្លឹមសារដែលមានតម្លៃខ្ពស់បន្ទាប់លំដាប់ទី២ គឺល្បះសំណួរទី៦ *«ខ្ញុំអាចសម្របខ្លួនទៅនឹងការប្រឈមថ្មីៗ អាស្រ័យលើតួនាទី ការទទួលខុសត្រូវ បរិបទ ស្ថានភាព និងបរិយាកាសនៅកន្លែងការងារបានល្អ»* មានតម្លៃមធ្យម ៣.៨៤ និងគម្លាតស្តង់ដា ០.៧២ (ស្ថិតក្នុងកត្តារង៖ ការអនុវត្ត)។ ខ្លឹមសារដែលមានតម្លៃខ្ពស់លំដាប់ទី៣ គឺល្បះសំណួរទី៤ *«មនុស្សជាច្រើនយល់ថា ខ្ញុំជាមនុស្សពោរពេញដោយការសហការក្រុម មានការទទួលខុសត្រូវខ្ពស់ និងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីសម្រេចជោគជ័យ»* មានតម្លៃមធ្យម ៣.៦៨ និងគម្លាតស្តង់ដា ០.៧៨ (ស្ថិតក្នុងកត្តារង៖ សមត្ថភាព)។ ដោយឡែក ខ្លឹមសារដែលមានតម្លៃទាបជាងគេបំផុត គឺល្បះសំណួរទី៩ *«ខ្ញុំយល់ថា សិស្សប្រុសមានមហិច្ឆតាអាជីពខ្ពស់ជាងសិស្សស្រី»* មានតម្លៃមធ្យម ២.៩៥ និងគម្លាតស្តង់ដា ១.១៥ (ស្ថិតក្នុងកត្តារង៖ ភេទ)។

តាមរយៈការបកស្រាយលទ្ធផលខាងលើ យើងអាចទាញសន្និដ្ឋានបានថា ក្នុងចំណោមកត្តារងទាំង ៦ ក្នុងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន គឺកត្តារង *«ចំណាប់អារម្មណ៍»*, *«ការអនុវត្ត»* និង *«សមត្ថភាព»* បានដើរតួនាទីដ៏សំខាន់ក្នុងជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ខណៈកត្តារង *«ភេទ»* ហាក់ដូចជាបានចូលរួមចំណែកតិចតួចដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ នៅកម្ពុជា។

### ៤.២.២. សំណួរស្រាវជ្រាវទី២៖ ភាពខុសគ្នានៃកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ដោយផ្អែកលើភេទ និងប្រភេទមុខរបរឪពុកម្តាយ

ក្នុងផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបកស្រាយអំពីភាពខុសគ្នានៃកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ដោយសិក្សាពីអថេរភេទរបស់សិស្ស និងកត្តាខាងក្រៅ (កត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច) ព្រមទាំងសិក្សាពីអថេរភេទរបស់សិស្ស និងកត្តាខាងក្នុង (កត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន)។ ការវិភាគដោយប្រើស្ថិតិពណ៌នា (Descriptive Statistics) ) និងស្ថិតិសន្និដ្ឋាន (Inferential

Statistics) លើទិន្នន័យដែលប្រមូលបានតាមរយៈកម្រងសំណួរផ្នែកទី២ ចំនួន ៨០ ឈ្នះសំណួរ ត្រូវបានបង្ហាញតាមតារាងនីមួយៗដូចខាងក្រោម៖

#### ៤.២.២.១. កត្តាខាងក្រៅ

**កត្តាខាងក្រៅ** ត្រូវបានសាងឡើងដោយកត្តាតូចៗចំនួន ៤ ជាអាទិ៍៖ កត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច។

*តារាង 14 ភាពខុសគ្នានៃកត្តាខាងក្រៅ ផ្អែកលើភេទរបស់សិស្ស (n=១៥២០)*

| ភេទ | | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | កត្តាគ្រួសារ | ៣.៧២ | ០.៦៣ | ៣.៧១ | ០.៥៤ | ០.២៨ | ០.៧៧ |
| ២ | កត្តាសាលារៀន | ៣.៧៥ | ០.៦៩ | ៣.៨០ | ០.៥២ | -១.៥២ | ០.១២ |
| ៣ | កត្តាព័ត៌មានទីផ្សារការងារ | ៣.៧០ | ០.៦៤ | ៣.៦៥ | ០.៥០ | ១.៩១ | ០.០៦ |
| ៤ | កត្តាសង្គម-សេដ្ឋកិច្ច | ៣.៨៦ | ០.៦៩ | ៣.៩១ | ០.៥៣ | -១.៥៥ | ០.១១ |

P>0.0៥

តាមតារាង *១៤* ខាងលើបង្ហាញថា កត្តាខាងក្រៅបានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ដោយមិនមានភាពខុសគ្នាទាក់ទងនឹងបញ្ហាភេទរបស់សិស្សនោះទេ, P>0.0៥។

*តារាង 15 ភាពខុសគ្នានៃកត្តាខាងក្រៅ ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាខាងក្រៅ | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ២.៩២២ | ០.៥៨៤ | ២.៥៦១* | ០.០៣ |
| ខាងក្នុងក្រុម | ១៥១៤ | ៣៤៥.៤២៣ | ០.២២៨ | | |
| សរុប | ១៥១៩ | ៣៤៨.៣៤៤ | | | |

P<0.0៥

តាមតារាង *១៥* ខាងលើបង្ហាញថា មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត ០.០៣, P<0.0៥ ទាក់ទងកត្តាខាងក្រៅជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងប្រភេទមុខរបរឪពុកម្តាយ។ ករណីនេះ ការវិភាគ Multiple Comparisons ត្រូវបានធ្វើឡើងជាបន្ត ដើម្បីរកឱ្យឃើញថាតម្លៃមធ្យមណាមួយទាបជាង ឬខ្ពស់ជាង។

*តារាង 16 ការលម្អិតពីភាពខុសគ្នានៃកត្តាខាងក្រៅ ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាខាងក្រៅ | MD | S.E | p-value |
|---|---|---|---|
| **មន្ត្រីរាជការ** | | | |
| ស្ថាប័នឯកជន | ០.២០៦* | ០.០៦៣ | ០.០២ |
| ស្ថាប័នសង្គមស៊ីវិល | ០.១៦២ | ០.១៥៤ | ១.០០ |
| អាជីវករ | ០.០៧៥ | ០.០៤៤ | ១.០០ |
| កសិករ | ០.០៣១ | ០.០៣៤ | ១.០០ |
| ផ្សេងៗ | ០.០៣៥ | ០.១០៤ | ១.០០ |
| **ស្ថាប័នឯកជន** | | | |
| ស្ថាប័នសង្គមស៊ីវិល | -០.០៤៤ | ០.១៦១ | ១.០០ |
| អាជីវករ | -០.១៣១ | ០.០៦៤ | ០.៦១ |
| កសិករ | -០.១៧៥* | ០.០៥៧ | ០.០៤ |
| ផ្សេងៗ | -០.១៧០ | ០.១១៤ | ១.០០ |
| **ស្ថាប័នសង្គមស៊ីវិល** | | | |
| អាជីវករ | -០.០៨៧ | ០.១៥៤ | ១.០០ |
| កសិករ | -០.១៣១ | ០.១៥១ | ១.០០ |

| | | | |
|---|---|---|---|
| ផ្សេងៗ | -០.១២៧ | ០.១៨០ | ១.០០ |
| **អាជីវករ** | | | |
| កសិករ | -០.០៤៤ | ០.០៣៥ | ១.០០ |
| ផ្សេងៗ | -០.០៣៩ | ០.១០៤ | ១.០០ |
| **កសិករ** | | | |
| ផ្សេងៗ | ០.០០៥ | ០.១០០ | ១.០០ |

P<០.០៥

តារាង *១៦* ខាងលើបង្ហាញថា មានភាពខុសគ្នាផ្នែកស្ថិតិរវាងការគិតរបស់សិស្សដែលមានឪពុកម្តាយប្រកបមុខរបរជាមន្ត្រីរាជការ អ្នកធ្វើការក្នុងស្ថាប័នឯកជន និងកសិករ, *F* (៥,១៥១៤)=២.៥៦, P<០.០៥។ ការវិភាគ Multiple Comparisons ដោយប្រើ Bonferroni Post Hoc បង្ហាញថា សិស្សដែលរស់នៅក្នុងគ្រួសារមានឪពុកម្តាយធ្វើការងារក្នុងស្ថាប័នឯកជន ទទួលឥទ្ធិពលពីកត្តាខាងក្រៅ លើជម្រើសអាជីពរបស់ខ្លួន ជាងសិស្សដែលមានឪពុកម្តាយធ្វើការជាមន្ត្រីរាជការ។ ជាមួយគ្នានេះ សិស្សដែលមានឪពុកម្តាយធ្វើការងារជាកសិករ ក៏ទទួលឥទ្ធិពលពីកត្តាខាងក្រៅលើជម្រើសអាជីពរបស់ខ្លួន ជាងសិស្សដែលមានឪពុកម្តាយធ្វើការងារក្នុងស្ថាប័នឯកជន។ លទ្ធផលវិភាគផ្នែកស្ថិតិនេះ ក៏បានបង្ហាញផងដែរ ថាសិស្សដែលមានឪពុកម្តាយធ្វើការជាមន្ត្រីរាជការ ជាបុគ្គលិកអង្គការសង្គមស៊ីវិល ជាអាជីវករ និងប្រភេទមុខរបរផ្សេងទៀតនោះ ទទួលឥទ្ធិពលពីកត្តាខាងក្រៅលើជម្រើសអាជីពរបស់ខ្លួនមិនខុសគ្នាទេ។

### ក.កត្តាគ្រួសារ

**កត្តាគ្រួសារ** ត្រូវបានសាងឡើងដោយកត្តារងចំនួន ៥ ដូចជា៖ ការគាំទ្រផ្លូវអារម្មណ៍ ការរំពឹងទុករបស់គ្រួសារ ការគាំទ្រផ្នែកហិរញ្ញវត្ថុ ការគាំទ្រផ្នែកព័ត៌មាន និងការផ្តល់ភាពជាគំរូ។

*តារាង 17 ភាពខុសគ្នានៃកត្តាគ្រួសារ ផ្អែកលើភេទរបស់សិស្ស (n=១៥២០)*

| ភេទ | | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | ការគាំទ្រផ្លូវអារម្មណ៍ | ៤.១១ | ០.៧៤ | ៤.១៣ | ០.៦៥ | -០.៥៩ | ០.៥៥ |
| ២ | ការរំពឹងទុករបស់គ្រួសារ | ៣.៧៤ | ០.៧៩ | ៣.៧២ | ០.៧៤ | ០.៤៦ | ០.៦៤ |
| ៣ | ការគាំទ្រផ្នែកហិរញ្ញវត្ថុ | ៣.៤៥ | ០.៨៦ | ៣.៤១ | ០.៧៨ | ០.៩៧ | ០.៣៣ |
| ៤ | ការគាំទ្រផ្នែកព័ត៌មាន | ៣.៨១ | ០.៧៩ | ៣.៨១ | ០.៧៣ | ០.០៨ | ០.៩៣ |
| ៥ | ការផ្តល់ភាពជាគំរូ | ៣.៤៨ | ០.៩០ | ៣.៤៨ | ០.៨៥ | ០.០២ | ០.៩៧ |

P>0.0៥

តាមតារាង *១៧* ខាងលើបង្ហាញថា ចំពោះការប្រៀបធៀបរវាង ការជះឥទ្ធិពលរបស់គ្រួសារលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា និងបញ្ហាភេទរបស់សិស្ស មិនមានភាពខុសគ្នាផ្នែកស្ថិតិនោះទេ, P>0.0៥។

*តារាង 18 ភាពខុសគ្នានៃកត្តាគ្រួសារ ផ្អែកលើស្ថានភាពប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាគ្រួសារ | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ៧.០៣១ | ១.៤០៦ | ៤.១៦៧* | 0.00 |
| ខាងក្នុងក្រុម | ១៥១៤ | ៥១០.៨៤៥ | ០.៣៣៧ | | |
| សរុប | ១៥១៩ | ៥១៧.៨៧៥ | | | |

P<0.0៥

តាមតារាង *១៨* ខាងលើបង្ហាញថា មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.00, P<0.0៥ ទាក់ទងនឹងកត្តាគ្រួសារបានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងប្រភេទ

មុខរបរឪពុកម្តាយ។ ករណីនេះ ការវិភាគ Multiple Comparisons ត្រូវបានធ្វើឡើងជាបន្ត ដើម្បីរកឱ្យឃើញថាតម្លៃមធ្យមណាមួយទាបជាង ឬខ្ពស់ជាង។

*តារាង 19 ការលម្អិតពីភាពខុសគ្នានៃកត្តាគ្រួសារ ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាគ្រួសារ | MD | S.E | p-value |
|---|---|---|---|
| **មន្ត្រីរាជការ** | | | |
| ស្ថាប័នឯកជន | ០.២៩០* | ០.០៧៧ | ០.០០ |
| ស្ថាប័នសង្គមស៊ីវិល | ០.២៩៦ | ០.១៨៧ | ១.០០ |
| អាជីវករ | ០.១៦០* | ០.០៥៤ | ០.០៤ |
| កសិករ | ០.១៥៧* | ០.០៤២ | ០.០០ |
| ផ្សេងៗ | ០.០៨២ | ០.១២៦ | ១.០០ |
| **ស្ថាប័នឯកជន** | | | |
| ស្ថាប័នសង្គមស៊ីវិល | ០.០០៦ | ០.១៩៥ | ១.០០ |
| អាជីវករ | -០.១២៩ | ០.០៧៧ | ១.០០ |
| កសិករ | -០.១៣២ | ០.០៧០ | ០.៨៧ |
| ផ្សេងៗ | -០.២០៧ | ០.១៣៨ | ១.០០ |
| **ស្ថាប័នសង្គមស៊ីវិល** | | | |
| អាជីវករ | -០.១៣៥ | ០.១៨៧ | ១.០០ |
| កសិករ | -០.១៣៨ | ០.១៨៤ | ១.០០ |
| ផ្សេងៗ | -០.២១៣ | ០.២២០ | ១.០០ |
| **អាជីវករ** | | | |

| | | | |
|---|---|---|---|
| កសិករ | -0.00៣ | 0.0៤៣ | ១.00 |
| ផ្សេងៗ | -0.0៧៧ | 0.១២៧ | ១.00 |
| **កសិករ** | | | |
| ផ្សេងៗ | -0.0៧៤ | 0.១២២ | ១.00 |

P<0.0៥

តារាង *១៩* ខាងលើបង្ហាញថា មានភាពខុសគ្នាផ្នែកស្ថិតិរវាងការគិតរបស់សិស្សដែលមានឪពុកម្តាយប្រកបមុខរបរជាមន្ត្រីរាជការ អ្នកធ្វើការក្នុងស្ថាប័នឯកជន និងអាជីវករ, *F* (៥,១៥១៤)=៤.១៧, P<0.0៥។ ការវិភាគ Multiple Comparisons ដោយប្រើ Bonferroni Post Hoc បង្ហាញថា សិស្សដែលរស់នៅក្នុងគ្រួសារមានឪពុកម្តាយធ្វើការងារក្នុងស្ថាប័នឯកជន ឪពុកម្តាយជាអាជីវករ និងជាកសិករ ទទួលឥទ្ធិពលពីគ្រួសារលើការសម្រេចចិត្តជ្រើសរើសអាជីព ជាងសិស្សដែលមានឪពុកម្តាយធ្វើការងារជាមន្ត្រីរាជការ។ លទ្ធផលវិភាគផ្នែកស្ថិតិនេះ ក៏បានបង្ហាញផងដែរថា សិស្សដែលមានឪពុកម្តាយធ្វើការជាមន្ត្រីរាជការ ជាបុគ្គលិកអង្គការសង្គមស៊ីវិល និងប្រភេទមុខរបរផ្សេងទៀតនោះ ទទួលឥទ្ធិពលពីគ្រួសារលើជម្រើសអាជីពរបស់ខ្លួនមិនខុសគ្នាទេ។

### ខ.កត្តាសាលារៀន

**កត្តាសាលារៀន** ត្រូវបានសាងឡើងដោយកត្តារងចំនួន ៦ ដូចជា៖ ការគាំទ្ររបស់គ្រូបង្រៀន ការគាំទ្ររបស់មិត្តភក្តិ លទ្ធផលសិក្សារបស់សិស្ស ការទទួលសេវាប្រឹក្សាអាជីព ការគាំទ្រផ្នែកសម្ភារៈរៀននិងបង្រៀន និងការផ្តល់ភាពជាគំរូ។

*តារាង 20 ភាពខុសគ្នានៃកត្តាសាលារៀន ផ្អែកលើភេទរបស់សិស្ស (n=១៥២០)*

| | ភេទ | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | ការគាំទ្ររបស់គ្រូបង្រៀន | ៣.៦០ | 0.៨១ | ៣.៦០ | 0.៧៤ | 0.១៨ | 0.៨៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ការគាំទ្ររបស់មិត្តភក្តិ | ៣.៦៧ | 0.៨៩ | ៣.៧៧ | 0.៧១ | -២.៤៦* | 0.0១ |
| ៣ | លទ្ធផលនៃការសិក្សារបស់សិស្ស | ៣.៨៣ | 0.៨៣ | ៣.៨៤ | 0.៧0 | -0.៣៨ | 0.៦៩ |
| ៤ | ការផ្តល់សេវាប្រឹក្សាអាជីព | ៣.៧៩ | 0.៨៣ | ៣.៨៤ | 0.៦៧ | -១.២៧ | 0.២0 |
| ៥ | ការគាំទ្រផ្នែកសម្ភារៈរៀននិងបង្រៀន | ៣.៧៦ | 0.៩0 | ៣.៨៧ | 0.៧៦ | -២.៥៧* | 0.0១ |
| ៦ | ការផ្តល់ភាពជាគំរូ | ៣.៨៦ | 0.៧៧ | ៣.៨៨ | 0.៦៥ | -0.៤៥ | 0.៦៤ |

P<0.0៥

តាមតារាង *២0* ខាងលើបង្ហាញពីការប្រៀបធៀបកត្តាសាលារៀន ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ដោយផ្អែកលើភេទរបស់សិស្ស។ លទ្ធផលវិភាគ T-Test បានបង្ហាញថា កត្តារង *ការគាំទ្ររបស់មិត្តភក្តិ* និង *ការគាំទ្រផ្នែកសម្ភារៈរៀននិងបង្រៀន* មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.0១, P<0.0៥។ លទ្ធផលនេះក៏បង្ហាញដែរថា កត្តារងផ្សេងទៀតដែលមានក្នុងកត្តាសាលារៀន មិនមានភាពខុសគ្នានោះទេ បើធៀបនឹងបញ្ហាភេទរបស់សិស្ស។

*តារាង 21 ភាពខុសគ្នានៃកត្តាសាលារៀន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២0)*

| កត្តាសាលារៀន | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ៧.២២៤ | ១.៤៤៥ | ៤.0២៥* | 0.00 |
| ខាងក្នុងក្រុម | ១៥១៤ | ៥៤៣.៣៨៩ | 0.៣៥៩ | | |
| សរុប | ១៥១៩ | ៥៥0.៦១២ | | | |

P<0.0៥

តាមតារាង *២១* ខាងលើបង្ហាញថា មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.00, P<0.0៥ ទាក់ទងនឹងកត្តាសាលារៀនបានជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹង

ប្រភេទមុខរបរឪពុកម្តាយ។ ករណីនេះ ការវិភាគ Multiple Comparisons ត្រូវបានធ្វើឡើងជាបន្ត ដើម្បីរកឱ្យឃើញថាតម្លៃមធ្យមណាមួយទាបជាង ឬខ្ពស់ជាង។

*តារាង 22 ការលម្អិតពីភាពខុសគ្នានៃកត្តាសាលារៀន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាសាលារៀន | MD | S.E | p-value |
|---|---|---|---|
| **មន្ត្រីរាជការ** | | | |
| ស្ថាប័នឯកជន | 0.១៨៤ | 0.0៧៩ | 0.៣១ |
| ស្ថាប័នសង្គមស៊ីវិល | -0.១0៤ | 0.១៩៣ | ១.00 |
| អាជីវករ | 0.0១៨ | 0.0៥៥ | ១.00 |
| កសិករ | -0.0៨៩ | 0.0៤៣ | 0.៦0 |
| ផ្សេងៗ | -0.0៩៩ | 0.១៣0 | ១.00 |
| **ស្ថាប័នឯកជន** | | | |
| ស្ថាប័នសង្គមស៊ីវិល | -0.២៨៨ | 0.២0១ | ១.00 |
| អាជីវករ | -0.១៦៥ | 0.0៨0 | 0.៥៩ |
| កសិករ | -0.២៧៣ | 0.0៧២ * | 0.00 |
| ផ្សេងៗ | -0.២៨៤ | 0.១៤៣ | 0.៧១ |
| **ស្ថាប័នសង្គមស៊ីវិល** | | | |
| អាជីវករ | 0.១២២ | 0.១៩៣ | ១.00 |
| កសិករ | 0.0១៥ | 0.១៩0 | ១.00 |
| ផ្សេងៗ | 0.00៤ | 0.២២៦ | ១.00 |
| **អាជីវករ** | | | |

| | | | |
|---|---|---|---|
| កសិករ | -០.១០៧ | ០.០៥៤ | ០.២៥ |
| ផ្សេងៗ | -០.១១៨ | ០.១៣១ | ១.០០ |
| **កសិករ** | | | |
| ផ្សេងៗ | -០.០១០ | ០.១២៦ | ១.០០ |

P<0.0៥

តារាង *២២* ខាងលើបង្ហាញថា មានភាពខុសគ្នាផ្នែកស្ថិតិរវាងការគិតរបស់សិស្សដែលមានឪពុកម្ដាយប្រកបមុខរបរជាមន្ត្រីរាជការ អ្នកធ្វើការក្នុងស្ថាប័នឯកជន និងអាជីវករ, *F* (៥,១៥១៤)=៤.០៣, P<0.0៥។ ការវិភាគ Multiple Comparisons ដោយប្រើ Bonferroni Post Hoc បង្ហាញថា សិស្សដែលរស់នៅក្នុងគ្រួសាមានឪពុកម្ដាយធ្វើការជាកសិករ ទទួលឥទ្ធិពលពីសាលារៀនលើការសម្រេចចិត្តជ្រើសរើសអាជីព ជាងសិស្សដែលមានឪពុកម្ដាយធ្វើការងារក្នុងស្ថាប័នឯកជន។ លទ្ធផលវិភាគនេះ ក៏បានបង្ហាញដែរថា សិស្សដែលមានឪពុកម្ដាយធ្វើការជាមន្ត្រីរាជការ ជាបុគ្គលិកក្នុងស្ថាប័នឯកជន ជាបុគ្គលិកក្នុងអង្គការសង្គមស៊ីវិល ជាអាជីវករ និងប្រកបមុខរបរផ្សេងទៀត ទទួលឥទ្ធិពលពីសាលារៀនលើជម្រើសអាជីពរបស់ខ្លួនមិនខុសគ្នាទេ។

### គ.កត្តាព័ត៌មានទីផ្សារការងារ

**កត្តាព័ត៌មានទីផ្សារការងារ** ត្រូវបានសាងឡើងដោយកត្តារងចំនួន ៥ ដូចជា៖ ទីកន្លែងបំពេញការងារ តំណែងតួនាទី ប្រាក់កម្រៃនិងអត្ថប្រយោជន៍ លក្ខខណ្ឌការងារ និងលទ្ធភាពទទួលបានការងារ។

*តារាង 23 ភាពខុសគ្នានៃកត្តាព័ត៌មានទីផ្សារការងារ ផ្អែកលើភេទរបស់សិស្ស (n=១៥២០)*

| | ភេទ | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | ទីកន្លែងបំពេញការងារ | ៣.៨០ | ០.៨២ | ៣.៧៩ | ០.៦៦ | ០.២២ | ០.៨១ |
| ២ | តំណែងតួនាទី | ៣.៥០ | ០.៨៧ | ៣.៣៩ | ០.៧៨ | ២.៤៥* | ០.0១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ប្រាក់កម្រៃនិងអត្ថប្រយោជន៍ | ៣.៦៧ | ០.៨២ | ៣.៥៣ | ០.៧៣ | ៣.៤៦* | ០.០០ |
| ៤ | លក្ខខណ្ឌការងារ | ៣.៩២ | ០.៦៨ | ៣.៩៧ | ០.៥៦ | -១.៤១ | ០.១៥ |
| ៥ | លទ្ធភាពទទួលបានការងារ | ៣.៦២ | ០.៧៨ | ៣.៥៥ | ០.៦៧ | ១.៩៥ | ០.០៥ |

P<0.0៥

តាមតារាង *២៣* ខាងលើបង្ហាញពីការប្រៀបធៀបកត្តាព័ត៌មានទីផ្សារការងារ ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ដោយផ្អែកលើភេទរបស់សិស្ស។ លទ្ធផលវិភាគ T-Test បានបង្ហាញថា កត្តារង *ប្រាក់កម្រៃនិងអត្ថប្រយោជន៍* និង *តំណែងតួនាទី* មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.00 និង ០.0១, P<0.0៥។ លទ្ធផលនេះក៏បង្ហាញដែរថា កត្តារងផ្សេងទៀតដែលមានក្នុងកត្តាព័ត៌មានទីផ្សារការងារ មិនមានភាពខុសគ្នានោះទេ បើធៀបនឹងបញ្ហាភេទរបស់សិស្ស។

*តារាង 24 ភាពខុសគ្នានៃកត្តាព័ត៌មានទីផ្សារការងារ ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| **កត្តាព័ត៌មានទីផ្សារការងារ** | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ២.៥១១ | ០.៥០២ | ១.៥៦១ | ០.១៧ |
| ខាងក្នុងក្រុម | ១៥១៤ | ៤៨៧.០១៨ | ០.៣២២ | | |
| សរុប | ១៥១៩ | ៤៨៩.៥៣០ | | | |

P>0.05

តាមតារាង *២៤* ខាងលើបង្ហាញថា មិនមានភាពខុសគ្នាផ្នែកស្ថិតិទេ រវាងឥទ្ធិពលនៃព័ត៌មានទីផ្សារការងារលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងស្ថានភាពប្រភេទមុខរបរឪពុកម្តាយ *F*(៥,១៥១៤)=១.៥៦, P>0.0៥។

### ឃ.កត្តាសង្គម-សេដ្ឋកិច្ច

**កត្តាសង្គម-សេដ្ឋកិច្ច** ត្រូវបានសាងឡើងដោយកត្តារងចំនួន ៣ ដូចជា៖ ឋានៈសង្គម ការវិវត្តផ្នែកសេដ្ឋកិច្ច និងគុណតម្លៃសង្គម។

*តារាង 25 ភាពខុសគ្នានៃកត្តាសង្គម-សេដ្ឋកិច្ច ផ្អែកលើភេទរបស់សិស្ស (n=១៥២០)*

| | ភេទ | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | ឋានៈសង្គម | ៤.០០ | ០.៨០ | ៤.០៧ | ០.៦៤ | -១.៨០ | ០.០៧ |
| ២ | ស្ថានភាពវិវត្តផ្នែកសេដ្ឋកិច្ច | ៣.៧០ | ០.៧៦ | ៣.៧៣ | ០.៦៦ | -០.៩០ | ០.៣៦ |
| ៣ | គុណតម្លៃសង្គម | ៣.៨៩ | ០.៧៨ | ៣.៩៤ | ០.៦៣ | -១.២៨ | ០.១៩ |

P>0.0៥

តាមតារាង *២៥* ខាងលើបង្ហាញថា ចំពោះការប្រៀបធៀបរវាងការជះឥទ្ធិពលរបស់កត្តាសង្គម-សេដ្ឋកិច្ចលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា និងបញ្ហាភេទរបស់សិស្ស មិនមានភាពខុសគ្នាផ្នែកស្ថិតិនោះទេ, P>0.0៥។

*តារាង 26 ភាពខុសគ្នានៃកត្តាសេដ្ឋកិច្ច-សង្គម ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាសង្គម-សេដ្ឋកិច្ច | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ៣.២៥៧ | ០.៦៥១ | ១.៧៦៦ | ០.១២ |
| ខាងក្នុងក្រុម | ១៥១៤ | ៥៥៨.៤៧៨ | ០.៣៦៩ | | |
| សរុប | ១៥១៩ | ៥៦១.៧៣៥ | | | |

P>0.05

តាមតារាង *២៦* ខាងលើបង្ហាញថា មិនមានភាពខុសគ្នាផ្នែកស្ថិតិទេ រវាងឥទ្ធិពលនៃសង្គម-សេដ្ឋកិច្ចលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងស្ថានភាពប្រភេទមុខរបរឪពុកម្តាយ *F*(៥,១៥១៤)=១.៧៧, P>0.0៥។

### ៤.២.២.២. កត្តាខាងក្នុង

**កត្តាខាងក្នុង** ត្រូវបានសាងឡើងដោយកត្តាតូចៗចំនួន ៤ ជាអាទិ៍៖ កត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន។

*តារាង 27 ភាពខុសគ្នានៃកត្តាខាងក្នុង ផ្អែកលើភេទរបស់សិស្ស (n=១៥២០)*

| ភេទ | | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | កត្តាភាពជឿជាក់លើខ្លួនឯង | ៣.៨០ | ០.៦១ | ៣.៨២ | ០.៤៧ | -០.៨៨ | ០.៣៨ |
| ២ | កត្តាលទ្ធផលរំពឹងទុក | ៣.៨២ | ០.៦៤ | ៣.៨៤ | ០.៥០ | -០.៦២ | ០.៥៣ |
| ៣ | កត្តាទេពកោសល្យផ្ទាល់ខ្លួន | ៣.៦៨ | ០.៦៧ | ៣.៦៥ | ០.៥៦ | ០.៨៥ | ០.៣៩ |
| ៤ | កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន | ៣.៦៥ | ០.៦២ | ៣.៥៣ | ០.៥១ | ៤.១៦ * | 0.00 |

P<0.0៥

តាមតារាង *២៧* ខាងលើបង្ហាញពីការប្រៀបធៀបកត្តាខាងក្នុង ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ដោយផ្អែកលើភេទរបស់សិស្ស។ លទ្ធផលវិភាគ T-Test បានបង្ហាញថា កត្តាតូច *អត្តសញ្ញាណផ្ទាល់ខ្លួន* មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.00, P<0.0៥។ លទ្ធផលនេះក៏បង្ហាញដែរថា កត្តាតូចៗផ្សេងទៀតដែលមានក្នុងកត្តាខាងក្នុង មិនមានភាពខុសគ្នានោះទេ បើធៀបនឹងបញ្ហាភេទរបស់សិស្ស។

*តារាង 28 ភាពខុសគ្នានៃកត្តាខាងក្នុង ផ្អែកលើប្រភេទមុខរបរឪពុកម្ដាយ (n=១ ៥២០)*

| កត្តាខាងក្នុង | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ២.៥០៨ | ០.៥០២ | ២.០៦២ | ០.០៧ |
| ខាងក្នុងក្រុម | ១៥១៤ | ៣៦៨.២១៧ | ០.២៤៣ | | |

| | | |
|---|---|---|
| សរុប | ១៥១៩ | ៣៧០.៧២៥ |

P>0.0៥

តាមតារាង *២៨* ខាងលើបង្ហាញថា មិនមានភាពខុសគ្នាផ្នែកស្ថិតិទេ រវាងឥទ្ធិពលនៃកត្តាខាងក្នុងលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងស្ថានភាពប្រភេទមុខរបរឪពុកម្តាយ *F*(៥,១៥១៤)=២.0៦, P>0.0៥។

### ក.កត្តាភាពជឿជាក់លើខ្លួនឯង

**កត្តាភាពជឿជាក់លើខ្លួនឯង** ត្រូវបានសាងឡើងដោយកត្តារងចំនួន ៥ ដូចជា៖ ការជ្រើសរើសគោលដៅ ព័ត៌មានអំពីមុខរបរ ការរៀបចំផែនការ ការស្វ័យវាយតម្លៃផ្ទាល់ខ្លួន និងការដោះស្រាយបញ្ហា។

*តារាង 29 ភាពខុសគ្នានៃកត្តាភាពជឿជាក់លើខ្លួនឯង ផ្អែកលើភេទរបស់សិស្ស (n=១៥២0)*

| ភេទ | | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | ការជ្រើសរើសគោលដៅ | ៣.៦៦ | 0.៧៧ | ៣.៦៦ | 0.៦៦ | 0.0៤ | 0.៩៦ |
| ២ | ព័ត៌មានអំពីមុខរបរ | ៣.៨៧ | 0.៧១ | ៣.៩៦ | 0.៧៨ | -២.៥៧ | 0.១0 |
| ៣ | ការរៀបចំផែនការ | ៣.៩១ | 0.៧២ | ៣.៩៧ | 0.៧៣ | -១.៨៧ | 0.0៦ |
| ៤ | ការស្វ័យវាយតម្លៃផ្ទាល់ខ្លួន | ៣.៨៩ | 0.៧១ | ៣.៨៦ | 0.៥៦ | 0.៨៧ | 0.៣៨ |
| ៥ | ការដោះស្រាយបញ្ហា | ៣.៦៦ | 0.៧0 | ៣.៦៧ | 0.៦៧ | -0.១0 | 0.៩២ |

P>0.0៥

តាមតារាង *២៩* ខាងលើបង្ហាញថា ចំពោះការប្រៀបធៀបរវាងការជះឥទ្ធិពលនៃភាពជឿជាក់លើខ្លួនឯង លើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា និងបញ្ហាភេទរបស់សិស្ស មិនមានភាពខុសគ្នាផ្នែកស្ថិតិនោះទេ, P>0.0៥។

*តារាង 30 ភាពខុសគ្នានៃកត្តាភាពជឿជាក់លើខ្លួនឯង ផ្អែកលើប្រភេទមុខរបរឪពុកម្ដាយ (n=១ ៥២០)*

| កត្តាភាពជឿជាក់លើខ្លួនឯង | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ២.៩៥៨ | ០.៥៩២ | ២.០៥៣ | ០.០៧ |
| ខាងក្នុងក្រុម | ១៥១៤ | ៤៣៦.២៨១ | ០.២៨៨ | | |
| សរុប | ១៥១៩ | ៤៣៩.២៣៩ | | | |

P>0.0៥

តាមតារាង *៣០* ខាងលើបង្ហាញថា មិនមានភាពខុសគ្នាផ្នែកស្ថិតិទេ រវាងឥទ្ធិពលនៃភាពជឿជាក់លើខ្លួនឯងលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងស្ថានភាពប្រភេទមុខរបរឪពុកម្ដាយ *F*(៥,១៥១៤)=២.០៥, P>0.0៥។

### ខ.កត្តាលទ្ធផលរំពឹងទុក

**កត្តាលទ្ធផលរំពឹងទុក** ត្រូវបានសាងឡើងដោយកត្តារងចំនួន ២ ដូចជា៖ ឥរិយាបថនៃការទទួលបានការអប់រំ និងឥរិយាបថនៃការជ្រើសរើសអាជីព។

*តារាង 31 ភាពខុសគ្នានៃកត្តាលទ្ធផលរំពឹងទុក ដោយផ្អែកលើភេទរបស់សិស្ស (n=១៥២០)*

| ភេទ | | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | ឥរិយាបថនៃការទទួលបានការអប់រំ | ៣.៧៦ | ០.៧០ | ៣.៧៦ | ០.៦០ | ០.១៦ | ០.៩៨ |
| ២ | ឥរិយាបថនៃការជ្រើសរើសអាជីព | ៣.៨៩ | ០.៦៨ | ៣.៩៣ | ០.៥១ | -១.១៥ | ០.២២ |

P>0.0៥

តាមតារាង *៣១* ខាងលើបង្ហាញថា ចំពោះការប្រៀបធៀបរវាងការជះឥទ្ធិពលនៃលទ្ធផលរំពឹងទុកលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា និងបញ្ហាភេទរបស់សិស្ស មិនមានភាពខុសគ្នាផ្នែកស្ថិតិនោះទេ, P>0.0៥។

*តារាង 32 ភាពខុសគ្នានៃកត្តាលទ្ធផលរំពឹងទុក ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាលទ្ធផលរំពឹងទុក | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ១.៧៨៤ | 0.៣៥៧ | ១.0៩៨ | 0.៣៦ |
| ខាងក្នុងក្រុម | ១៥១៤ | ៤៩១.៩១៩ | 0.៣២៥ | | |
| សរុប | ១៥១៩ | ៤៩៣.៧0៤ | | | |

P>0.0៥

តាមតារាង *៣២* ខាងលើបង្ហាញថា មិនមានភាពខុសគ្នាផ្នែកស្ថិតិទេ រវាងឥទ្ធិពលនៃលទ្ធផលរំពឹងទុកលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងស្ថានភាពប្រភេទមុខរបរឪពុកម្តាយ *F*(៥,១៥១៤)=១.0៩, P>0.0៥។

### គ.កត្តាទេពកោសល្យផ្ទាល់ខ្លួន

**កត្តាទេពកោសល្យផ្ទាល់ខ្លួន** ត្រូវបានសាងឡើងដោយកត្តារងចំនួន ៣ ដូចជា៖ ផ្អែកលើទេពកោសល្យ ផ្អែកលើតម្រូវការផ្ទាល់ខ្លួន និងផ្អែកលើគុណតម្លៃ។

*តារាង 33 ភាពខុសគ្នានៃកត្តាទេពកោសល្យផ្ទាល់ខ្លួន ផ្អែកលើភេទរបស់សិស្ស (n=១៥២0)*

| | ភេទ | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | ផ្អែកលើទេពកោសល្យ | ៣.៥៧ | 0.៧៤ | ៣.៤៨ | 0.៦៥ | ២.៣៨* | 0.0២ |
| ២ | ផ្អែកលើតម្រូវការផ្ទាល់ខ្លួន | ៣.៧៤ | 0.៧២ | ៣.៧២ | 0.៦២ | 0.៥២ | 0.៥៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ផ្អែកលើគុណតម្លៃ | ៣.៧៦ | ០.៧២ | ៣.៨០ | ០.៦៣ | -១.២២ | ០.២២ |

P<0.0៥

តាមតារាង *៣៣* ខាងលើបង្ហាញពីការប្រៀបធៀបកត្តាទេពកោសល្យផ្ទាល់ខ្លួន ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ដោយផ្អែកលើភេទរបស់សិស្ស។ លទ្ធផលវិភាគ T-Test បានបង្ហាញថា កត្តារង *ផ្អែកលើទេពកោសល្យ* មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.0២, P<0.0៥។ លទ្ធផលនេះក៏បង្ហាញដែរថា កត្តារងផ្សេងទៀតដែលមានក្នុងកត្តាទេពកោសល្យផ្ទាល់ខ្លួន មិនមានភាពខុសគ្នានោះទេ បើធៀបនឹងបញ្ហាភេទរបស់សិស្ស។

*តារាង 34 ភាពខុសគ្នានៃកត្តាទេពកោសល្យផ្ទាល់ខ្លួន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាទេពកោសល្យផ្ទាល់ខ្លួន | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ៤.៤៧៥ | ០.៨៩៥ | ២.៤០៥* | ០.០៣ |
| ខាងក្នុងក្រុម | ១៥១៤ | ៥៦៣.៣៥៣ | ០.៣៧២ | | |
| សរុប | ១៥១៩ | ៥៦៧.៨២៨ | | | |

P<0.0៥

តាមតារាង *៣៤* ខាងលើបង្ហាញថា មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត ០.០៣ ទាក់ទងនឹងកត្តាទេពកោសល្យផ្ទាល់ខ្លួន ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងប្រភេទមុខរបរឪពុកម្តាយ។ ករណីនេះ ការវិភាគ Multiple Comparisons ត្រូវបានធ្វើឡើងជាបន្ត ដើម្បីរកឱ្យឃើញថា តម្លៃមធ្យមណាមួយទាបជាង ឬខ្ពស់ជាង។

*តារាង 35 ការលម្អិតភាពខុសគ្នានៃកត្តាទេពកោសល្យផ្ទាល់ខ្លួន ផ្អែកលើប្រភេទមុខរបរឪពុកម្តាយ (n=១ ៥២០)*

| កត្តាទេពកោសល្យផ្ទាល់ខ្លួន | MD | S.E | p-value |
|---|---|---|---|
| **មន្ត្រីរាជការ** | | | |

| | | | |
|---|---|---|---|
| ស្ថាប័នឯកជន | ០.២៣៧ * | ០.០៨១ | ០.០៤ |
| ស្ថាប័នសង្គមស៊ីវិល | ០.៣៤៥ | ០.១៩៦ | ១.០០ |
| អាជីវករ | ០.១១៧ | ០.០៥៦ | ០.៥៩ |
| កសិករ | ០.០៨៩ | ០.០៤៤ | ០.៦១ |
| ផ្សេងៗ | ០.១៥៩ | ០.១៣៣ | ១.០០ |
| **ស្ថាប័នឯកជន** | | | |
| ស្ថាប័នសង្គមស៊ីវិល | ០.១០៧ | ០.២០៥ | ១.០០ |
| អាជីវករ | -០.១២០ | ០.០៨១ | ១.០០ |
| កសិករ | -០.១៤៨ | ០.០៧៣ | ០.៦៦ |
| ផ្សេងៗ | -០.០៧៨ | ០.១៤៥ | ១.០០ |
| **ស្ថាប័នសង្គមស៊ីវិល** | | | |
| អាជីវករ | -០.២២៨ | ០.១៩៧ | ១.០០ |
| កសិករ | -០.២៥៦ | ០.១៩៣ | ១.០០ |
| ផ្សេងៗ | -០.១៨៥ | ០.២៣១ | ១.០០ |
| **អាជីវករ** | | | |
| កសិករ | -០.០២៧ | ០.០៤៥ | ១.០០ |
| ផ្សេងៗ | ០.០៤២ | ០.១៣៣ | ១.០០ |
| **កសិករ** | | | |
| ផ្សេងៗ | ០.០៧០ | ០.១២៨ | ១.០០ |

តារាង *៣៥* ខាងលើបង្ហាញថា មានភាពខុសគ្នាផ្នែកស្ថិតិរវាងការគិតរបស់សិស្សដែលមានឪពុកម្ដាយប្រកបមុខរបរជាមន្ត្រីរាជការ និងស្ថាប័នឯកជន, *F* (៥,១៥១៤)=២.៤១, P<0.0៥។ ការវិភាគ Multiple Comparisons ដោយប្រើ Bonferroni Post Hoc បង្ហាញថា កត្តាទេពកោសល្យផ្ទាល់ខ្លួនជះឥទ្ធិពលលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សដែលមានឪពុកម្ដាយធ្វើការក្នុងស្ថាប័នឯកជន ជាងសិស្សដែលមានឪពុកម្ដាយជាមន្ត្រីរាជការ។ លទ្ធផលវិភាគនេះ ក៏បានបង្ហាញដែរថា សិស្សដែលមានឪពុកម្ដាយធ្វើការជាបុគ្គលិកក្នុងអង្គការសង្គមស៊ីវិល ជាអាជីវករ ជាកសិករ និងប្រកបមុខរបរផ្សេងទៀតទទួលឥទ្ធិពលពីកត្តាទេពកោសល្យផ្ទាល់ខ្លួនមិនខុសគ្នាទេ។

### ឃ.កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន

**កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន** ត្រូវបានសាងឡើងដោយកត្តារងចំនួន ៦ ដូចជា៖ ចំណាប់អារម្មណ៍ ការទទួលស្គាល់ ការអនុវត្ត សមត្ថភាព ភេទ និងការយល់ឃើញ។

*តារាង 36 ភាពខុសគ្នានៃកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ផ្អែកលើភេទរបស់សិស្ស (n=១៥២០)*

| | ភេទ | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១ | ចំណាប់អារម្មណ៍ | ៣.៧៦ | 0.៧៣ | ៣.៨២ | 0.៦២ | -១.៥៥ | 0.១២ |
| ២ | ការទទួលស្គាល់ | ៣.៦៩ | 0.៧៣ | ៣.៦៣ | 0.៦៩ | ១.៥២ | 0.១២ |
| ៣ | ការអនុវត្ត | ៣.៧៤ | 0.៧៣ | ៣.៧២ | 0.៦៤ | 0.៦៦ | 0.៥0 |
| ៤ | សមត្ថភាព | ៣.៦៧ | 0.៧៤ | ៣.៥៧ | 0.៦៧ | ២.៥៦* | 0.0១ |
| ៥ | ភេទ | ៣.៣៩ | 0.៩៤ | ២.៨៦ | ១.0១ | ១0.២៣* | 0.00 |
| ៦ | ការយល់ឃើញ | ៣.៦៥ | 0.៧៣ | ៣.៥៦ | 0.៦៩ | ២.៤៤ | 0.១៤ |

P<0.0៥

តាមតារាង *៣៦* ខាងលើបង្ហាញពីការប្រៀបធៀបកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ដោយផ្អែកលើភេទរបស់សិស្ស។ លទ្ធផលវិភាគ T-Test បានបង្ហាញថា កត្តារង *ភេទ* និង *សមត្ថភាព* មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.00 និង 0.0១, P<0.0៥។ លទ្ធផលនេះក៏បង្ហាញដែរថា កត្តារងផ្សេងទៀតដែលមានក្នុងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន មិនមានភាពខុសគ្នានោះទេ បើធៀបនឹងបញ្ហាភេទរបស់សិស្ស។

*តារាង 37 ភាពខុសគ្នានៃកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ផ្អែកលើប្រភេទមុខរបរឪពុកម្ដាយ (n=១ ៥២០)*

| **កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន** | Df | SS | MS | F | p-value |
|---|---|---|---|---|---|
| រវាងក្រុម | ៥ | ៣.០៦៥ | 0.៦១៣ | ១.៨៩១ | 0.0៩ |
| ខាងក្នុងក្រុម | ១៥១៤ | ៤៩0.៧៨៩ | 0.៣២៤ | | |
| សរុប | ១៥១៩ | ៥៦៧.៨២៨ | | | |

P>0.05

តាមតារាង *៣៧* ខាងលើបង្ហាញថា មិនមានភាពខុសគ្នាផ្នែកស្ថិតិទេ រវាងឥទ្ធិពលនៃអត្តសញ្ញាណផ្ទាល់ខ្លួនលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ធៀបទៅនឹងស្ថានភាពប្រភេទមុខរបរឪពុកម្ដាយ *F*(៥,១៥១៤)=១.៨៩, P>0.05។

## ៤.៣. ការពិភាក្សា

### ៤.៣.១. ការពិភាក្សាលើទិន្នន័យប្រជាសាស្ត្រ

តាមរយៈទិន្នន័យប្រជាសាស្ត្រដែលទទួលបានពីការបំពេញកម្រងសំណួរប្រមូលទិន្នន័យ ពីក្នុងចំណោមសិស្សកំពុងសិក្សាថ្នាក់ទី១២ ចំនួន ១ ៥២០ នាក់ យើងសង្កេតឃើញថា ពួកគេទាំងអស់ស្ថិតក្នុងរបាយក្រុមអាយុចំនួន ៥ ប្រភេទ៖ ក្រុមអាយុ ១៦ ឆ្នាំ មានចំនួន ៦៦ នាក់ ស្មើនឹង ៤.៣% ក្រុមអាយុ ១៧ ឆ្នាំ មានចំនួន ៤៥៤ នាក់ ស្មើនឹង ២៩.៩% ក្រុមអាយុ ១៨ ឆ្នាំ មានចំនួន ៦២៣ នាក់ ស្មើនឹង ៤១% ក្រុមអាយុ ១៩ ឆ្នាំ មានចំនួន ២១៨ នាក់ ស្មើនឹង ១៤.៣% និងក្រុមអាយុ ២០ ឆ្នាំ មានចំនួន ១៥៩ នាក់

ស្មើនឹង ១០.៥%។ ច្បាប់អប់រំកម្ពុជា មាត្រា៣២ បានចែងថា *«ការចុះឈ្មោះចូលសិក្សានៅថ្នាក់ទី១ នៃកម្មវិធីអប់រំចំណេះទូទៅ ត្រូវបានកំណត់ចំពោះកុមារដែលមានអាយុចាប់ពី៦ឆ្នាំ ឬយ៉ាងទាបបំផុត ៧០ខែឡើងទៅ នៅថ្ងៃកំណត់ចូលសិក្សារបស់សាលារៀន»* (នាយកដ្ឋានរដ្ឋបាល, ២០១៩)។ ករណីនេះ ប្រសិនជាការរៀនរបស់សិស្ស មានឱកាសឡើងថ្នាក់រៀងរាល់ឆ្នាំសិក្សានោះ ពួកគេនឹងមានអាយុ ១៨ឆ្នាំនៅថ្នាក់ទី១២។ យោងតាមទិន្នន័យក្រុមអាយុរបស់សិស្សនេះយើងឃើញថា ក្នុងចំណោមសិស្សថ្នាក់ទី១២សរុបខាងលើមានសិស្សចំនួន ២៤.៨% ដែលស្ថិតក្នុងក្រុមអាយុ១៩ និង ២០ឆ្នាំ។ បញ្ហានេះ អាចបណ្តាលមកពីទិដ្ឋភាពចំនួន ២ ចំណុច ជាអាទិ៍៖ *ទី១* លទ្ធភាពនៃការចុះឈ្មោះចូលរៀនដំបូងរបស់កុមារកម្ពុជាក្នុងប្រព័ន្ធអប់រំផ្លូវការ ១២ ឆ្នាំ អាចនៅមានភាពយឺតយ៉ាវ។ ការយឺតយ៉ាវនេះ អាចបណ្តាលមកពីពួកគេមិនមានលទ្ធភាពចូលរៀនបាននៅពេលដល់អាយុត្រូវចូលរៀនស្របតាមច្បាប់កំណត់ ដោយហេតុជាប់រវល់ធ្វើការងារដើម្បីជួយរកចំណូលគ្រួសារ (វិទ្យាស្ថានជាតិស្ថិតិ, ២០២០)។ *ទី២* បើយោងតាមវិទ្យាស្ថានជាតិស្ថិតិ (២០២០) រកឃើញថា ដោយសារពួកគេរៀនមិនសូវពូកែ។ ដូច្នេះ អាយុសិស្សដែលសិក្សានៅថ្នាក់ទី១២ អាចត្រូវបានកើនឡើង ១ឆ្នាំ ឬ ២ឆ្នាំ អាស្រ័យលើការលទ្ធភាពនៃការរៀនត្រួតថ្នាក់របស់ពួកគេក្នុងឆ្នាំសិក្សាមុនៗ។ ជាមួយគ្នានេះ ក៏អាចបណ្តាលមកពីក្រុមសិស្សមួយចំនួនដែលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមិនជាប់ភ្លាម ពួកគេសម្រេចចិត្តរៀនត្រួតថ្នាក់ ១ឆ្នាំ ឬ ២ឆ្នាំបន្ថែម ដើម្បីឱ្យបានប្រឡងជាប់។ ចំណុចនេះ ក៏អាចឆ្លុះបញ្ចាំងលើគុណភាព និងប្រសិទ្ធភាពនៃការរៀននិងបង្រៀនក្នុងប្រព័ន្ធអប់រំចំណេះទូទៅផងដែរ។

របាយទិន្នន័យប្រជាសាស្ត្រដដែលនេះ ក៏បានបង្ហាញសិស្សថ្នាក់ទី១២ ដែលកំពុងរៀននៅក្នុងបណ្តុំថ្នាក់វិទ្យាសាស្ត្រមានចំនួន ៥៦១ នាក់ ស្មើនឹង ៣៦.៩% និងសិស្សនៅបណ្តុំថ្នាក់វិទ្យាសាស្ត្រសង្គមមានចំនួន ៩៥៩ នាក់ ស្មើនឹង ៦៣.១%។ ជាមួយគ្នានេះ ទិន្នន័យដែលប្រមូលក្នុងកម្រងសំណួរផ្នែកទី៣ បង្ហាញថា ក្នុងចំណោមសិស្សសរុប ១ ៥២០ នាក់ ពួកគេបានដាក់គោលដៅជ្រើសរើសមុខជំនាញបន្តការសិក្សានៅកម្រិតឧត្តមសិក្សា លើបណ្តុំមុខជំនាញវិទ្យាសាស្ត្រ សរុបមានចំនួន ៤០.៣% (សុខាភិបាល ១១.៤% កសិកម្ម ៦.២% វិស្វកម្ម ១០% វិទ្យាសាស្ត្រមូលដ្ឋាន ៥.៩% និងបច្ចេកវិទ្យាព័ត៌មានវិទ្យា ៦.៨%) ខណៈ

សិស្សចង់បន្តការសិក្សាលើបណ្ដុំមុខជំនាញវិទ្យាសាស្ត្រសង្គម សរុបមានចំនួន ៥៩.៧% (ធុរកិច្ច ២១% វិទ្យាសាស្ត្រសង្គមនិងសិល្បៈ ១២.៤% ភាសាបរទេស ៤.១% ច្បាប់និងកិច្ចការយុត្តិធម៌ ១៨.៨% និង ទេសចរណ៍និងបដិសណ្ឋារកិច្ច ៣.៤%)។ តាមរយៈទិន្នន័យទាំងពីរប្រភេទនេះឃើញថា សិស្សថ្នាក់ទី១២ ដែលកំពុងរៀនក្នុងបណ្ដុំថ្នាក់វិទ្យាសាស្ត្រ នឹងបន្តការចាប់យកមុខជំនាញសិក្សានៅកម្រិតឧត្តមសិក្សា ក្នុងបណ្ដុំមុខជំនាញវិទ្យាសាស្ត្រដដែល។ ជាមួយគ្នានេះ សិស្សថ្នាក់ទី១២ ដែលកំពុងរៀនក្នុងបណ្ដុំថ្នាក់វិទ្យាសាស្ត្រសង្គម មាននិន្នាការប្រែប្រួលតិចតួចក្នុងការងាកមកចាប់យកមុខជំនាញវិជ្ជាជីវៈ នៅកម្រិតឧត្តមសិក្សាក្នុងបណ្ដុំមុខជំនាញវិទ្យាសាស្ត្រវិញ ប្រសិនបើគណនាមានប្រហែលត្រឹម ៣-៤%។

### ៤.៣.២. ការពិភាក្សាលើសំណួរស្រាវជ្រាវទី១

តាមរយៈការសិក្សាស្រាវជ្រាវ និងបំណកស្រាយខាងលើឃើញថា កត្តាខាងក្រៅ និងកត្តាខាងក្នុង បានរួមចំណែកយ៉ាងសកម្ម ក្នុងដំណើរការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា។ តាមការវិភាគដោយប្រើស្ថិតិពណ៌នាខាងលើឃើញថា តម្លៃមធ្យមរបស់កត្តាខាងក្រៅ (M=៣.៧៦) មានតម្លៃខ្ពស់ជាងបន្តិចលើតម្លៃមធ្យមរបស់កត្តាខាងក្នុង (M=៣.៧២)។ ចំណុចនេះអាចបង្ហាញបានថា កត្តាខាងក្រៅចូលរួមចំណែកក្នុងការធ្វើសេចក្ដីសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ ច្រើនជាងកត្តាខាងក្នុង ឬអាចនិយាយមួយបែបទៀតបានថា សិស្សវិទ្យាល័យនៅកម្ពុជា បានទទួលរងឥទ្ធិពលពីមជ្ឈដ្ឋានខាងក្រៅខ្លួនច្រើន មុននឹងពួកគេធ្វើការសម្រេចចិត្តជ្រើសរើសអាជីពនាថ្ងៃអនាគត។ ខាងក្រោមនេះ គឺជាការពិភាក្សាលម្អិតនៃឥទ្ធិពលលើការជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ដោយផ្អែកលើកត្តានីមួយៗ៖

#### ៤.៣.២.១. កត្តាខាងក្រៅ

**កត្តាខាងក្រៅ** ត្រូវបានសាងឡើងដោយកត្តាតូចៗចំនួន ៤ ជាអាទិ៍៖ កត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច។ តាមការវិភាគដោយប្រើស្ថិតិពណ៌នាខាងលើឃើញថា ក្នុងចំណោមកត្តាតូចៗទាំង៤នេះ *កត្តាសង្គម-សេដ្ឋកិច្ច* ឈរក្នុងលំដាប់ទី១ ដែលទទួលបានតម្លៃមធ្យម ៣.៨៩ *កត្តាសាលារៀន* ឈរក្នុងលំដាប់ទី២ មានតម្លៃមធ្យម ៣.៧៨ *កត្តាគ្រួសារ* ឈរក្នុងលំដាប់ទី៣ មានតម្លៃមធ្យម ៣.៧១ និង *កត្តាព័ត៌មានទីផ្សារការងារ* ឈរក្នុងលំដាប់ទី៤ មានតម្លៃមធ្យម ៣.៦៧។

តាមរយៈលទ្ធផលវិភាគនេះ យើងអាចវាយតម្លៃបានថា ឥរិយាបថនៃការគិតគូរពីអនាគតការងាររបស់យុវជនកម្ពុជានាពេលបច្ចុប្បន្ន ហាក់មានភាពចាស់ទុំច្រើនដោយពួកគេចាប់ផ្តើមយល់ដឹងពីគុណតម្លៃនៃការរស់នៅក្នុងសង្គម និងតាមដាននិន្នាការវិវត្តផ្សេងៗក្នុងសង្គម ជាពិសេសស្ថានភាពវិវត្តផ្នែកសេដ្ឋកិច្ច-សង្គម ដែលជាជ្រុងមួយនៃការជំរុញឱ្យមានកំណើន និងការបង្កើតឱកាសការងារថ្មីសម្រាប់ពួកគេ។ បញ្ហាការរស់នៅប្រចាំថ្ងៃ យុវជនយើងចាប់ផ្តើមមានតម្រូវការក្នុងការទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ ជីវភាពកាន់តែល្អប្រសើរនៅក្នុងសង្គមស៊ីវិល័យ ដែលទាំងនេះជាផ្នែកមួយដ៏សំខាន់ ទាមទារឱ្យបង្កើនការយកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីបំពេញតម្រូវការផ្នែកសង្គម-សេដ្ឋកិច្ច (រាជរដ្ឋាភិបាលកម្ពុជា, ២០១៧)។ ក្នុងន័យនេះ លោក David L. Blustein (2002) បានលើកឡើងពីលទ្ធផលស្រាវជ្រាវរបស់ខ្លួនដែរថា ក្តីកង្វល់របស់ប្រជាជន ពិសេសយុវជន គឺផ្តោតលើបញ្ហាជីវភាពទន់ខ្សោយ វណ្ណៈសង្គមមិនសូវល្អ ហើយពួកគេជារឿយៗតែងធ្វើការប្រៀបធៀបកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ទៅនឹងមជ្ឈដ្ឋានសង្គមដែលគេរស់នៅ។ នៅក្នុងលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបង្ហាញថា យុវជនកម្ពុជាជាសិស្សថ្នាក់ទី១២ បានផ្តោតការចាប់អារម្មណ៍របស់ខ្លួនខ្លាំងទៅលើគោលដៅអាជីពណាដែលអាចផ្តល់ឱ្យពួកគេនូវឋានៈសង្គម និងគុណតម្លៃសង្គម ច្រើនជាងការគិតគូរពីផ្នែកផ្សេងទៀត។ លទ្ធផលនេះ ក៏បានឆ្លើយតបក្នុងន័យស្របគ្នាផងដែរទៅនឹងទស្សនៈយល់ឃើញរបស់លោក Anna P. Chaves (2004) ដែលថា ឋានៈសង្គមត្រូវបានគេសន្មតថាបានដើរតួនាទីជារចនាសម្ព័ន្ធដ៏មានឥទ្ធិពល ក្នុងការអភិវឌ្ឍអាជីពរបស់យុវជន។ អ្នកស្រាវជ្រាវបានណែនាំថា វណ្ណៈសង្គមប៉ះពាល់ដល់លទ្ធភាពនៃការទទួលបានការងារ ការរក្សាស្ថិរភាពការងារ និងគុណតម្លៃការងារ (David L. Blustein, 2002)។ លោក David L. Blustein (2002) បញ្ជាក់បន្ថែមថា យើងបានស្វែងរកដើម្បីបង្កើតការសន្និដ្ឋានអំពីវិធីដែលថ្នាក់សង្គម ជះឥទ្ធិពលលើរបៀបដែលយុវជនចូលទៅជិត និងដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍអាជីព នៅក្នុងការផ្លាស់ប្តូររបស់ពួកគេទៅតួនាទីការងារ។

ដទៃពីនេះ អ្វីដែលមិនអាចកាត់ផ្តាច់ចេញពីមូលដ្ឋានជម្រើសអាជីពរបស់យុវជននោះគឺ ការទទួលរងឥទ្ធិពលពីសាលារៀន។ លទ្ធផលស្រាវជ្រាវបានបង្ហាញពីការរួមចំណែករបស់សាលារៀន ក្នុងជម្រើស

អាជីពរបស់សិស្ស ដោយផ្ដើមចេញពីភាពជោគជ័យនៃលទ្ធផលសិក្សារៀនសូត្ររបស់ពួកគេផ្ទាល់។ លទ្ធផលល្អប្រសើរចេញពីការសិក្សារៀនសូត្ររបស់សិស្ស ជាកត្តាមួយលើកទឹកចិត្ត និងជំរុញឱ្យគេកាន់តែខិតខំប្រឹងប្រែងដើម្បីសម្រេចក្ដីសុបិនអាជីពជាក់លាក់ណាមួយ (Karl L. Alexander, 1997; Susan L. Dauber, 1996)។ លោក Ruth Mampane (2011) យល់ឃើញថា វាជាតួនាទីរបស់សាលារៀន ដែលជួយកុមារតាំងពីវ័យជំទង់ ដើម្បីឱ្យអ្នកសិក្សាស្វែងរកអត្ថន័យនៃជីវិតរបស់ពួកគេ ទាំងក្នុងបច្ចុប្បន្ន និងការងារនាពេលអនាគត។ ក្រោមដំបូលសាលារៀន យុវជនបានចំណាយពេលវេលារបស់ខ្លួនដ៏ច្រើនក្នុងការប្រាស្រ័យទាក់ទងជាមួយលោកគ្រូអ្នកគ្រូ និងមិត្តភក្តិ។ ចេញពីអន្តរទំនាក់ទំនងនៅសាលារៀន សិស្សមានឱកាសក្នុងរៀនសូត្រ និងទទួលឥទ្ធិពលដោយមិនដឹងខ្លួនលើដំណើរជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ការផ្លាស់ប្ដូរជាច្រើនត្រូវបានកើតឡើង ក្នុងអន្តរកម្មសង្គមនៅសាលារៀន តាមរយៈការផ្ដល់ភាពជាគំរូរបស់គ្រូបង្រៀន (Eccles, 2004)។ ស្របគ្នានេះ ការសិក្សាស្រាវជ្រាវអំពីកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យ ក៏បានបង្ហាញពីភាពពាក់ព័ន្ធនៃភាពជាគំរូរបស់គ្រូបង្រៀន ក្នុងការកំណត់នូវគោលដៅជម្រើសអាជីពរបស់សិស្សនៅកម្ពុជាផងដែរ។ មានការសិក្សាមួយចំពោះសិស្សវិទ្យាល័យម៉ិកស៊ិក-អាមេរិក បង្ហាញថា សិស្សភាគច្រើនបានកំណត់យកគ្រូបង្រៀនជាបុគ្គលគំរូ តាមរយៈគំរូភាពជាអ្នកដឹកនាំ និងការណែនាំដោយផ្ទាល់អំពីអាជីព ដែលវាមានឥទ្ធិពលវិជ្ជមានលើការសម្រេចចិត្តលើអាជីពរបស់ពួកគេ (Julius Koech, 2016)។ ដូច្នេះ កត្តាសាលារៀន បានរួមចំណែកដ៏សំខាន់ដល់សិស្សក្នុងការសម្រេចចិត្តជ្រើសរើសអាជីពការងារ។

បន្ថែមលើនេះ កត្តាក្រុមគ្រួសារ បានរួមចំណែកក្នុងលំដាប់ទី៣ ក្នុងចំណោមកត្តាខាងក្រៅទាំង៤ ពាក់ព័ន្ធដំណើរការជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា។ ការសិក្សាស្រាវជ្រាវរកឃើញថា ការយកចិត្តទុកដាក់ផ្ដល់អន្តរាគមន៍គាំទ្រ និងលើកទឹកចិត្តផ្លូវអារម្មណ៍របស់ឪពុកម្ដាយ ជាមួយនឹងការផ្ដល់មូលដ្ឋានព័ត៌មានចាំបាច់មួយចំនួន បានក្លាយជាត្រីវិស័យតម្រង់ទិសអាជីពវិជ្ជាជីវៈរបស់កូនៗនៅក្នុងបន្ទុកយ៉ាងមានប្រសិទ្ធភាព។ ស្របគ្នានឹងការរកឃើញក្នុងបរិបទសិស្សវិទ្យាល័យនៅកម្ពុជានេះ នៅក្នុងការពិនិត្យ

ឡើងវិញដ៏ទូលំទូលាយរបស់ Susan C. Whiston (2004) បង្ហាញថា ក្រុមគ្រួសារមានឥទ្ធិពលលើដំណើរអភិវឌ្ឍអាជីពរបស់យុវជនតាមវិធីជាច្រើនដែលត្រូវបានកត់សម្គាល់ដូចជា៖ ការផ្ដល់នូវភាពជាគំរូតាមរយៈអាជីពដែលឪពុកម្ដាយកំពុងបំពេញការងារជាប្រចាំ និងការគាំទ្រផ្នែកអារម្មណ៍ មនោសញ្ចេតនា ដោយការផ្ដល់ឱ្យនូវភាពកក់ក្ដៅ កម្លាំងចិត្តជាប្រចាំដល់កូនៗ រាប់ចាប់ពីដំណាក់កាលកុមារភាពរហូតដល់ពួកគេក្លាយជាយុវជនពេញវ័យ (Cindy L. Juntunen, 2001; David L. Blustein & Selcuk Sirin, 2002; Susan C. Whiston, 2004)។

ចុងក្រោយគេ គឺកត្តាព័ត៌មានទីផ្សារការងារ បានរួមចំណែកខ្លះៗដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្ស។ ជាក់ស្ដែង ការសិក្សាស្រាវជ្រាវបង្ហាញថា មុននឹងសម្រេចចិត្តជ្រើសរើសមុខជំនាញ ឬអាជីពការងារនាពេលអនាគត សិស្សតែងសិក្សាលើបញ្ហាលក្ខខណ្ឌការងារ តួនាទីនិងការទទួលខុសត្រូវក្នុងអាជីព ឬប្រភេទមុខរបរនោះជាមុនសិន ដើម្បីធានាបាននូវការទទួលបានការងារដែលមានស្ថិរភាពច្បាស់លាស់សម្រាប់ពួកគេ។ ជាធម្មតា វាជាការងារពេញម៉ោងអចិន្ត្រៃយ៍ផ្ដល់ឱ្យនូវប្រាក់ឈ្នួល មុខតំណែង និងតម្លៃសង្គម សមស្របទៅនឹងប្រភេទ និងកម្រិតនៃជំនាញរបស់បុគ្គលម្នាក់ៗ (Schmitt, 2012) ដែលវាគឺជាអ្វីដែលឆ្លុះបញ្ចាំងគ្នាធៀបទៅនឹងការសិក្សាស្រាវជ្រាវនេះរកឃើញ។ ជាមួយគ្នានេះ ការចូលក្នុងទីផ្សារការងារសមរម្យ មានប្រាក់ខែគ្រប់គ្រាន់ មានពេលវេលាកម្សាន្ត មានចំណង់ចង់បង្កើតកសាងគ្រួសារ ទាំងនេះជាធាតុផ្សំដំបូងនៃអត្តសញ្ញាណមនុស្សពេញវ័យ (Jeremy Staff, 2004)។

#### ៤.៣.២.២. កត្តាខាងក្នុង

**កត្តាខាងក្នុង** ត្រូវបានសាងឡើងដោយកត្តាតូចៗចំនួន ៤ ជាអាទិ៍៖ កត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន។ តាមការវិភាគដោយប្រើស្ថិតិពណ៌នាខាងលើឃើញថា ក្នុងចំណោមកត្តាតូចៗទាំង៤នេះ *កត្តាលទ្ធផលរំពឹងទុក* ឈរក្នុងលំដាប់ទី១ មានតម្លៃមធ្យម ៣.៨៤ *កត្តាភាពជឿជាក់លើខ្លួនឯង* ឈរក្នុងលំដាប់ទី២ មានតម្លៃមធ្យម ៣.៨១ *កត្តាទេពកោសល្យផ្ទាល់ខ្លួន* ឈរក្នុងលំដាប់ទី៣ មានតម្លៃមធ្យម ៣.៦៦ និង *កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន* ឈរក្នុងលំដាប់ទី៤ មានតម្លៃមធ្យម ៣.៥៨។

តាមរយៈលទ្ធផលវិភាគនេះ យើងអាចវាយតម្លៃបានថា ឥរិយាបថនៃការគិតគូរពីអនាគតការងារ របស់សិស្សវិទ្យាល័យនៅកម្ពុជាយើង ភាគច្រើនគាត់ទោរទន់ទៅការប្រមើលមើលលទ្ធផលដែលនឹងអាច កើតមានឡើងនាពេលអនាគត។ ពួកគាត់ធ្វើសកម្មភាពពេលនេះ ដើម្បីរំពឹងលើលទ្ធផលដែលនឹងអាចកើត មាននៅថ្ងៃស្អែក។ AllanWigfield (2002) យល់ឃើញថា ការរំពឹងទុកពីជោគជ័យ គឺជាជំនឿរបស់ មនុស្សអំពីរបៀបដែលពួកគេនឹងធ្វើបានល្អលើកិច្ចការណាមួយនាពេលខាងមុខ ចំណែកតម្លៃនៃកិច្ចការ នោះគឺសំដៅលើការលើកទឹកចិត្ត ឬហេតុផលសម្រាប់ការបំពេញកិច្ចការចំពោះមុខ។ ការលើកឡើងពី ទ្រឹស្តីជំនឿជាក់លើសមត្ថភាពខ្លួនឯងរបស់ Bandura (1977) បានបង្ហាញនូវធាតុផ្សំសំខាន់ៗចំនួន ២ គឺៈ ការជឿជាក់លើសមត្ថភាព និងការរំពឹងទុកលើលទ្ធផល។ ឆ្លើយតបទៅនឹងទ្រឹស្តីនេះ ការសិក្សាស្រាវជ្រាវ ក្នុងបរិបទកម្ពុជានាពេលនេះបង្ហាញឱ្យឃើញស្របគ្នាថា កត្តាលទ្ធផលរំពឹងទុក និងភាពជឿជាក់លើខ្លួនឯង បានដើរតួនាទីដ៏សំខាន់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ។ ពួកគេ បានដាក់ចេញនូវសេចក្តីប៉ងប្រាថ្នាផ្សេងៗដោយចង់ឱ្យអាជីពនេះបានផលយ៉ាងនេះ ឬយ៉ាងនោះ សម្រាប់បំពេញតម្រូវការខ្លួន។ ជាមួយគ្នានេះ ការរំពឹងទុកពីលទ្ធផលទទួលបានចេញពីជម្រើសអាជីពណា មួយ ត្រូវបានសន្មតថាជាការចាប់ផ្តើមមួយមានភាពប្រាកដប្រជា (Patrick Ian Armstrong, 2000)។ ទ្រឹស្តីនៃការរំពឹងទុកលើលទ្ធផលនេះ ត្រូវបានលើកយកមកសិក្សាក្នុងដំណាក់កាលជ្រើសរើសអាជីពរបស់ សិស្សវិទ្យាល័យនៅតាមតំបន់ ឬប្រទេសនានា ដើម្បីពិនិត្យមើលនូវភាពជាប់ពាក់ព័ន្ធ និងកម្រិតឥទ្ធិពលរបស់ វាទៅលើការសម្រេចចិត្តរបស់សិស្ស (Saba Rasheed Ali, 2005)។ ទន្ទឹមនេះ ការផ្សារភ្ជាប់ភាពជឿជាក់ លើសមត្ថភាពខ្លួនឯង ទៅនឹងជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ក៏ត្រូវបានរកឃើញសមស្រប ទៅនឹងទ្រឹស្តីរបស់ Bandura (1977) ផងដែរ។ ការសិក្សាស្រាវជ្រាវបានរកឃើញកម្រិតនៃភាពសំខាន់ ដែលរួមចំណែកដល់ការដាក់ចេញនូវវត្ថុបំណងគោលដៅអាជីពរបស់សិស្ស ពាក់ព័ន្ធទៅនឹងកត្តាភាពជឿ ជាក់លើខ្លួនឯងនេះ ស្ថិតក្នុងលំដាប់ទី២ បន្ទាប់ពីកត្តាលទ្ធផលរំពឹងទុក។ ជំនឿជាក់លើខ្លួនឯងនេះ មានឥទ្ធិ ពលលើសេចក្តីប្រាថ្នា និងភាពខ្លាំងនៃការប្តេជ្ញាចិត្តរបស់បុគ្គលម្នាក់ ទៅលើគុណភាពនៃការវិភាគ និងការគិត

ជាយុទ្ធសាស្ត្រ កម្រិតនៃការលើកទឹកចិត្ត និងការតស៊ូក្នុងការប្រឈមមុខនឹងការលំបាក និងបញ្ហាប្រឈមក្នុងជីវិត (Betz, 2000; Nancy E. Betz, 1997b)។ តាមរយៈជំនឿជាក់លើខ្លួនឯងនេះ បានផ្តល់នូវប្រសិទ្ធភាពនៃការយល់ឃើញរបស់មនុស្សកាន់តែខ្ពស់ ដើម្បីបំពេញតម្រូវការអប់រំ ការងារ និងជម្រើសអាជីពដែលពួកគេបានផ្តោតការពិចារណាយ៉ាងយកចិត្តទុកដាក់ ធ្វើការសិក្សាតាមដាន និងផ្តោតការចាប់អារម្មណ៍កាន់តែខ្លាំង។ ការរៀបចំផែនការផ្ទាល់ខ្លួនសម្រាប់ការជ្រើសរើសអាជីព និងការពិចារណាលើប្រភេទអាជីពដែលសក្តិសមសម្រាប់ខ្លួមឯង គឺជាអ្វីដែលសិស្សភាគច្រើននៅកម្ពុជាផ្តោតការយកចិត្តទុកដាក់ខ្ពស់ ក្នុងអំឡុងពេលត្រៀមឆ្លងចូលកម្រិតសិក្សាទី៣ កម្រិតឧត្តមសិក្សានាពេលខាងមុខ។ ជាមួយគ្នានេះ លទ្ធផលស្រាវជ្រាវដែលបានរកឃើញនៅពេលនេះ ទទួលបានលទ្ធផលប្រហាក់ប្រហែលគ្នាទៅនឹងការសិក្សាស្រាវជ្រាវរបស់ Kao Sovansophal (2019) ដែលបានធ្វើឡើងលើក្រុមគោលដៅសិស្សវិទ្យាល័យនៅកម្ពុជាប្រមាណជាជាងមួយពាន់នាក់ដូចគ្នា។ Kao Sovansophal (2019) រកឃើញថា នៅពេលសិស្សមានភាពជឿជាក់លើសមត្ថភាពខ្លួនឯងក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ នោះពួកគេនឹងមាននិន្នាការទោរទន់ទៅរកការជ្រើសរើសមុខជំនាញសិក្សាកម្រិតឧត្តមសិក្សា ពាក់ព័ន្ធនឹងផ្នែកវិទ្យាសាស្ត្រ ឬស្តែមផងដែរ។

លទ្ធផលចេញពីការវិភាគស្ថិតិពណ៌នាខាងលើក៏បានបង្ហាញដែរថា ក្រៅពីកត្តាលទ្ធផលរំពឹងទុក និងកត្តាភាពជឿជាក់លើខ្លួនឯង នៅមានកត្តាទេពកោសល្យផ្ទាល់ខ្លួន និងអត្តសញ្ញាណផ្ទាល់ខ្លួន បានផ្តល់នូវឥទ្ធិពលក្នុងលំដាប់ទី៣ និងទី៤ ដល់ការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា។ ការឆ្លើយតបទៅនឹងកម្រងសំណួរប្រមូលទិន្នន័យផ្តល់មកថា សិស្សភាគច្រើនផ្តោតការយល់ឃើញពាក់ព័ន្ធឥរិយាបថនៃការអប់រំ និងឥរិយាបថនៃការជ្រើសរើសអាជីពក្នុងតម្លៃប្រហាក់ប្រហែលគ្នា នៅពេលពួកគេគិតដល់វិថីអាជីពការងារ។ ការពិនិត្យពីទេពកោសល្យផ្ទាល់ខ្លួនមុននឹងសម្រេចចិត្តជ្រើសរើសអាជីព គឺជាការរួមបញ្ចូលគ្នានូវផ្នែកដែលមើលឃើញពីសមត្ថភាព ការលើកទឹកចិត្ត ការជំរុញចិត្ត អាកប្បកិរិយា និងតម្លៃទាក់ទងនឹងជម្រើសការងារដែលមានជំនាញវិជ្ជាជីវៈ ប្រកបដោយស្ថិរភាពពេញលេញ (W. Brent Barclay, 2013)។ បញ្ហានេះ Schein (1980) ស្នើឱ្យមានពេលវេលាសមរម្យក្នុងការឆ្លុះបញ្ចាំងពីដំណើរអភិវឌ្ឍអាជីពរបស់បុគ្គលណាម្នាក់ តាមរយៈការណ៍ដែលបុគ្គលនោះអាចពិនិត្យមើលបទពិសោធផ្ទាល់ខ្លួន

ដើម្បីកំណត់ថាតើមានប្រភេទការងារ ឬអាជីពអ្វីខ្លះ ដែលពួកគេចង់ធ្វើ និងកន្លែងការងារបែបណាល្អសមរម្យបំផុតសម្រាប់ពួកគេផងដែរ។ ក្នុងការសិក្សាស្រាវជ្រាវមួយរបស់ Hwee-Hoon Tan (2001) នៅប្រទេសសិង្ហបុរីបានបង្ហាញថា ដើម្បីរក្សាមនុស្សដែលមានទេពកោសល្យក្នុងវិជ្ជាជីវៈគ្រូបង្រៀន គឺទាមទារឱ្យបុគ្គលទាំងនោះ មើលឃើញពីគុណសម្បត្តិខាងក្នុងនៃវិជ្ជាជីវៈនេះដោយខ្លួនគេផ្ទាល់ជាកត្តាអាទិភាព។ លទ្ធផលនេះមានភាពស្របគ្នាទៅនឹងអ្វីដែលបានរកឃើញពីការសិក្សាស្រាវជ្រាវមួយនេះ។ បន្ថែមលើនេះ កត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ក៏បានរួមចំណែកក្នុងការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្ស លំដាប់ទី៤ក្នុងចំណោមកត្តាតូចទាំង៤។ លទ្ធផលស្រាវជ្រាវបង្ហាញថា សិស្សផ្តោតការយកចិត្តទុកដាក់លើបញ្ហាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនថាតើអាជីពដែលគេជ្រើសរើសនោះ ឆ្លើយតបទៅនឹងចំណាប់អារម្មណ៍ពួកគេឬអត់។ ជាទូទៅ ការអភិវឌ្ឍចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្សលើការសិក្សាមុខវិជ្ជាសិក្សានីមួយៗ ពិតជាមានសារៈសំខាន់ណាស់។ វាទំនងជាមានទំនាក់ទំនងរវាងការអភិវឌ្ឍចំណាប់អារម្មណ៍ និងជម្រើសអាជីពរបស់សិស្ស ដែលត្រូវពឹងអាស្រ័យទៅលើយល់ឃើញដោយខ្លួនឯងធៀបទៅនឹងអត្តសញ្ញាណផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ (Zahra Hazari, 2010)។ ឱកាស និងចំណាប់អារម្មណ៍ជាក់ស្តែងក្នុងប្រភេទមុខរបរ ឬអាជីព ដែលសិស្សម្នាក់ៗធ្លាប់បានទទួលបទពិសោធ បានរួមចំណែកដល់ការអភិវឌ្ឍវិជ្ជាជីវៈ និងទស្សនៈរបស់ពួកគេលើពិភពការងារ (Fouad, 2007)។ ដទៃពីនេះ គោលគំនិតនៃអាជីព គឺជាការយល់ឃើញផ្ទាល់ខ្លួន ឬគំនិតរបស់បុគ្គលណាម្នាក់ដែលកើតចេញពីបទពិសោធជីវិត និងអន្តរកម្មសង្គមជាក់លាក់មួយ (សង្គម-វប្បធម៌)។ ភាពចម្រុះ ជាអ្វីដែលគួរឱ្យកត់សម្គាល់នៅក្នុងវប្បធម៌នៃការរស់នៅ ជាចំណែកមួយមានឥទ្ធិពលលើជម្រើសអាជីពរបស់បុគ្គលម្នាក់ៗ (Carter, 1991; Michele J. Gelfand, 2007)។ ការលើកឡើងនេះ មានភាពឆ្លើយតបទៅនឹងលទ្ធផលរកឃើញក្នុងការសិក្សាស្រាវជ្រាវនេះ ដែលថាសិស្សវិទ្យាល័យនៅកម្ពុជា មានលទ្ធភាពសម្របខ្លួនទៅនឹងស្ថានភាពនៃការផ្លាស់ប្តូរថ្មីៗក្នុងវប្បធម៌នៃការរស់នៅចម្រុះ។ សរុបមក ការពិភាក្សាខាងលើបានបង្ហាញឱ្យឃើញថា កត្តាតូចៗទាំង៤ សុទ្ធតែបានរួមចំណែកជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជាតាមលំដាប់ពីខ្ពស់មកទាប។

### ៤.៣.៣. ការពិភាក្សាលើសំណួរស្រាវជ្រាវទី២

ការសិក្សាស្រាវជ្រាវ និងបំណកស្រាយខាងលើឃើញថា ការសិក្សាប្រៀបធៀបកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ដោយផ្អែកលើភេទ និងប្រភេទមុខរបរឪពុកម្ដាយសិស្សបានឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ។

តាមរយៈលទ្ធផលនៃសំណួរស្រាវជ្រាវទី២ បានបង្ហាញឱ្យឃើញថា ប្រសិនពិនិត្យលើការសិក្សាពីកត្តាខាងក្រៅជារួម បញ្ហាភេទរបស់សិស្ស មិនបានធ្វើឱ្យមានភាពប្រែប្រួលទៅលើកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់ពួកគេនោះទេ។ ប៉ុន្តែប្រសិនបើយើងសិក្សាលម្អិតពីកត្តាតូចៗទាំង៤ ដែលស្ថិតក្នុងកត្តាខាងក្រៅរួមមាន៖ កត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច ឃើញថាលទ្ធផលនៃការវិភាគ T-Test បានបង្ហាញពីកត្តារង *ការគាំទ្ររបស់មិត្តភក្តិ* និង *ការគាំទ្រផ្នែកសម្ភារៈរៀន និងបង្រៀន* នៃកត្តាសាលារៀន មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.0១, P<0.0៥ និងកត្តារង *ប្រាក់កម្រៃនិងអត្ថប្រយោជន៍* និង *តំណែងតួនាទី* ក្នុងកត្តាព័ត៌មានទីផ្សារការងារ មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.00 និង 0.0១, P<0.0៥ ធៀបទៅនឹងបញ្ហាភេទរបស់សិស្ស។ ដោយឡែក ប្រសិនការពិនិត្យលើការសិក្សាពីកត្តាខាងក្នុងជារួម លទ្ធផលវិភាគ T-Test បានបង្ហាញថា កត្តាតូច *អត្តសញ្ញាណផ្ទាល់ខ្លួន* មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.00, P<0.0៥ ធៀបទៅនឹងបញ្ហាភេទរបស់សិស្ស។ ជាមួយគ្នានេះ ប្រសិនយើងសិក្សាលម្អិតពីកត្តាតូចៗទាំង៤ ដែលស្ថិតក្នុងកត្តាខាងក្នុងរួមមាន៖ កត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន ឃើញថា លទ្ធផលវិភាគ T-Test បានបង្ហាញពី កត្តារង *ផ្អែកលើទេពកោសល្យ* ក្នុងកត្តាទេពកោសល្យផ្ទាល់ខ្លួន មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.0២, P<0.0៥ និងកត្តារង *ភេទ* និង *សមត្ថភាព* ក្នុងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន មានភាពខុសគ្នាផ្នែកស្ថិតិក្នុងកម្រិត 0.00 និង 0.0១, P<0.0៥ ធៀបទៅនឹងបញ្ហាភេទរបស់សិស្ស។ លទ្ធផលនេះ បង្ហាញថា កត្តាសាលារៀន និងកត្តាព័ត៌មានទីផ្សារការងារ (ក្នុងកត្តាខាងក្រៅ) និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន (ក្នុងកត្តាខាងក្នុង) មានឥទ្ធិពលខុសគ្នារវាងសិស្សប្រុស និងសិស្សស្រី ពាក់ព័ន្ធនឹងការគិតគូរពីជម្រើស

អាជីពរបស់ពួកគេទៅថ្ងៃអនាគត។ ការរកឃើញនេះ មានភាពស្របគ្នាទៅនឹងការសិក្សារបស់ Lindsay Noble Calkins (2006) និង Akpan (1986) ដែលបានរកឃើញថា ការជ្រើសរើសមុខវិជ្ជាសិក្សា ឬមុខជំនាញសិក្សាសម្រាប់ថ្ងៃអនាគតរបស់សិស្សកម្រិតវិទ្យាល័យ មានភាពជាប់ពាក់ព័ន្ធ ឬរងឥទ្ធិពលពីបញ្ហាភេទ ចំណាប់អារម្មណ៍ គុណតម្លៃ សមត្ថភាព និងលទ្ធផលសិក្សា។

តាមរយៈលទ្ធផលនៃការសិក្សាដូចបានបកស្រាយ ក្នុងសំណួរស្រាវជ្រាវទី២ខាងលើដដែលឃើញថា ប្រសិនពិនិត្យលើការសិក្សាពីកត្តាខាងក្រៅជារួម ធៀបទៅនឹងប្រភេទមុខរបរឪពុកម្តាយសិស្ស ការវិភាគ Multiple Comparisons ដោយប្រើ Bonferroni Post Hoc កត្តាខាងក្រៅ បង្ហាញពីស្ថានភាព សិស្សដែលរស់នៅក្នុងគ្រួសារមានឪពុកម្តាយធ្វើការងារក្នុងស្ថាប័នឯកជន ទទួលឥទ្ធិពលពីកត្តាខាងក្រៅ លើជម្រើសអាជីពរបស់ខ្លួន ជាងសិស្សដែលមានឪពុកម្តាយធ្វើការងារជាមន្ត្រីរាជការ។ ជាមួយគ្នានេះ សិស្សដែលមានឪពុកម្តាយធ្វើការងារជាកសិករ ក៏ទទួលឥទ្ធិពលពីកត្តាខាងក្រៅលើជម្រើសអាជីពរបស់ខ្លួន ជាងសិស្សដែលមានឪពុកម្តាយធ្វើការងារក្នុងស្ថាប័នឯកជន។ លទ្ធផលវិភាគផ្នែកស្ថិតិនេះ ក៏បានបង្ហាញផងដែរថា សិស្សដែលមានឪពុកម្តាយធ្វើការជាមន្ត្រីរាជការ ជាបុគ្គលិកអង្គការសង្គមស៊ីវិល ជាអាជីវករ និងប្រភេទមុខរបរផ្សេងទៀតនោះ ទទួលឥទ្ធិពលពីកត្តាខាងក្រៅលើជម្រើសអាជីពរបស់ខ្លួនមិនខុសគ្នាទេ។ ជាមួយគ្នានេះ ប្រសិនពិនិត្យលើកត្តាតូចៗទាំង៤ ដែលចំណុះឱ្យកត្តាខាងក្រៅឃើញថា មានតែកត្តាគ្រួសារ និងកត្តាសាលារៀនប៉ុណ្ណោះដែលលទ្ធផលបង្ហាញពីឥទ្ធិពលនៃគ្រួសារ និងសាលារៀន ទៅលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យ មានភាពប្រែប្រួលអាស្រ័យលើប្រភេទមុខរបររបស់ឪពុកម្តាយ។ ភាពប្រែប្រួលនេះស្ថិតនៅតែក្នុងរង្វង់សិស្សដែលមានឪពុកម្តាយបម្រើការងារជាមន្ត្រីរាជការ ជាបុគ្គលិកស្ថាប័នឯកជន និងជាកសិករដូចគ្នា។ ចំណែកសិស្សដែលមកពីគ្រួសារមានឪពុកម្តាយប្រកបរបរជាអាជីវករ បុគ្គលិកស្ថាប័នសង្គមស៊ីវិល និងមុខរបរផ្សេងៗ មានការគិតប្រហាក់ប្រហែលគ្នាជុំវិញការជ្រើសរើសអាជីពនាពេលខាងមុខ។ ដោយឡែក ប្រសិនក្រឡេកមើលស្ថានភាពប្រភេទមុខរបរឪពុកម្តាយ ទៅនឹងកត្តាជះឥទ្ធិពលផ្នែកខាងក្នុងខ្លួនវិញ លទ្ធផលវិភាគបង្ហាញថា មានតែកត្តាទេពកោសល្យផ្ទាល់ខ្លួនប៉ុណ្ណោះ ដែលប្រភេទមុខរបររបស់

ឪពុកម្តាយសិស្ស បណ្តាលឱ្យមានភាពប្រែលប្រួលលើជម្រើសអាជីពរបស់សិស្ស។ ភាពប្រែប្រួលនៃឥទ្ធិពលកត្តាទេពកោសល្យផ្ទាល់ខ្លួននេះ ត្រូវបានកើតឡើងចំពោះតែទៅលើសិស្សដែលមានឪពុកម្តាយជាអ្នកបម្រើការងារក្នុងស្ថាប័នឯកជន ធៀបនឹងឪពុកម្តាយធ្វើការជាអ្នករាជការប៉ុណ្ណោះ។ ជារួម តាមរយៈលទ្ធផលនៃសំណួរស្រាវជ្រាវទី២ ពាក់ព័ន្ធនឹងភាពខុសគ្នានៃប្រភេទមុខរបរឪពុកម្តាយសិស្ស ធៀបទៅនឹងកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្ស គឺមានភាពប្រែប្រួលអាស្រ័យលើស្ថានភាពប្រកបមុខរបររបស់ឪពុកម្តាយសិស្សជាមន្ត្រីរាជការ ជាអ្នកបម្រើការងារក្នុងស្ថាប័នឯកជន ជាអាជីវករ និងជាកសិករ។ លទ្ធផលនេះ ស្របគ្នាទៅនឹងការរកឃើញថ្មីៗរបស់ក្រុមការងារលោក ពៅ សុគុណរិទ្ធ (២០២១) ដែលបង្ហាញពីការជះឥទ្ធិពលលើការសម្រេចចិត្តជ្រើសរើសផ្លូវសិក្សារបស់សិស្សវិទ្យាល័យនៅកម្ពុជា អាស្រ័យមួយផ្នែកលើស្ថានភាពជីវភាពគ្រួសាររបស់ពួកគេផ្ទាល់។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន

# និងសំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

ក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ដោយសំយោគមតិចេញពីក្របខណ្ឌទ្រឹស្ដីក្នុងជំពូកទី២ លទ្ធផលទទួលបានក្នុងជំពូកទី៤ ដើម្បីបង្ហាញឱ្យកាន់តែស៊ីជម្រៅនូវអ្វីដែលបានស្រាវជ្រាវរកឃើញ ថាតើមានភាពឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវកម្រិតណា។ អ្នកស្រាវជ្រាវ ក៏នឹងដាក់ចេញនូវសំណូមពរមួយចំនួនជូនដល់អ្នកពាក់ព័ន្ធក្នុងការកែលម្អ ឬរៀបចំសកម្មភាពការងាររបស់ខ្លួនឱ្យបានកាន់តែល្អប្រសើរ ព្រមទាំងផ្ដល់ជាការណែនាំបង្ហាញផ្លូវដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗ មានមូលដ្ឋានកាន់តែច្បាស់លាស់ក្នុងការសិក្សាស្រាវជ្រាវបន្ត។

## ៥.១. សេចក្តីសន្និដ្ឋាន

ការសិក្សានៅថ្នាក់ទី១២ គឺជាដំណាក់កាលមួយដ៏សំខាន់ដែលសិស្សនឹងត្រូវឆ្លងកាត់របត់ជីវិតសិក្សាពីភូមិសិក្សាទី២ ឈានឆ្ពោះទៅកាន់ភូមិសិក្សាទី៣ ដែលជាវិថីផ្សារភ្ជាប់ទៅនឹងអាជីពការងារ ឬអាចនិយាយបានថា ជាដំណាក់កាលសិស្សត្រូវធ្វើសមាហរណកម្មខ្លួនពីសាលារៀនទៅពិភពការងារ។ ការដាក់ចេញនូវអន្តរាគមន៍ជួយសិស្សឱ្យបានសមស្រប គឺជារឿងមួយដែលត្រូវធ្វើជាចាំបាច់បំផុត ដើម្បីឱ្យដំណើរការចាប់យកជម្រើសអាជីពរបស់ពួកគេមានភាពច្បាស់លាស់ និងអាចផ្ដល់ផលជះជាវិជ្ជមានមកវិញឆ្លើយតបនឹងតម្រូវការផ្នែកសេដ្ឋកិច្ចជាតិ។ ដូចនេះ ការលើកយកមកសិក្សានូវប្រធានបទពាក់ព័ន្ធនឹងកត្តាជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា ជាចំណែកមួយក្នុងការផ្ដល់មូលដ្ឋានអន្តរាគមន៍ចំទិសដៅ។

ឆ្លងតាមការសិក្សាក្នុងជំពូកទី២ លទ្ធផលទទួលបាន និងការពិភាក្សាក្នុងជំពូកទី៤ ខាងលើនេះ អ្នកសិក្សាស្រាវជ្រាវអាចទាញសន្និដ្ឋានចុងក្រោយបានថា ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយបង្ហាញយ៉ាងប្រត្យក្សអំពីកត្តាពាក់ព័ន្ធសំខាន់ៗចំនួន ២ គឺកត្តាខាងក្រៅ និងកត្តាខាងក្នុង ដែលជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា។ បើយើងវែកញែកឱ្យល្អិតល្អន់ កត្តាខាងក្រៅសំដៅលើកត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច។ ចំណែកកត្តាខាងក្នុង

រួមមាន កត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន។ ជារួម យើងអាចសរុបបានថា យ៉ាងហោចមានកត្តាតូចៗចំនួន ៨ ដែលត្រូវបានលើកយកមកសិក្សាក្នុងការស្រាវជ្រាវនេះ។ ផ្អែកលើលទ្ធផលស្រាវជ្រាវដែលទទួលបាន កត្តាពាក់ព័ន្ធទាំង ៨ ខាងលើសុទ្ធតែបានរួមចំណែកក្នុងការផ្តល់ជាមូលដ្ឋានគំនិតដល់សិស្សវិទ្យាល័យនៅកម្ពុជា ធ្វើការពិចារណាភ្ជាប់ទៅនឹងនិន្នាការឥទ្ធិពលរបស់កត្តានីមួយៗតាមស្ថានភាពជាក់ស្តែងរបស់បុគ្គល មុននឹងពួកគេសម្រេចចិត្តជ្រើសរើសអាជីពមុខរបរនាថ្ងៃអនាគត។ ទោះជាយ៉ាងនេះក្តី យើងសង្កេតឃើញថាក្នុងបរិបទកម្ពុជា កត្តាខាងក្រៅ បានដើរតួនាទីសំខាន់ជាងបន្តិចប្រសិនធ្វើការប្រៀបធៀបទៅនឹងកត្តាខាងក្នុង ដែលជះឥទ្ធិពលលើជម្រើសអាជីពរបស់បុគ្គលម្នាក់ៗ។ ការណ៍នេះ បង្ហាញពីភាពខុសគ្នាបន្តិចបន្តួចលើផ្នែកទ្រឹស្តីរបស់ Bandura (1977) ដែលបានលើកឡើងនូវឥទ្ធិពលដ៏សំខាន់របស់កត្តាខាងក្នុង ជាពិសេសកត្តាជំនឿជាក់និងលទ្ធផលរំពឹងទុក ជាការកំណត់ជម្រើសអាជីពរបស់បុគ្គលម្នាក់ៗថាមានភាពសំខាន់ជាងកត្តាផ្សេងៗ។

កត្តាខាងក្រៅ ដែលត្រូវបានផ្សំឡើងដោយកត្តាគ្រួសារ កត្តាសាលារៀន កត្តាព័ត៌មានទីផ្សារការងារ និងកត្តាសង្គម-សេដ្ឋកិច្ច សុទ្ធតែជាចំណែកនៃអន្តរាគមន៍ខាងក្រៅខ្លួនរបស់សិស្ស ដែលពួកគេមានបទពិសោធឆ្លងកាត់ផ្ទាល់ខ្លួន។ ការទទួលបាននូវជំនួយផ្នែកស្មារតីពីអ្នកនៅជុំវិញខ្លួន ពិសេសការផ្តល់នូវការគាំទ្រផ្នែកផ្លូវចិត្តពីក្រុមគ្រួសារ ការបង្ហាញនូវភាពជាគំរូរបស់ឪពុកម្តាយ ការគាំទ្រលើកទឹកចិត្តពីគ្រូបង្រៀន ពីមិត្តភក្តិលទ្ធភាពទទួលបានលទ្ធផលសិក្សារៀនសូត្រល្អប្រសើរ ការទទួលបានព័ត៌មានអំពីលក្ខខណ្ឌនៃការអនុវត្តអាជីពការងារនីមួយៗ ព្រមទាំងតម្លៃសង្គមចេញពីអាជីពការងារនីមួយៗ សុទ្ធតែជាអ្វីដែលបានរួមចំណែកដល់ការពិចារណាសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្ស នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ដែលការសិក្សាស្រាវជ្រាវនេះបានរកឃើញ។ ការណ៍នេះយើងអាចសន្និដ្ឋានបានថា នៅពេលដែលមជ្ឈដ្ឋានខាងក្រៅជុំវិញខ្លួន បានផ្តល់ ឬបំពេញតម្រូវការជាមូលដ្ឋានដល់សិស្សបានពេញលេញតាមតួនាទីភារកិច្ចរបស់ខ្លួន នោះលទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្តច្បាស់លាស់របស់សិស្សលើបញ្ហាជម្រើសអាជីព ក៏ពិតជាកាន់តែមានភាពល្អប្រសើរ។ ឪពុកម្តាយ និងសមាជិកគ្រប់គ្នាក្នុងគ្រួសារ ជាចំណែកមួយសំខាន់ក្នុងការទទួល

ខុសត្រូវលើដំណើរជ្រើសរើសអាជីពរបស់កូនៗពួកគេ ក្នុងដំណាក់កាលត្រៀមឆ្លងភូមិសិក្សាចំណេះទូទៅឈានឆ្ពោះទៅកាន់មាគ៌ាអាជីព តាមរយៈការចាប់យកមុខជំនាញសិក្សានៅកម្រិតឧត្តមសិក្សា។ ទន្ទឹមនេះតួអង្គរឹតតែសំខាន់ជាងគ្រួសារទៅទៀតនោះ គឺសាលារៀនដែលជាជំបូលរួមគ្នារវាងគ្រូនិងសិស្ស។ ស្ទើរតែពាក់កណ្តាលនៃពេលវេលាក្នុងមួយថ្ងៃៗ ឬអាចច្រើនជាងនេះ សិស្សត្រូវស្ថិតក្នុងសាលារៀនដើម្បីសិក្សារៀនសូត្របង្កើនចំណេះដឹងមុខវិជ្ជារបស់ខ្លួនផង និងរៀនសូត្រពីអ្វីដែលពួកគេជួបប្រទះប្រចាំថ្ងៃនៃទំនាក់ទំនងនៅសាលារៀនផង ដែលពេលខ្លះសិស្សខ្លួនឯងអាចនឹងទទួលយកនូវឥរិយាបថថ្មីដោយមិនដឹងខ្លួន។ ពេលវេលាសេសសល់ក្រៅពីការស្នាក់នៅផ្ទះជាមួយគ្រួសារ និងការសិក្សានៅសាលារៀន គឺជាពេលវេលាដែលសិស្សត្រូវស្ថិតក្នុងមជ្ឈដ្ឋានសង្គមដែលគេរស់នៅ។ អ្វីដែលពួកគេឆ្លងកាត់បទពិសោធ អាចនឹងមានឥទ្ធិពលទៅលើការគិត និងការកំណត់គោលដៅក្នុងកម្រិតណាមួយ តួយ៉ាងដូចជាពាក់ព័ន្ធនឹងការជ្រើសរើសផ្លូវអាជីពថ្ងៃអនាគតជាដើម។

កត្តាខាងក្នុង ដែលបានមកពីកត្តាភាពជឿជាក់លើខ្លួនឯង កត្តាលទ្ធផលរំពឹងទុក កត្តាទេពកោសល្យផ្ទាល់ខ្លួន និងកត្តាអត្តសញ្ញាណផ្ទាល់ខ្លួន សុទ្ធតែជាអន្តរាគមន៍ផុសចេញពីក្នុងខ្លួនរបស់បុគ្គលផ្ទាល់ ដែលមិនអាចនឹងមើលឃើញដោយភ្នែក។ លទ្ធផលស្រាវជ្រាវពាក់ព័ន្ធនឹងកត្តាទាំងនេះ បានបង្ហាញយ៉ាងច្បាស់ថាសមត្ថភាពលើការសិក្សារៀនសូត្រ ជំនឿជាក់លើអ្វីដែលខ្លួនបានធ្វើ ការបង្កើតក្តីស្រមៃថាអ្វីដែលនឹងអាចកើតមានឡើងចេញពីសកម្មភាពនៃការប្រព្រឹត្តផ្ទាល់ខ្លួន ចំណាប់អារម្មណ៍ ការយល់ឃើញផ្ទាល់ខ្លួន បញ្ហាភេទរបស់បុគ្គលផ្សារភ្ជាប់នឹងជម្រើសផ្សេងៗជាដើម សុទ្ធតែជាចំណែកដែលមានភាពពាក់ព័ន្ធទៅដល់ការសម្រេចចិត្តកំណត់គោលដៅអាជីពការងារនាពេលអនាគត របស់សិស្សវិទ្យាល័យនៅកម្ពុជា។ នៅពេលដែលសិស្សម្នាក់ បានដាក់ចេញនូវគោលជំហរជាក់លាក់ដោយមានជំនឿមុតមាំថា ការខិតខំប្រឹងប្រែងសិក្សារៀនសូត្រឱ្យបានគត់មត់ គេនឹងអាចទទួលបានលទ្ធផលល្អប្រសើរ នោះកម្លាំងចលករជំរុញទឹកចិត្តពីខាងក្នុងក៏នឹងកាន់តែមានភាពពុះកញ្ជ្រោលក្លៀវក្លា ញ៉ាំងឱ្យសិស្សរូបនោះបង្កើនសកម្មភាពរៀនសូត្រទ្វេរដងដោយមិនមានភាពនឿយហត់។ យ៉ាងណាមិញ សិស្សដែលបានដាក់ក្តីស្រមៃក្នុងរូបភាពការងារណាមួយនាពេល

អនាគត ជាចំណែកមួយជួយឱ្យរូបគេបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងសកម្មភាពពេលបច្ចុប្បន្នកាន់តែខ្លាំងដូចនោះដែរ។ ជាមួយគ្នានេះ ការយល់ដឹងពីសមត្ថភាពផ្ទាល់ខ្លួន ចំណុចខ្លាំងចំណុចខ្សោយ ក៏ជាចំណែកមួយជួយឱ្យសិស្សអាចផ្សារភ្ជាប់ទៅនឹងនិន្នាការព័ត៌មានអំពីការងារដែលពួកគេបានដឹងឮ និងសាកល្បងកំណត់អាជីពជាជម្រើសសមស្របផ្ទាល់ខ្លួនបានល្អ។ បន្ថែមលើនេះ ចំណាប់អារម្មណ៍ ផ្ដើមចេញពីចំណូលចិត្តផ្ទាល់ខ្លួនសាមញ្ញៗ ក៏បានជះឥទ្ធិពលដល់ការរៀបចំផែនការអាជីពផងដែរ។ ឧទាហរណ៍ សិស្សអាចឆ្លុះបញ្ចាំងខ្លួនឯង ថាតើគេចូលចិត្តការជជែកពិភាក្សាវែកញែក និងការចូលរួមធ្វើកិច្ចការជាក្រុម ឬការចូលរួមព្រឹត្តិការណ៍សង្គមឬទេ ក្នុងការរៀនសូត្រ និងរស់នៅប្រចាំថ្ងៃ។ ប្រសិនជាគេចូលចិត្តសកម្មភាពបែបនេះពិតណាស់ថា សិស្សរូបនោះអាចនឹងដាក់គោលដៅអាជីពជាអ្នកធ្វើការងារក្នុងវិស័យសង្គមកិច្ច។ ជារួមកត្តាខាងក្នុង ជាអ្វីមួយដែលអាចស្ដែងឱ្យឃើញតាមរយៈសកម្មភាព និងឥរិយាបថផ្ទាល់ខ្លួនរបស់សិស្សដែលវាជាចំណែកមួយដែលរួមចំណែកក្នុងការកំណត់គោលដៅអាជីពរបស់សិស្សផងដែរ។

## ៥.២. សំណូមពរ

តាមរយៈលទ្ធផលសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវសូមស្នើឡើងនូវសំណូមពរមួយចំនួនដល់សមាសភាពពាក់ព័ន្ធសំខាន់ៗជាអាទិ៍៖ អ្នករៀបចំគោលនយោបាយនិងផែនការ អ្នកអនុវត្តកម្រិតសាលារៀន មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស សាមីខ្លួនសិស្ស អ្នកសិក្សាស្រាវជ្រាវ ដូចខាងក្រោម៖

### ៥.២.១. អ្នករៀបចំគោលនយោបាយនិងផែនការ

ក្នុងស្មារតីរួមចំណែកពង្រឹងគុណភាពមូលធនមនុស្សកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ច និងសង្គម អ្នករៀបចំគោលនយោបាយនិងផែនការអប់រំ និងអង្គភាពពាក់ព័ន្ធកម្រិតថ្នាក់ជាតិ (ក្រសួងអប់រំ យុវជន និងកីឡា) គួរពិនិត្យលទ្ធភាពក្នុងការពង្រឹងក្របខណ្ឌនៃការអនុវត្តគោលនយោបាយមគ្គុទ្ទេសក៍អាជីព និងការផ្ដល់ប្រឹក្សា និងពង្រីកគោលដៅអនុវត្តកម្មវិធីនេះឱ្យបានទៅដល់គ្រប់គ្រឹះស្ថានសិក្សា ឬក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិជាអាទិភាព ដើម្បីជាផ្នែកមួយនៃប្រព័ន្ធអន្តរាគមន៍គាំទ្រដល់ដំណើរការឆ្លងភូមិសិក្សារបស់សិស្សឈានឆ្ពោះទៅការចាប់យកមុខជំនាញសិក្សា អាជីពការងារ ប្រភេទមុខរបរ បានសមរម្យស្របទៅ

នឹងទេពកោសល្យ ចំណាប់អារម្មណ៍ បំណិនប្រសប់ និងគុណតម្លៃផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ។ ជាមួយគ្នានេះ ស្ថាប័នទទួលបន្ទុកលើប្រព័ន្ធព័ត៌មានទីផ្សារការងារកម្ពុជា គួរបង្កើនកិច្ចសហប្រតិបត្តិការស្អិតរមួតជាមួយស្ថាប័នអប់រំ ដើម្បីចែករំលែក ផ្លាស់ប្តូរព័ត៌មាន កសាងឯកសារជំនួយស្មារតីពាក់ព័ន្ធនឹងនិន្នាការវិវត្ត ក៏ដូចជាបច្ចុប្បន្នភាពព័ត៌មានទីផ្សារការងារ (ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ) និងផ្សព្វផ្សាយឱ្យបានទូលំទូលាយជ្រួតជ្រាបដល់កម្រិតសាលារៀន ដើម្បីជាទុនមូលដ្ឋានដល់ការសម្រេចចិត្តជ្រើសរើសមុខជំនាញសិក្សាកម្រិតឧត្តមសិក្សា និងការកំណត់គោលដៅអាជីពមុខរបររបស់សិស្សបានកាន់តែមានភាពច្បាស់លាស់។

### ៥.២.២. អ្នកអនុវត្តកម្រិតសាលារៀន

ផ្អែកលើលទ្ធផលស្រាវជ្រាវខាងលើ សាលារៀនគឺជាផ្នែកមួយដ៏សំខាន់ដែលជះឥទ្ធិពលដល់ជម្រើសអាជីពរបស់សិស្សក្នុងរូបភាពផ្សេងៗ។ ដូចនេះ សាលារៀន ជាពិសេសគណៈគ្រប់គ្រង និងបុគ្គលិកអប់រំតាមអង្គភាពសាមី ក្រៅពីការបំពេញមុខងារក្នុងការពង្រឹងគុណភាពនិងប្រសិទ្ធភាពអប់រំហើយនោះ ការពង្រឹងយន្តការផ្ទៃក្នុងលើកិច្ចការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា (សម្រាប់សាលារៀនដែលត្រូវបានក្រសួងដាក់ឱ្យអនុវត្តកន្លងមករួចហើយ) និងអន្តរាគមន៍លើការងារអប់រំតម្រង់ទិសវិជ្ជាជីវៈដល់សិស្ស (ថ្នាក់ទី១២ជាអាទិភាព) គឺជាកិច្ចការសំខាន់មួយទៀតចំពោះមុខដែលគួរត្រូវបានអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះ ដោយហេតុភាពជាគំរូរបស់គ្រូបង្រៀនជាចំណែកមួយជះឥទ្ធិពលលើជម្រើសអាជីពរបស់សិស្ស ដូចនេះ គ្រូបង្រៀនគ្រប់រូបគួរពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ ពង្រឹងពង្រីកគុណវុឌ្ឍិ ពង្រីកវិសាលភាពចំណេះដឹងទូទៅឱ្យកាន់តែទូលំទូលាយ ជាពិសេសចំណេះដឹងពាក់ព័ន្ធព័ត៌មានទីផ្សារការងារ បរិវត្តកម្មឌីជីថលជាដើម ដើម្បីបានជាប្រយោជន៍ដល់ការចែករំលែកបន្តដល់សិស្សរបស់ខ្លួន ជំរុញឱ្យពួកគេមានលទ្ធភាពកាន់តែប្រសើរជាមុន ក្នុងការត្រៀមខ្លួនធ្វើសមាហរណកម្មចូលទីផ្សារការងារ និងដំណើរការនានានៃសង្គមជាតិ ឆ្លើយតបទៅនឹងវត្ថុបំណងកម្មវិធីសិក្សា និងក្របខណ្ឌគោលនយោបាយជាតិ។

### ៥.២.៣. មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស

តួនាទីដ៏សំខាន់របស់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ត្រូវបានរកឃើញថាមានឥទ្ធិពលខ្លាំងទៅលើការសម្រេចចិត្តជ្រើសរើសអាជីពរបស់សិស្សវិទ្យាល័យនៅកម្ពុជា។ ផ្អែកលើតួនាទីនេះ មាតាបិតា ឬអ្នកអាណាព្យាបាលគ្រប់រូប គប្បីពង្រឹងការសមត្ថភាពចាប់យកចំណេះដឹងថ្មីៗ និងនិន្នាការវិវត្តជាវិជ្ជមានផ្សេងៗក្នុងសង្គម ដើម្បីជាចំណែកមួយជួយផ្តល់មូលដ្ឋានគាំទ្រដល់កូនៗរបស់ខ្លួន ក៏ដូចជាផ្តល់នូវព័ត៌មានសំខាន់ៗចាំបាច់ដល់ពួកគេ ជាពិសេសក្នុងដំណាក់កាលត្រៀមបញ្ចប់ការសិក្សាកម្រិតវិទ្យាល័យឈានចូលការជ្រើសរើសមុខជំនាញនៅឧត្តមសិក្សាតែម្តង។ បន្ថែមលើនេះ ការចំណាយពេលវេលាក្នុងក្រុមគ្រួសារបង្កើនការយកចិត្តទុកដាក់ ការបង្ហាញឱ្យឃើញនូវការគាំទ្រលើកទឹកចិត្តតាមរូបភាពផ្សេងៗ ការអប់រំតម្រង់ទិសសិក្សា និងការងារ ការផ្តល់នូវភាពជាគំរូទាំងគំរូក្នុងភាពជាមាតាបិតាទាំងគំរូក្នុងភាពជាបុគ្គលិកបំពេញការងារតាមស្ថាប័ននានាប្រចាំថ្ងៃ ទាំងនេះគឺជាអ្វីដែលសំខាន់បំផុតដែលមាតាបិតា ឬអ្នកអាណាព្យាបាលត្រូវធ្វើ ដើម្បីមាគ៌ាអនាគតល្អដល់កូនៗរបស់ខ្លួន។ ក្នុងន័យនេះ មាតាបិតា ឬអ្នកអាណាព្យាបាលគ្រប់រូប គឺជាចំណែកមួយនៃការទទួលខុសត្រូវសំខាន់ ក្នុងដំណើរការអភិវឌ្ឍការអប់រំ បុគ្គលិកលក្ខណៈ និងអាជីពរបស់កូនៗខ្លួនឯងផ្ទាល់។

### ៥.២.៤. សាមីខ្លួនសិស្ស

លទ្ធផលសិក្សាស្រាវជ្រាវក៏បានរកឃើញថា កត្តាសិស្សផ្ទាល់ខ្លួនក៏រួមចំណែកជះឥទ្ធិពលដល់ការគិតគូរពីបញ្ហាអាជីពមុខរបរនាថ្ងៃអនាគតរបស់ពួកគេផងដែរ។ ដូចនេះ ក្នុងតួនាទីជាសិស្ស ក្រៅតែពីការខិតខំសិក្សារៀនសូត្រក្រេបយកចំណេះដឹងលើមុខវិជ្ជាស្របតាមកម្មវិធីសិក្សាហើយនោះ ការពង្រីកវិសាលភាពចំណេះដឹងបន្ថែម ការសិក្សាស្រាវជ្រាវរាវរកព័ត៌មានសំខាន់ៗតួយ៉ាងដូចជា ព័ត៌មានទីផ្សារការងារ ព័ត៌មានអាហារូបករណ៍ ព័ត៌មានអំពីអាជីព ព័ត៌មានអំពីគ្រឹះស្ថានឧត្តមសិក្សា ឬគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនានា ក៏គួរត្រូវបានធ្វើឡើងជារឿយៗ ដើម្បីជាផ្នែកមួយនៃកញ្ចប់ព័ត៌មានជំនួយដល់ការសម្រេចចិត្តជ្រើសរើសអាជីពផ្ទាល់ខ្លួនបានសមរម្យ។ ជាមួយគ្នានេះ ការសិក្សាឈ្វេងយល់ និងឆ្លុះបញ្ចាំងអំពីខ្លួនឯងនូវ

ទិដ្ឋភាពបុគ្គលិកលក្ខណៈ ចំណាប់អារម្មណ៍ បំណិនប្រសប់ គុណតម្លៃ ក៏ជារឿងចាំបាច់ផងដែរ រួចសាកល្បងបន្ស៊ីអ្វីខ្លួនឯងមាន ផ្សារភ្ជាប់ទៅនឹងចរិតលក្ខណៈនៃអាជីពណាមួយដែលខ្លួនចង់ធ្វើ ដើម្បីកំណត់ថាតើអាជីពនោះ សក្តិសមនឹងខ្លួនឯងដែរឬទេ ហើយគួរត្រៀមខ្លួនដូចម្តេចខ្លះ ទើបអាចទទួលបានអាជីពដែលខ្លួនពេញចិត្ត។ ក្នុងន័យនេះ សិស្សម្នាក់ៗគួរគប្បីកាត់បន្ថយឱ្យបានជាអតិបរមានូវការសម្រេចចិត្តជ្រើសរើសអាជីពក្នុងទំនោរតាមគ្នា ដោយមិនបានសិក្សាស្វែងរកព័ត៌មាន និងពិចារណាឱ្យបានហ្មត់ចត់ជាមុន។

### ៥.២.៥. អ្នកសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងក្នុងក្របខណ្ឌដែនកំណត់ផ្តោតយកត្រឹមតែសិស្សថ្នាក់ទី១២ ហើយពាក់ព័ន្ធតែទៅលើកត្តាជះឥទ្ធិពលនៃជម្រើសអាជីពរបស់ពួកគេតែប៉ុណ្ណោះ។ ចំណែកគោលបំណងនៃការសិក្សាស្រាវជ្រាវនេះទៀតសោត ត្រូវបានដាក់ចេញត្រឹមការរកឱ្យឃើញនូវកត្តាជះឥទ្ធិពល និងសិក្សាប្រៀបធៀប ឥទ្ធិពលនៃកត្តាទាំងនោះទៅនឹងបញ្ហាភេទ និងប្រភេទមុខរបររបស់ឪពុកម្តាយសិស្ស។ តាមរយៈនេះ អ្នកសិក្សាស្រាវជ្រាវក្រោយៗ អាចបន្តសិក្សាឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតលើក្រុមសំណាកជានិស្សិតកម្រិតឧត្តមសិក្សា (ឆ្នាំទី១) ដើម្បីរកឱ្យឃើញនូវគោលដៅជម្រើសអាជីព និងកត្តាជះឥទ្ធិពលពាក់ព័ន្ធ។ បន្ថែមលើនេះ ប្រធានបទពាក់ព័ន្ធនឹងការរៀបចំគន្លងអាជីពរបស់សិស្សចំណោះទូទៅនៅកម្ពុជា ក៏គួរត្រូវបានលើកយកមកសិក្សានៅពេលក្រោយផងដែរ ដ្បិតថា វាជាបន្ទាត់តម្រង់ទិសវិជ្ជាជីវៈមួយដ៏សំខាន់នៃប្រព័ន្ធអន្តរាគមន៍អាជីព ដើម្បីផ្តល់ការគាំទ្រដល់សិស្សឱ្យមានលទ្ធភាព និងសមត្ថភាពកាន់តែពេញលេញក្នុងការធ្វើសមាហរណកម្មចូលទីផ្សារការងារដែលមានភាពប្រកួតប្រជែង ដោយអាចជណ្តើមបាននូវមោទនភាពសម្រាប់ខ្លួនឯង ក្រុមគ្រួសារ និងសង្គមជាតិ៕

# ឯកសារយោង

# ឯកសារយោង

ក្រសួងអប់រំយុវជននិងកីឡា. (២០១១). *គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា*. គណៈរដ្ឋមន្ត្រី។

ក្រសួងអប់រំយុវជននិងកីឡា. (២០១៩). *ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០: គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤*. អយក។

ក្រសួងអប់រំយុវជននិងកីឡា. (២០២១a). *គោលនយោបាយស្តីពី មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា*. អយក។

ក្រសួងអប់រំយុវជននិងកីឡា. (២០២១b). *ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជា ឆ្នាំ២០៣០*. អយក។

ក្រសួងអប់រំយុវជននិងកីឡា. (២០២១c). *យុទ្ធសាស្ត្រអនុវិស័យការអប់រំមធ្យមសិក្សា ២០២១-២០៣០*. អយក។

ក្រសួងអប់រំយុវជននិងកីឡា. (២០២២a). *សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២០-២០២១ និងទិសដៅឆ្នាំសិក្សា២០២១-២០២២*. អយក។

ក្រសួងអប់រំយុវជននិងកីឡា. (២០២២b). *ស្ថិតិ និងសូចនាករអប់រំសាធារណៈ ២០២១-២០២២*. អយក។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា. (២០១៩). *របាយការណ៍ស្តីពី តម្រូវការជំនាញ និងកម្លាំងពលកម្មសម្រាប់ការវិនិយោគនៅកម្ពុជា*។

ណារ៉ុន, ហ. ជ. ន. (2020). *កំណែទម្រង់សាលារៀននៅកម្ពុជា*. អយក។

នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ. (២០២១). *ឯកសារណែនាំប្រតិបត្តិស្តីពី មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា (សម្រាប់គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន)*. ក្រសួងអប់រំ យុវជន និងកីឡា។

នាយកដ្ឋានរដ្ឋបាល. (២០១៩). *ឯកសារស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា*. អយក។

ពៅ សុគុណរិទ្ធ, ជ. យ. រ. ឋ., អ៊ុប ប៊ុនណាត, ហាក់ មករា, សៀង លីនដា, ស៊ុក សុផល. (២០២១). *កត្តាជះឥទ្ធិពលលើការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងប្រទេសកម្ពុជា*. អយក។

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥a). *គោលនយោបាយជាតិស្តីពី មុខរបរនិងការងារឆ្នាំ២០១៥-២០២៥*. ទីស្តីការគណៈរដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥b). *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥*. ទីស្តីការគណៈរដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា. (២០១៧). *ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥*. ទីស្តីការគណៈរដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា. (២០១៨). *ក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០*. ទីស្តីការគណៈរដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា. (២០១៩). *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*. ទីស្តីការគណៈរដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា. (២០២១). *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*. ទីស្តីការគណៈរដ្ឋមន្ត្រី។

វិទ្យាស្ថានជាតិស្ថិតិ. (២០២០). *របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកម្ពុជាឆ្នាំ២០១៩/២០*. ក្រសួងផែនការ។

សាំង សុចិន្តា, ក. ង. ស. ង. ង., ស៊ឹម វិសុទ្ធ, ឈឹម ភារី, យាង ប៉េងលី. (២០១៩). *ការជ្រើសរើសជំនាញបន្តការសិក្សាថ្នាក់ឧត្តមសិក្សារបស់សិស្សថ្នាក់ទី១២ នៅរាជធានី-ខេត្ត*. ព្រឹត្តិបត្រស្រាវជ្រាវអប់រំនៃវិទ្យាស្ថានជាតិអប់រំ, ៤, ៥០-៧៥។

ហ៊ុនឡេង, ហ. (2018). *ព័ត៌មានអាជីព: ជ្រើសរើសការងារ និងអាជីពដែលសមស្រប*. National Employment Agency។

Akpan, E. U. U. (1986). Factors affecting students' choice of science subjects in Nigerian secondary schools. *Research in Science & Technological Education*, *4*(1), 99-109. https://doi.org/10.1080/0263514860040110

Albert Bandura, C. B., Gian Vittorio Caprara, and Concetta Pastorelli. (2001). Self-efficacy beliefs as shapers of children's aspirations and career trajectories. *Child Development*, *72*(1), 187-206. https://doi.org/10.1111/1467-8624.00273

Alderfer, D. A. T. A. C. P. ( 1989 ). The influence of race on career dynamics: Theory and research on minority career experiences. In d. t. H. Michael b. Arthur, barbara s. Lawrence ( Ed. ), *Handbook of career theory* ( pp. 133-158 ). University of Cambridge.

AllanWigfield, J. S. E. a. ( 2002 ). Motivational beliefs, values, and goals. *Annual Review of Psychology*, *53*, 109-132.

Almon Shumba, M. N. ( 2012 ). Factors influencing students' career choice and aspirations in South Africa. *Journal of Social Sciences*, *32*( 2 ), 169-178. https://doi.org/10.1080/09718923.2012.11893096

